សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា

# KhmerPost USA

E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

# អ្នកស្រី យោម បុប្ផា ទទួលពានរង្វាន់នៅស.រ.អា

**ដោយ : ពិន សំខុន**

បសស្តុន-អង្គការណុនវាយឡិនខនហ្វ្លិក (Non violence Conflict) ពីភពលោកមួយមានទីស្នាក់ការនៅបសស្តុនបានប្រគល់ពានរង្វាន់ ជេម ឡសុន អាវដ (James Lawson Award) ជាកិត្តិយសដល់ជ័យលាភី

**តទៅទំព័រទី ០២**



## Yorm Bopha to Receive Awards for Outstanding Achievement in the Field of Nonviolent Resistance

**Continued to Page 02**









Continued from Page 01

# Yorm Bopha to Receive Awards for Outstanding...

Medford/Somerville, Massachusetts, June 16, 2014 - In the wake of the Arab Spring and as nonviolent movements in Ukraine, Thailand, Brazil, and around the world capture the global public's attention, on Wednesday, June 18th, two activists will be recognized for their courageous use of strategic nonviolent tactics to win human rights and justice, and two prominent scholars will be honored for their ground-breaking contributions to the field of civil resistance.




The James Lawson Awards are named after and presented in person by James Lawson, a leader in US Civil Rights movement who led the Nashville Lunch Counter sit-ins of 1960 and who Martin Luther King, Jr. called, "the leading theorist and strategist of nonviolence in the world."

### The four Lawson awardees are:

Yorm Bopha, a 30-year old leader of a land rights movement in Cambodia who has boldly struggled alongside her community against forced evictions by the Cambodian government. As a result of her nonviolent activism, she was arrested on trumped up charges in September 2012 and became an Amnesty International Prisoner of Conscience while imprisoned for 444 days. In the face of government retribution, her commitment to nonviolent struggle has not wavered.

Kumi Naidoo, a human rights activist from South Africa and the current International Executive Director of Greenpeace since 2009. Naidoo was an organizer and activist in the struggle against apartheid in South Africa, and as the international executive director of Greenpeace, has continued to personally commit daring acts of direct nonviolent action for environmental protection. In 2011 Kumi and another activist climbed aboard an oil rig floating off of the coast of Greenland while the crew attempted to repel them with water cannons. Kumi was calling on the Scottish oil company, Cairn, to stop drilling for oil and ensure that Cairn had a response plan for oil spills.

Howard Clark, a radical pacifist and full-time nonviolent activist and researcher who chaired War Resisters International (WRI). His work and that of his WRI colleagues supported activists around the world to take nonviolent action to advance just and sustainable peace. He passed away in December 2013, and his partner and children will be present to accept his award.

Jacques Sémelin, a professor of Political Science at Sciences-Po Paris (Center for International Research and Studies) and Senior Researcher at the National Center for Scientific Research, who has produced many seminal publications on the use of civil resistance against dictatorships and the political roots of mass violence. He is the world's foremost scholar on understanding how civilian-based nonviolent action can be used to resist perpetrators of extreme human rights abuse and atrocities.

"These awardees show how ordinary people can fight oppression by organizing themselves and nonviolently mobilizing to win their rights," said Hardy Merriman, Vice President of the International Center on Nonviolent Conflict, which organizes the Lawson Awards. "Each of them has taught others, put pressure on power-holders, and revealed that civil resistance is a potent force that will continue to shape humanity's future."

The James Lawson Awards will begin at 1:30 p.m. on The Tufts University campus. The event will be live-streamed online and James Lawson Award winners, Fletcher Summer Institute participants, and experts in the field of nonviolent civil resistance who are presenting at the Fletcher Summer Institute will be available for interviews afterwards.

The awards ceremony will be held at the 9th annual Fletcher Summer Institute for the Advanced Study of Nonviolent Conflict at Tufts University, in front of activists, scholars, and journalists participating in a week long institute on civil resistance. The International Center on Nonviolent Conflict (a Washington, DC-based educational foundation) partners with the Fletcher School of Law & Diplomacy at Tufts University to put on this event.

## មាតិការឿង

Issue 156 June 22th- July 04th, 2014

**Free**


១-អត្ថបទជ្រើសរើសនៃសារព័ត៌មាន........ ............០៤
២-រី ម៉ាត មកដល់ឡូវែល..............................០៦
៣-លទ្ធផលប្រកួតនៃយុទ្ធនាឃាសានារកសន្លឹក........០៧
៤-ត្រឡប់មក ម៉ាយាមី នៃរដ្ឋ ផ្លរីដា ...................០៨
៥-ប្រាសាទអង្គរវត្ត និងប្រាសាទបាយ័ន................១៩
៦-បុណ្យខួបទី ៦៥ នៃថ្ងៃបាត់បង់ទឹកដីកម្ពុជាក្រោម.២០
៧-គុណប្រយោជន៍នៃផ្លែឈើក្នុងការ.......................២៥
៨-ទេសចរណ៍បន្ទាយ សត្វស្លាបទឹកនៅតំបន់.........៣២


New Office: Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852

## តមកទំព័រទី ០១ អ្នកស្រី យោម បុប្ផា ទទួលពានរង្វាន់...

ប្រចាំឆ្នាំ៤រូប ដែលបានបំពេញការងារ ប្រកបដោយគ្រោះថ្នាក់ ដោយប្រើមធ្យោបាយ




ជាក ឌុយវ៉ល អ្នកនិពន្ធសៀវភៅការតស៊ូអហឹង្សា (A Force More Powerful)




អហឹង្សាបានលទ្ធផលច្រើនតែមិនទាន់បញ្ឈប់ការតស៊ូនោះនៅឡើយទេ។

ក្នុងឱកាសដែលពិធីជូនក្ខត្តប្បក្យនេះកំពុងប្រព្រឹត្តទៅលោក ចាក ឌុយវ៉ល Jack Duval ជាប្រធាននៃអង្គការ ណុន វ៉ាយឡិនខនហ្វ្លិក បានឡើងថ្លែងបង្ហាញពីអ្នកដែលឱ្យឈ្មោះដល់ពានរង្វាន់គឺ បណ្ឌិត ជេម ឡសុន ដែលជាអ្នក

**តទៅទំព័រទី ០៥**




# ពត៌មានសម្រាប់រដូវក្តៅ
## Good News For Summer

Merrimack Valley Food Bank, Inc.
Help US... Help OTHERS

# The Merrimack Valley Food Bank
## Summer Food Service Program
## កម្មវិធីចែកម្ហូបអាហាររដូវក្តៅ នៃមជ្ឈមណ្ឌលផ្តល់ម្ហូបអាហារមែរីម៉ាក់

The Merrimack Valley Food Bank will continue its Summer Lunch and Community Market Programs in Lowell in the summer months. The Food Bank partners with organizations throughout Lowell that provide activities to children up to age 18, through support from the USDA Summer Food Service Program at the following locations from Monday through Friday unless otherwise noted:

មជ្ឈមណ្ឌលផ្តល់ម្ហូបអាហារមែរីម៉ាក់នឹងបន្តកម្មវិធីចែកអាហារនារដូវក្តៅ តាមរយៈការផ្តល់អាហារថ្ងៃត្រង់ និងមានជាផ្សារអាហារសហគមន៍នាខែដែលស្ថិតក្នុងរដូវក្តៅនេះ។ មជ្ឈមណ្ឌលផ្តល់ម្ហូបអាហារមែរីម៉ាក់សហការជាមួយអង្គការនានាក្នុងសហគមន៍ឡូវែលបង្កើតឱ្យមានជាសកម្មភាពនានាដល់កុមារ និងយុវជនត្រឹមអាយុ១៨ឆ្នាំ ឱ្យទទួលបាននូវកម្មវិធីអាហារល្អៗ ស្តង់ដារ យូ អេស ឌី អេ ហើយប្រព្រឹត្តទៅនៅទីតាំងផ្សេងៗពីគ្នាដោយមានជាកាលវិភាគ និងអាស័យដ្ឋានដូចខាងក្រោម:

| | | |
|---|---|---|
| YWCA | 41Rock Street | 12:00 – 12:30 |
| McPherson Park, | 185 Hildreth Street | 11:15 11:45 |
| Olga Nieves Park, | 123 Adams Street | 12:15 12:45(M-Th) |
| George W. Flanagan (LHA) | 580 Chelmsford Street | 12:00 – 12:45 |
| Christ Jubilee Ministry | 101 Smith Street | 12:00 12:45 |
| Caleb Group | 77 Chestnut Street | 12:00 12:45 |
| Mercier Center (LHA) | 22 Salem Street | 11:45 12:30 |
| North Canal Summer Program | 517 Moody Street | 12:00 – 12:45 (M-W-F) |
| LCHC Teen Block | 161 Jackson Street | 12:00 – 1:00 (M-Th) |

For more information call 978-454-7272 ឬ សូមអញ្ជើញទៅដោយផ្ទាល់ការិយាល័យ
735 Broadway Street Lowell, MA 01854







# អត្ថបទជ្រើសរើសនៃសារព័ត៌មានខ្មែរប៉ុស្តសហរដ្ឋអាមេរិក

## សិស្សឆ្នើម ឆ្នាំ ២០១៤ នាង ម៉ារីនដា ខាស្សមែន

**អត្ថបទដោយ : ម៉ូនីផល ប៊ីង**

**ប្រែសម្រួលសង្ខេបដោយ : សុខា**

**ក្រុងឡូវែល:** និស្សិតដែលបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យសហគមន៍មីដដលស៊ិក ឆ្នាំ ២០១៤ គឺនាងម៉ារីនដា ខាស្សមែន ត្រូវបានជ្រើសរើសជាមនុស្សម្នាក់ក្នុងចំណោម"មនុស្សដែលលេចធ្លោទាំង២៩នាក់" ដោយនាយកដ្ឋានថ្នាក់ឧត្តមសិក្សានៃរដ្ឋម៉ាសាឈូសេតក្នុងកម្មវិធីប្រចាំឆ្នាំ ហើយមនុស្សលេចធ្លោទាំង២៩នាក់នោះ តំណាងឱ្យមហាវិទ្យាល័យរដ្ឋទាំង២៩នៃការិយាល័យរដ្ឋម៉ាសាឈូសេត។ នៅអាយុ១៦ឆ្នាំ នាងម៉ារីនដា ខាស្សមែន ចុះឈ្មោះសិក្សាត្រួតគ្នាខណៈដែលនាងស្វ័យសិក្សានៅផ្ទះ ហើយនាងទទួលបានកម្រិតពិន្ទុខ្ពស់បំផុត គឺ៤កន្ទក់សញ្ញាសូន្យ។

នាងម៉ារីនដា ខាស្សមែន មានថ្វីដៃឆ្នើមក្នុងការសរសេរ ហើយនាងទទួលបានរង្វាន់មេដៃប្រាក់តាមរយៈការសរសេរអត្ថបទមួយនិយាយអំពីកង្វះភាពល្អប្រសើរក្នុងការបកស្រាយតម្លៃជនជាតិអាស៊ី ដែលមានឱកាសតិចតួចបំផុត សម្តែងភាពយន្តក្នុងវិស័យភាពយន្ត និងប្រព័ន្ធផ្សព្វផ្សាយនៃសហរដ្ឋអាមេរិក ដែលមានខ្លឹមសារជាភាសាអង់គ្លេសសរសេរដោយនាងផ្ទាល់ដាក់ចំណងជើងថា The Asian Misrepresentation:

**How the Portrayal of Asians in the Media Harms America .**
KhmerPost USA Selected Essay and Distinguished Student 2014: Miranda Cashman

**By Moniphal Bing**

LOWELL- A Middlesex Community College graduate of 2014, Miranda Cashman was named in "29 Who Shine" by the Massachusetts Department of Higher Education in its annual program recognizing outstanding students representing from each 29 public campuses at the Massachusetts State House. Cashman was enrolled at Middlesex as a home-schooled Dual Enrollment at age 16, graduated with a 4.0 GPA and an Associate Degree in Liberal Arts & Sciences, she was selected as commencement speaker of her graduation ceremony. The "29 Who Shine" recognized Cashman for her academic achievements, record of student leadership, and community service.

"Miranda Cashman typifies this group, having committed so much time and energy to helping her community and fellow students, while excelling academically. Miranda is the latest example of a Middlesex student who has proven to be a great asset to the Commonwealth," said Gov. Deval Patrick in his award ceremonial speech.

The 19-year-old has won several awards for creative writing including her essay a National Silver Medal from Scholastic, "The Asian Misrepresentation: How Stereotypes of Asians in the Media Harm America," was published in Scholastic's Art & Writing Award anthology, "The Best Teen Writing of 2013." With the author permission to reprint, Khmer-PostUSA invite you to read her essay as followed.


និស្សិតឆ្នើម Miranda Cashman រូបថតពីសកលវិទ្យាល័យ (Middlesex Community College)

### The Asian Misrepresentation: How the Portrayal of Asians in the Media Harms America

***By Miranda Cashman***

*There are a whole host of bankable stars... Can youname one bankable Asian-American star? No. There isn't... One can't name a singleAsian-American whose name you can take to the bank and get a project financed.*

**-George Takei**

This statement, spoken by George Takei about American film actors and actresses, brings to our attention the lack of Asians on film. George Takei, famous for his role as Hikaru Sulu on "Star Trek," has long been an advocate for Asian-American social justice. In an interview about primarily white actors playing originally Asian characters, Takei stated clearly the problem in Hollywood with Asian American actors – there aren't any "bankable" Asian stars. Asians are not accurately depicted in the media, and the lack of Asians in American media socially harms the country and negatively impacts how Americans relate to Asian-Americans.

Maybe it's because Asians have gotten the reputation for being successful in many fields, but the stereotypes made about Asian people still prevail within American society, especially when it comes to the Asians portrayed in movies and on television. America is a television-driven society, with Americans individually watching around 34 hours a week in 2010 (Stelter), and therefore it is no surprise that we are all subtly influenced by what we see on the screen. Many racial minorities have broken through the confining bonds of stereotypes on screen, and we see a fair share of African Americans and Latinos, but Asians still lag behind in American media. Essentially, this lack of Asians in the American media today keeps the stereotypes about Asians alive. These attitudes prevent the social integration of Asians into an un-biased country, and it limits the thinking of some non-Asians, resulting in socially stratifying the country.

Though famous Asian actors, directors, and screenwriters like Chow Yun Fat, Jackie Chan or Ang Lee may be household names, movies with such round and intricate Asian characters that are successful in America are few and far between. Even though in 2010 Asians make up 5.6 percent of the United States population, roughly 17 million people (United States Census), the media does not reflect the strong Asian influences within the country. Instead, the majority of television shows and movies in the United States unconsciously influence us to hold onto the stereotypical and sometimes offensive views of Asians. For example, Margaret Cho, a well-known Korean stand-up comic, for one year starred in a sitcom called "American Girl," which aired in 1994. The show centered on her struggles with her traditional Korean family and the desire to assimilate into American culture. The New York Times presented two different reactions to this show when aired. Elizabeth Wong talked about phone calls from people who say, "Thank God, at last we're being seen."But others, like John H. Lee, a critic for L.A. Weekly, seethed about "'the butchered Korean language and pseudo-traditions' of the mostly non-Korean cast" (qtd. Southgate). This presents a question: is it worse for Asians to be seen in the media, butwith incorrect or offensive stereotypes, or not to see Asians at all? "Both are unacceptable," should be the answer.

More questions arise: how does the lack of Asians in the media influence the views Americans hold about Asians? Or is the better question, how does American culture influence the media, resulting in the lack of Asians in the media? Both of these questions are absolutely valid, but my question is, which one came first? This leads us into a vicious cycle that somehow must be broken, because both influence the other, and both are hurting the perception of the Asian-American community.

The American public greatly influences what is portrayed on the screen. Hollywood, like all forms of media entertainment, is out to make money. When television shows do not receive high ratings or when movies are not box-office hits, studios are less likely to give funding to similar projects, even if a script featuring Asians is good for the world socially. When one of the first Asian-centered sitcoms, Margaret Cho's "American Girl," failed to keep its ratings high on American TV, the studio cancelled the show (qtd. Southgate). The character of Lane Kim from the seven-year run of "Gilmore Girls" was lucky to be on television for so long. Lane Kim, the best friend to one of the main characters, is presented as a rebellious and free-thinking girl who lives with a very traditional and strict mother. This tense mother-daughter relationship was described on a blog as "grossly exaggerated... making the Korean mother seem almost like a totalitarian Nazi" (qtd. Dynamitekenji). The actress who played Lane Kim, Keiko Agena, though, thinks that Lane was a complex part that broke all the traditional "good Korean girl" stereotypes. "Parts are very rare for Asian Americans, and parts as good as this are even rarer" (qtd. Heldenfels). Lane is a character who breaks the Asian girl stereotype, but when will characters like Lane lead their own show? How long will Asians stay stuck as the

**Continued to Page 17**

តមកពីទំព័រទី ០២

## អ្នកស្រី យោម បុប្ផា ទទួលពានរង្វាន់...

ឯកទេសខាងទស្សនៈនឹងយុទ្ធសាស្ត្រអហឹង្សា ធ្លាប់ ជាទីប្រឹក្សារបស់បណ្ឌិត ម៉ាទីន លូធ័រ ឃីង ជូញ៉័រ Dr.Martin Luther King Jr. មុនពេលលោក ឃីង ត្រូវគេសម្លាប់ទ្រឹស្តីលោក ឡសុន បានត្រូវគេប្រើប្រាស់បានជោគជ័យរហូតដល់បានសម្រេចជាស្ថាពរអ្នកទាំងពីរបានសម្តែងការកោតសរសើរពីសកម្មភាពដែលបណ្តាលនាង យោម បូផ្ផា ឱ្យបានក្លាយជាជ័យលាភីរង្វាន់ ជេម ឡសុន ថ្ងៃនេះ ។ លោក ចាក ឌុយវល បាននិយាយប្រាប់ខ្មែរផុសថា នាង យោម បូផ្ផា បានបំពេញលក្ខខណ្ឌសំខាន់ៗ ៣យ៉ាង គឺ**១**–នាងជាអ្នកដឹកនាំម្នាក់ចេញពីប្រភពសាមញ្ញ១រូប គឺគ្មាននរណារៀបចំត្រៀមឱ្យនាងឡើងជាថ្នាក់ដឹកនាំទេ **២**–នាងបានធ្វើការដឹកនាំចលនាបានលទ្ធផលច្រើនគួរកត់សំគាល់ **៣**–នាងនៅបន្តរសកម្មភាពជាសកម្មជនមិនទាន់ឈប់នៅឡើយ ។

បន្ទាប់មកលោក ជាក ឌុយវល ក៏អញ្ជើញនាង យោម បូផ្ផា មកសម្តែងការចាប់អារម្មណ៍នៅចំពោះសាធារណជនប្រមាណ១០០នាក់ ដែលសុទ្ធសឹងជាជ័យលាភីជំនាន់មុនសាស្ត្រាចារ្យអ្នកស្រាវជ្រាវ ឬជាសកម្មជនដូចគ្នា...

នាងនិយាយបន្ទាប់ពីថ្លែងអរគុណពីមជ្ឈមណ្ឌលដែលនាំនាងឱ្យមកទទួលពានរង្វាន់ពិភពលោកនេះ នាងបានបន្តថា រដ្ឋាភិបាលបានរំលោភសិទ្ធយើងដោយយកដីយកផ្ទះរបស់យើងទៅលក់ជាបន្តរបន្ទាប់យើងត្រូវតែបញ្ឈប់ពួកគេយើងមិនបានដឹងអំពីរបៀបដង្ហែក្បួនមិនដឹងពីចលនាអហឹង្សាមិនដឹងពីការឈឺចាប់នៃអ្នកធ្វើអហឹង្សាអ្វី ហើយក៏មិនដឹងពីមូលហេតុដែលនាំឱ្យអាជ្ញាធរវាយដំពួកខ្ញុំទេ ខ្ញុំតែងតែដឹងថា អាជ្ញាធរនឹងមកការពារពួកខ្ញុំ តែខ្ញុំដឹងថាខ្ញុំពុំបានធ្វើអ្វីខុសទេ តែអ្វីដែលសំខាន់ គឺខ្ញុំមានសេចក្តីរីករាយយ៉ាងខ្លាំងនៅពេលដឹងថា ការតស៊ូរបស់ខ្ញុំបានត្រូវចូលរួមដោយអ្នកនៅបឹងកក់ទាំងមូលមិនមែននៅតែម្នាក់ឯងទៀតទេ ហើយការតស៊ូនោះបានត្រូវទទួលស្គាល់នៅលើឆាកអន្តរជាតិ...អស់រយពេលច្រើនឆ្នាំនៃយុទ្ធនាការណ៍នេះបានលទ្ធផលជាច្រើន ប៉ុន្តែក៏ទទួលនូវការលះបង់នឹងឈឺចាប់ច្រើនណាស់ដែរ ហើយក៏នៅមិនទាន់បានសម្រេចគោលបំណងនៅឡើយ អ្នកតស៊ូដែលផ្តើមមាន៤ពាន់គ្រួសារ ឥឡូវនៅតែ៦រយគ្រួសារតែប៉ុណ្ណោះ អ្នកដែលនៅសល់ទាំងនោះមានជីវភាពយ៉ាប់យ៉ឺននឹងធ្ងន់ធ្ងរនឹងគ្រួសារមួយចំនួននៅមិនទាន់ទទួលបាននូវការវាស់វែងតាមច្បាច់នឹងស្របច្បាប់នៅឡើយ... នៅប្រទេសកម្ពុជាប្រព័ន្ធតុលាការគ្មានយុត្តិធម៌បញ្ហាដីធ្លីនៅតែរំលោភបំពានសម្បត្តិធម្មជាតិព្រៃឈើត្រូវបានបំផ្លាញនឹងពោរពេញទៅដោយអំពើពុករលួយព្រមទាំងការរំលោភសិទ្ធមនុស្សនៅតែធ្ងន់ធ្ងរនៅឡើយ...។ ច្រើនឆ្នាំបន្តមកទៀត សហគមន៏ឯទៀតៗក៏ទទួលផលប៉ះពាល់ដូចសហគមន៏ខ្ញុំដែរ ដោយអ្នកទាំងនោះបានបាត់បង់ផ្ទះសម្បែង ស្រែចំការ និងព្រៃឈើ អ្នកទាំងអស់បានក្រោកឈរប្រឆាំងនឹងអាជ្ញាធរ ហើយក៨ត្រូវបានចូលរួមក្នុងសកម្មភាពនេះជាញឹកញាប់ផងដែរ សហគមន៏ទាំងអស់រួមមានថ្មគោល បូរីកីឡា អតីតបឹងកក់ នឹងសហគមន៏ផ្សេងៗទៀត ក៏បានធ្វើការផ្លាស់ប្តូរយុទ្ធសាស្ត្រទៅវិញទៅមកធ្វើការសាមគ្គីជាក្រុមមួយការងារយើងបានកើនកម្លាំងនៅពេលមានការចូលរួមសកម្មភាពពីសហជីពកម្មករអ្នករត់ម៉ូតូអ្នកបើកប៉ូតូកង់៣ អ្នកធ្វើការនៅកន្លែងកំសាន្តនៅផ្ទះនឹង

តទៅទំព័រទី ០៩




# V-Mart Is Opening in Lowell
# វី ម៉ាត មកដល់ឡូវែល

**ដោយ : សុខា, រូបថតដោយ** Moniphal Bing

**ក្រុងឡូវែល:** ផ្សារលក់ចំណីអាហារ និងគ្រឿងឧបភោគបរិភោគក្នុងសហរដ្ឋអាមេរិក ក្នុងសហរដ្ឋអាមេរិកដែលប្រកួតប្រជែង និងនាំមុខមានលក្ខណៈពិសេសដោយឡែកពីគ្នា។ លក្ខណៈពិសេសទាំងនោះ ក៏ជាមូលហេតុចម្បងក្នុងការទាក់ទាញក្រុមអតិថិជនដោយឡែកៗពីគ្នាផងដែរ។ ផ្សារខ្លះល្បីល្បាញ និងពេញនិយមសម្រាប់សហគមន៍អាគាំង (អាមេរិក) ផ្សារខ្លះទៀត ពេញនិយមសម្រាប់សហគមន៍អេស្ប៉ាញ ឬអាហ្វ្រិក។ ចំណែកវីម៉ាត បានកសាងខ្លួនចូលក្នុងលំដាប់ផ្សារមួយប្រភេទដែលទាក់ទាញអតិថិជន និងពេញនិយមសម្រាប់សញ្ជាតិអាស៊ី។



ទាក់ទិននឹងប្រវត្តិវីម៉ាតសារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិកបានទទួលសម្ភាសន៍ជាមួយស្ថាបនិក ផ្សារវីម៉ាត ដោយផ្ទាល់នៅការិយាល័យកណ្ដាល។ ផ្អែកទៅលើបទសម្ភាសន៍ដែលទទួលបានពីស្ថាបនិកវីម៉ាតមានស្វាមីឈ្មោះ ស្កត់ ទ្រឹង (Scott Truong) និងភរិយាឈ្មោះ ក្លៅឌៀ តាំង (Klaudia Dang) បានថ្លែងថា វីម៉ាត ត្រូវបានបើកជាលើកដំបូងនៅឆ្នាំ២000 ពោលគឺទីតាំងទីមួយនៅ វ៉សស្ទឺ (Worcester) ជាទីដែលលោក និងក្រុមគ្រួសាររស់នៅ។ Worcester គឺជាតំបន់សំបូរមនុស្សរស់នៅ និងជាទីក្រុងធំទី២ បន្ទាប់ពីក្រុងបសស្តុន។ វីម៉ាត ជាពាក្យកាត់ចេញពីពាក្យពេញ វ៉ារ៉ាយអឺតធី ម៉ាត (Variety Mart) មានន័យថា ហាងសំបូរបែប ។ ដើមកំណើត វីម៉ាត កើតឡើងដោយលោក ស្កត់ (Scnott) ជាស្វាមីរបស់អ្នកស្រី ក្លោឌៀ ចងចាំនូវរឿងដែលភរិយា និងម្ដាយរបស់នាងមកដល់អាមេរិកដំបូងថ្ងៃទីមួយរស់នៅក្នុងរដ្ឋខនិកធិកខិត ហើយក្នុងពេលមួយដែលកំពុងហូបម្ហូបបានស្រម័យឃើញចានបាយ និងម្ហូបសម្លដែលខ្លួនតែងហូបកាលនៅស្រុកកំណើត។ មកដល់អាមេរិកឆ្នាំ១៩៧៩ ពេលដែលលោកស្កត់រំឭករឿងនោះឃើញថា ជំនាន់នោះ ជម្រើសអាហារអាស៊ីកម្រមានណាស់។

ផ្អែកលើប្រវត្តិខាងលើដែលបង្ហាញពីភាពសំខាន់នៃតួនាទីរបស់ម្ហូបអាហារប្រចាំជាតិសាសន៍មានសារៈសំខាន់ខ្លាំងក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូច្នេះហើយ ទើបលោក ស្កត់ និងភរិយា បានចាប់ផ្ដើមនូវមុខរបរនេះឡើង ហើយទទួលបានលទ្ធផលវិជ្ជមានដោយបម្រើការរស់នៅជនជាតិអាស៊ីនៅសហរដ្ឋអាមេរិកនេះយ៉ាងច្រើន។

ការបង្កើតហាងវីម៉ាតមិនត្រឹមតែអាចបម្រើតម្រូវការខាងផ្នែកគ្រឿងឧបភោគបរិភោគប៉ុណ្ណោះទេតែការកកើតឡើងនៃហាងនេះ បង្កើតឱកាសការងារដល់ប្រជាជនផងដែរ។

បន្ទាប់ពីបើកទីតាំងទីមួយនៅ Worcester វីម៉ាត មានទីតាំងទី២ នៅ Providence នៃរដ្ឋរ៉ូដអាយឡិនហើយ បច្ចុប្បន្ន វីម៉ាត កំពុងពង្រីកសាខារបស់ខ្លួនមួយកន្លែងទៀត កាន់តែកៀកចូលក្នុងសហគមន៍ខ្មែរ ពោលគឺការមកបើកទីតាំងទីបីនៅឡូវែល ផ្លូវ ១២៣ Church Street ហើយនឹងធ្វើការសម្ពោធបើកប្រើប្រាស់ហាងនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤។

តាមប្រសាសន៍របស់លោក ស្កត់ ហាង វីម៉ាត នៅឡូវែលផ្ដល់ដល់អតិជននូវជម្រើសម្ហូបអាហារប្រមាណ១២000មុខ។ លោក ស្កត់ បញ្ជាក់ថា លោកមិនដែលនឿយហត់នឹងមុខរបរនេះឡើយ




Mr. Ha Le, Ms. Klaudia Dang, Mr. Scott Truong ម្ចាស់ហាង វីមាត នៅឡូវលៃ

ព្រោះរាល់ពេលដែលធ្វើការក្នុងហាងលោកបាន ជួបមនុស្សជាច្រើន។

ការជួបមនុស្សជាចំណង់ចំណូលចិត្តរបស់លោក។ លោករីករាយ និងសប្បាយចិត្តនៅពេលដែលឃើញស្នាមញញឹមរបស់អតិថិជនពេលដែលពួកគេមកទិញ និងចេញពីហាងបន្ទាប់ពីទិញបាននូវអ្វីដែលគេត្រូវការ ហើយជារបស់ដែលពួកគេមានកាលនៅឯស្រុកកំណើត។

ចំនុចមួយទៀត លោកស្កត់បានបញ្ជាក់ពីលក្ខណៈពិសេសនៃហាងដែលលក់គ្រឿងឧបភោគបរិភោគដោយប្រៀបធៀបទៅនឹងភោជនីយដ្ឋាន ដូច្នេះថា មនុស្សរាល់គ្នាអាចមានជាតិព័ន្ធផ្សេងពីគ្នាចេញពីតំបន់អាស៊ី មានលាវ ថៃ វៀតណាម ចិន ខ្មែរ តែពួកគេអាចរកទិញគ្រឿងក្រៅពី វីម៉ាត បាន ហើយអាចយកទៅច្នៃជាម្ហូបតាមដែលគេរបៀបដែលគេធ្លាប់ធ្វើ និងទៅតាមទម្លាប់ទទួលទាន ៕






# លទ្ធផលប្រកួតនៃយុទ្ធនាការឃោសនារកសន្លឹកឆ្នោតនៃបេក្ខជនបក្សប្រជាធិបតេយ្យ

**ដោយ : រីឆាដ ហូវ**
**ប្រែសម្រួលសង្ខេបដោយ : សុខា**

យុទ្ធនាការឃោសនារកសន្លឹកឆ្នោតនៃបេក្ខជនពីបក្សប្រជាធិបតេយ្យឆ្នាំនេះ ត្រូវបានធ្វើឡើងនៅថ្ងៃសុក្រទី១៣ ខែមិថុនា និងថ្ងៃសៅរ៍ទី១៤។ គោលបំណងនៃការជ្រើសរើសនេះ គឺដើម្បីបង្កើតឱ្យមានជាទម្រង់មួយកំណត់ឱ្យច្បាស់លាស់នូវតួនាទី និងតំណែង ដើម្បីកំណត់យកឈ្មោះបេក្ខជនដែលទទួលបានការគាំទ្របឋម១៥% ពីក្រុមគណប្រតិភូមាននិន្នាការគាំទ្របក្សប្រជាធិបតេយ្យដែលទៅចូលរួមក្នុងយុទ្ធនាការនៃថ្ងៃនោះ។

បេក្ខជន៣នាក់ដែលមិនបានទទួលការគាំទ្រឱ្យដល់១៥% ពីគណប្រតិភូនាំដល់ពួកគេនូវការបញ្ឈប់យុទ្ធនាការឃោសនាភ្លាមៗតែម្តងក្នុងនោះមាន ជូលីយៀត ខេយហែម និង ចូ អាវែលឡុន ដែលប្រកួតសម្រាប់តំណែងអភិបាលរដ្ឋ និងបេក្ខជនទីបី គឺ ចេមស៍ អារេណាដឺរ៉ូសា ដែលប្រកួតសម្រាប់តំណែងអភិបាលរដ្ឋរង។

សម្រាប់បេក្ខជនដែលមានសម្លេងគាំទ្រច្រើនជាង១៥% ហើយអាចបន្តឈ្មោះទៅប្រកួតប្រជែងក្នុងការបោះឆ្នោតបឋម នាពេលខាងមុខនោះ មានបេក្ខជន ស្ទីវ ហ្គ្រសមែន , ម៉ាសា ខូកលី និង ដុន ប៊ើរីក សម្រាប់តំណែងអភិបាលរដ្ឋ ។រីឯ ស្ទីវ ឃឺរីហ្គែន, ម៉ៃខ៏ ឡេក និង លីឡែន ឈឹង អាចមានឈ្មោះបន្តទៅប្រកួតប្រជែងសម្រាប់តំណែងអភិបាលរដ្ឋរង។ ចំណែកឯតំណែងអគ្គមេធាវី មានបេក្ខជន វ៉ារិន ថលមែន និង ម៉ូរ៉ា ហ៊ៀលី។ រីឯតំណែងហិរញ្ញិក មាន ដេបប៊ីហ្គោលប៊ើក, ថម ខុនរ៉យ និង ប៊ែរី ហ្វាញហ្គូល។

ឈ្មោះបេក្ខជនទាំងអស់នេះ នឹងលេចឡើងក្នុងសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតបឋម នាថ្ងៃទី៩ ខែកញ្ញាឆ្នាំ២០១៤។ គួរបញ្ជាក់ផងដែរថា ក្នុងចំណោមគណប្រតិភូ៤០០នាក់ ដែលចូលរួមក្នុងការរៀបចំខាងលើមាន៩០នាក់អញ្ជើញមកពីឡូវែល ៕


Richard Howe

# Democratic State Convention Results

**By Richard P. Howe Jr.**

The Democratic State Convention was held this year in Worcester on Friday June 13 and Saturday June 14. The purpose of the convention is to adopt a platform of positions on the issues and to nominate candidates for statewide office. All candidates running for office must first gather nomination signatures from registered votes to qualify to appear on the election ballot. Candidates for statewide office have the additional requirement of receiving the votes of at least 15% of the delegates to the state convention.

Three candidates failed to get 15% of the delegate votes so their campaigns ended immediately. The unsuccessful candidates were Juliette Kayyem and Joe Avellone, both running for governor, and James Arena-DeRosa who was running for lieutenant governor. Candidates who did receive more than 15% of the delegate vote were (for governor) Steve Grossman, Martha Coakley and Don Berwick; (for lieutenant governor) Steve Kerrigan, Mike Lake and Leland Cheung; (for attorney general) Warren Tolman and Maura Healey; (for treasurer) Deb Goldberg, Tom Conroy and Barry Finegold. All of these candidates will appear on the ballot in the Democratic primary election which will be held on Tuesday, September 9, 2014.





Delegates to the convention from Lowell were selected at a caucus held at Lowell High School back in February. Anyone who is registered as a Democratic voter is eligible to be elected to be a delegate. Of the 4000 delegates who attended this year's convention, approximately 90 were from Lowell.


បង្កើតឲ្យមានភាពជោគជ័យ

ធនាគារអ៊ីនធ័រប្រៃអាចជួយលោក-អ្នកនូវរាល់សេចក្តីត្រូវការផ្នែកហិរញ្ញវត្ថុទាំងអស់របស់លោក-អ្នក រួមបញ្ចូលទាំងធនាគារផ្ទាល់ខ្លួន, ធនាគារជំនួញ, និក្ខេប, ការចាត់ចែងផ្នែកវិនិយោគ, និងគ្រោងការចូលនិវត្តន៍។

» ភាពចំរុះ » ស្ថិរភាព » ការចំរើនល្អលាស់
» ការបានជោគជ័យ » គ្រួសារ » ជំនួញ

យើងនិយាយភាសាខ្មែរ


**Bopha Malone**
*Branch Relationship Manager, AVP*
430 Gorham Street, Lowell, MA
Bopha.Malone@ebtc.com
978-656-5561


**Sue Suon**
*Branch Service Specialist*
222 Merrimack Street, Lowell, MA
Sue.Suon@ebtc.com
978-656-5679

សូមនិយាយជាមួយបុប្ផា ម៉ាឡូន ឬស៊ូ សួន ថ្ងៃនេះ
ហើយឲ្យគេជួយលោក-អ្នកបង្កើតឲ្យមានភាពជោគជ័យ!

Enterprise Bank
CREATE SUCCESS
EnterpriseBanking.com

*ការចាត់ចែងផ្នែកវិនិយោគមិនមែនជាផលិតផលប្រាក់បញ្ញើ, មិនត្រូវបានរ៉ាប់រងដោយ FDIC, មិនមានការធានាដោយធនាគារ អ៊ីនធ័រប្រៃ, មិនត្រូវបានធានាដោយស្ថាប័នរដ្ឋណាមួយ ហើយមិនអាចត្រូវបាត់បង់គុណតម្លៃ។

Member FDIC

# ត្រឡប់មក ម៉ាយាមី នៃរដ្ឋ ផ្លរីដា ធម្មតាវិញ



**តពីលេខមុន (ភាគ៣)**






**ដោយៈ ពិន សំខុន**

ក្នុងដំណើរទៅ ម៉ាយ៉ាមី នៃរដ្ឋ ផ្លរីដា នេះ យើងតែងតែមានអារម្មណ៍ថា រកឱ្យជួបនូវអ្វីដែលទំនើប អ្វីដែលចម្លែក អ្វីដែលអច្ឆរិយៈ ដែលនឹងណែនាំដៃនឹងមនោសញ្ចេតនាយើងសរសេរអំពីភាពអស្ចារ្យនៃស្នាដៃមនុស្សនាំគ្នាគិតកសាងសំណង់ចុងក្រោយបំផុតសំណង់ថ្មមនឹងលួងលោមបំពេរទេសចរណ៍មិនឱ្យឃ្លើសចិត្តបន្តិចណាទាល់តែសោះមិនដែលនឹកទេថា នៅកន្លែងដ៏ដែលនេះ យើងនឹងបានត្រឡប់ទៅភ្លក់រស់ជាតិនៃស្រែចំការខ្មែរ នៃដំណាំដាំដុះ ជាពូជខ្មោ ល្មុត ចេក ទឹកដោះកូលែន ត្របែក ល្ហុង...។ល។ ដែលជាក្លិនដ៏ប្រហើរនៃជនបទខ្មែរយ៉ាងនេះទេ ។ គិតមែនទែនទៅនេះក៏ជាភាពអច្ឆរិយៈមួយទៅទៀតដែលគ្រួសារអ្នកស្រីឈុន ភីរុង បានបង្កើតជូនក្រុមគ្រួសារអាស៊ី ជាពិសេសខ្មែរយើងដោយមិនដឹងខ្លួនឱ្យមានអារម្មណ៍អណ្តែតអណ្តូងទៅរកអាស៊ីអាគ្នេយ៍វិញ យ៉ាងហោចណាស់ក៏ក្នុងមួយថ្ងៃនៃទស្សនកិច្ចមួយថ្ងៃនៅចំការខ្មែរយើងនោះដែរ ។ ដោយសារតែអារម្មណ៍នេះ ហើយអ្នកស្រី ភីរុង និយាយថា ផលិត-ផលរបស់គាត់មិនចាំបាច់អំពាវនាវទៅលក់ទីផ្សារណាមួយទេ ពាណិជ្ជករគេមកទិញដល់កន្លែងយើងគ្រាន់តែរៀបចំហៅមនុស្សជំនួយឱ្យមកបេះផ្លែថ្មីៗរៀបចំដាក់ប្រអប់ឱ្យគេទៅជាការស្រេចអ្នកស្រីមិនបានដឹងថា ផលិតផលអ្នកស្រីបញ្ជូនទៅដល់ផ្នែកណាខ្លះនៃស.រ.អា. នោះទេ។

នៅសល់ពេលបន្តិចនាល្ងាចនោះ អ្នកស្រី ភីរុង បាននាំយើងត្រឡប់មកទស្សនាតាមរថយន្តក្រុងម៉ាយាមីរដ្ឋផ្លរីដានៃឋានសួគ៌លោកិយវិញម្តង។ នៅជ្រោយខាងត្បូងនឹងខាងកើតបង្អស់នៃសហរដ្ឋនេះ គឺល្បីល្បាញដោយសារក្រុងម៉ាយាមីដ៏ទំនើបបង្អស់អាចនាំទេសចរណ៍រាប់លាននាក់មកទស្សនារៀងរាល់ឆ្នាំ គឺជាការរកស៊ីមួយដ៏ចំឡែកដោយការលក់ក្តីស្រមៃបានក្នុងតម្លៃខ្ពស់ ។ គេមកមើលមិនត្រឹមតែទីក្រុងប្រកបដោយសួនច្បារផ្កាចំរុះពណ៌ទេសភាពនៃឆ្នេរសមុទ្រខៀវស្រងាត់តែប៉ុណ្ណោះទេ គេទស្សនាផ្ទះធ្វើពីកញ្ចក់ខ្ពស់ក៏មានទាបក៏មានរូបរាងរបៀបណាក៏មានដែលលំអរដោយពន្លឺថ្ងៃរេរាំចែងចាំងប្តូររូបរៀងរាល់វិនាទីខុសគ្នាពីពេលមានថ្ងៃទៅពេលមានភ្លៀងពីពេលត្រជាក់ទៅពេលក្តៅខុសគ្នាជាច្បាប់នគរដាក់កំហិតគិតដូចសេះដែលគេពាប់វែនតាឱ្យមើលតែទៅមុខទស្សនៈនេះនៅតែលងជនជាតិអាស៊ីជនាន់ចាស់យើងគ្រប់ជំហ៊ានដែលដើរឆ្លងបន្ទាត់ហាមឃាត់ពណ៌ក្រហមនោះម្តងៗក៏ប៉ុន្តែវាជាការល្អដែរ ដែលនៅពេលឆ្លងបន្ទាត់នាពេលនេះ គ្មាននរណាបន្ទោស ឬបង្អាប់បន្ទាត់នោះក៏រលប់ជាស្វ័យប្រវត្តម្តងបន្តិចៗដោយឯកឯងទៅវិញ។








ល្ងាចនេះ យើងមាននៅសល់ពេលខ្លះសម្រាប់ចូលទៅទស្សនាចំណតនាវាកំសាន្តនៅទិនោះ មានហាងលក់វត្ថុអនុស្សាវរីយតូចធំមានមនុស្សដើរលំហែរកាយនាវាកំសាន្តប្រណិតៗចតមានសណ្តាប់ធ្នាប់បង្ហាញខ្លួនគួរឱ្យចង់ជិះលេងមានក្រុមតន្ត្រីយុវវ័យសម្តែងសិល្បៈដូរ្យតន្ត្រីចម្រៀងនឹងរាំជូនទស្សនិកជនដែលមកទាំងមនុស្សរូបអាក្រក់ដោយធ្វើកាងាររកលុយយ៉ាងខិតខំទៅជាមនុស្សរូបល្អៗប្រឹងចាយលុយយ៉ាងសង្ហារ។ យើងមកពីស្រុកនាយតែងបន្ទោសថា ជាគុណវិបត្តសម្បូរបែបជាឋាននរកលោកិយ អបអរយ៉ាងច្រើនគួរសម ជាពិសេសក្រោមអាកាសធាតុក្តៅហែងយ៉ាងនេះ យើងពិបាកនឹងទ្រាំមិនទិញអាយស្គ្រីម ឬការ៉េមគី នឹងសូដាមួយកំប៉ុង

**តទៅទំព័រទី ១៨**

តមកពីទំព័រទី ០៥

## អ្នកស្រី យោម បុប្ផា ទទួលពានរង្វាន់...

អ្នកតស៊ូមតិផ្សេងមួយចំនួនទៀត អ្នកទាំងនោះមានសារៈសំខាន់ណាស់ដែលបានចេញមុខតស៊ូមតិមកបង្ហាញពីទុក្ខលំបាកកាលពីឆ្នាំមុនជាពិសេសមកបង្ហាញករតស៊ូកាន់តែច្រើនឡើង ចំនួនសម្រាប់ប្រើកាំភ្លើងគ្រាប់បែកផ្សែងបង្ហូរទឹកភ្នែកទទួលការគម្រាមកំហែងចាប់ខ្លួនជាបន្តបន្ទាប់... កាលពីឆ្នាំមុនមានប្រជាពលរដ្ឋរាប់ពាន់នាក់បានចូលរួមចង់ឱ្យមានការផ្លាស់ប្តូរនយោបាយ នេះហើជាបុព្វហេតុដែលធ្វើឱ្យប្រជាពលរដ្ឋភិតភ័យចំពោះការតស៊ូរបស់ខ្លួនមកដល់ពេលនេះទៀត យើងនាំការតស៊ូមកដល់បសស្តុនឱ្យទាំងអស់គ្នាចូលរួមក្នុងពិភពលោកដែលនឹងនាំឱ្យមានទំនុកចិត្តកាន់តែខ្លាំងឡើង ខ្ញុំក៏ដឹងដែរថា ការតស៊ូរបស់ខ្ញុំត្រូវប្រើរយពេលច្រើនឆ្នាំតទៅទៀត គឺ ជេម ឡូសុន ដែលបានជម្រុញឱ្យស.រ.អា មានប្រធានាធិបតីសម្បុរស្បែកខ្មៅជាលើកដំបូងបង្អស់ បាននាងបានឧទ្ទិសស្នាដៃចំពោះមិត្តរួមប្រយុទ្ធទាំងអស់ដែលយើងសុំឱ្យរាប់ឈ្មោះ៥នាក់ដំបូងថា អ្នកដែលស្លាប់រស់ជាមួយគ្នាមានអ្នកស្រី ទេព វណ្ណី ក៏ជាអ្នកធ្លាប់ទទួលពានរង្វាន់ដែរ លោកយាយ



យោម បុប្ផា ជាប់គុក៤៤៤ថ្ងៃ



លោក James Lawson សកម្មជនតស៊ូក្នុង
Civil Rights Movement in American South

ដោយអហិង្សារ ហើយយុទ្ធនាការទាមទារសិទ្ធិរបស់យើងធ្វើការទាមទារខ្លាំងឡើងៗ អាជ្ញាធរក៏រឹតតែវាយបង្ក្រាបខ្លាំងឡើងៗដែរ ដោយការប្រើយុទ្ធសាស្ត្រផ្សេងៗទៅលើក្រុមតវ៉ាដូចពួកខ្ញុំដែរ សហគមន៍ផ្សេងៗបានក្រោកឈរជាមួយសហគមន៍បឹងកក់ ហើយក៏ក្លាយជាគោលដៅអាជ្ញាធរមួយនឹងអ្នកដឹកនាំ ហើយខ្ញុំមានមោទនភាពនឹងរីករាយចំពោះអ្នកទាំងនោះខ្លាំងណាស់ ពីព្រោះអ្នកទាំងនោះបានទាមទារដោយប្រើយុទ្ធនាការណ៍អហឹង្សាជាមួយគ្នានេះដែរ រដ្ឋាភិបាលបានប្រើគ្រាប់កាំភ្លើងពិតវាយប្រហារលើក្រុមបាតុករបណ្តាលឱ្យស្លាប់របួសនឹងចាប់ខ្លួនដាក់ពន្ធនាគារ តែយើងនឹងមិនបោះបង់ការតស៊ូរបស់យើងនោះទេ ខ្ញុំនឹងយកមេរៀនដែលរៀនសូត្រទីនេះទៅផ្សព្វផ្សាយជូនបងប្អូនបឹងកក់នឹងសម្រាប់ប្រជា-ពលរដ្ឋទាំងអស់...។

នាង យោម បូផ្ផា សម្តែងការអបអរបន្ទាប់ពីបានទទួលពានរង្វាន់ពីដៃមនុស្សដ៏អស្ចារ្យម្នាក់ ង៉ែត ឃុន អ្នកស្រី គុង ចន្ថា អ្នកស្រី បូ ឆវី ហើយអ ្កដែលនៅជិតបំផុត ដែលបានឱ្យកម្លាំងចិត្តដល់ខ្ញុំ គឺម្តាយរបស់ខ្ញុំឈ្មោះ សាបូ សុខ ជាពិសេសកូនប្រុសរបស់ខ្ញុំដែលបានធ្វើអ្វីគ្រប់យ៉ាង ដើម្បីជួយដោះខ្ញុំចេញពីគុកវិញ ៕

MARCOTTE LAW FIRM
ក្រុមហ៊ុនមេធាវី Marcotte
45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីអន្តរាយដល់បុគ្គល
- ច្បាប់ធានារ៉ាប់រង
- សំណងបុគ្គល
- ការរំលោភបទព្រហ្មទណ្ឌ
- ពិការភាពដោយសន្តិសុខសង្គម
- គ្រោះថ្នាក់ចរាចរណ៍
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- គ្រោះថ្នាក់នៅការដ្ឋាន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បំណុលអចលទ្រព្យ
- បណ្តឹងវិវាទទូទៅ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍

មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ
(978) 458-1229
www.marcottelawfirm.com

Seamstress / Sewing Machine Operator (in Woburn)

We are a decorative throw pillow manufacturer seeking a skilled sewing machine operator.

Qualifications:
- Must be available to work **Monday - Thursday 7 AM - 4 PM and Fridays 7 AM - 1 PM.**
- Flexible to work overtime as needed.
- Skilled in the operation of a commercial sewing machine (JUKI or Singer).
- Able to speak English, Spanish and/or Cambodian.
- Attention to detail and take great pride in their work.
- Get to and from work on time.
- Have a helpful and positive attitude.

We offer a starting compensation of $10 an hour and the opportunity for overtime and some take-home piece goods. We are a fun and friendly group of about 8 seamstresses and 2 cutters. We are a fast growing company with a secure employment opportunity for the right person. Only serious candidates apply. Must have two forms of ID.
**Call 781-281-7044 and ask for Sonita.**

ការិយាល័យ មេធាវី
ថំមាស ស្តាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852
- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
Only Licensed in Massachusets




| | Washington SAVINGS BANK We give you more | Big Banks |
|---|---|---|
| ATMs | 60,000 Nationwide free ATMs | Much Less! |
| Free Checking | YES! | Are you kidding? |
| Online Banking | Everything the 'Big Banks' have: Online banking, Bill payment, mobile banking, mobile deposit | We'll give them this one, they have it too |
| Free Designer Debit Card | YES, OVER 80 DESIGNS! | They are not that creative |
| Unlimited Debit Card Cash Rewards | YES! Anytime, Anywhere | No |
| Customer Service | Friendly local people who really want to help solve problems | One word "Voicemail" |
| Lending | Local decisions, by local people who sincerely want to work with you. Your place or ours, day, evening or weekend | See above |
| Bank Headquarters | Lowell, MA - your money and loan payments stay in your community | Canada, Spain Scotland, North Carolina |

"I switched from a large bank several years ago and have never regretted it. This is a small town bank with large bank benefits and far superior service than you get at the larger banks." - Joe S."

"I recently switched from Bank of America and love it here. Should have done it sooner!" – Kelly P.



**PLUS RECEIVE A FREE**

**kindle fire®**

- Monthly Direct Deposit of at least $1,000
- At least one monthly automatic payment
- An active debit card

Washington SAVINGS BANK
We give you more

washingtonsavings.com

978-458-7999

Member FDIC/ Member DIF / Equal Housing Lender

See reverse side for terms and conditions

KhmerPost USA

# តួនាទី : ជំនួយការនិពន្ធនាយក

## សារព័ត៌មានខ្មែរផុស្តស.រ.អា ឡូវែល រដ្ឋម៉ាសាឈូសេត

**បេក្ខជនត្រូវ :**

- មានបរិញ្ញាបត្រពីប្រទេសខ្មែរ
- ចេះសរសេរ និងអានភាសាខ្មែរបានជ្រៅជ្រះ
- ចេះសរសេរព័ត៌មាន និងកែអត្ថបទ
- ចេះស្រាវជ្រាវ និងសង្ខេបព័ត៌មានពីប្រព័ន្ធអ៊ីនធឺណិត និងប្រភពផ្សេងទៀត
- ជាមនុស្សដែលចេះសម្របខ្លួនក្នុងការងារ និងមជ្ឈដ្ឋានខាងក្រៅ
- ចេះគោរពកាលកំណត់ ចំពោះភារកិច្ចដែលទទួលធ្វើ
- ចេះវាយអត្ថបទជាភាសាខ្មែរ
- ចេះភាសាអង់គ្លេស
- ចេះថតរូបរឹតតែប្រសើរ
- មានបទពិសោធន៍ធ្វើការផ្នែកសង្គម ពីបីទៅប្រាំឆ្នាំ
- ពូកែផ្នែកទំនាក់ទំនង តាមអ៊ីម៉ែល ទូរស័ព្ទ និងផ្ទាល់មាត់
- ចេះធ្វើការជាក្រុម
- មានស្មារតីចង់ចេះ និងដឹង ដើម្បីភាពរីកចម្រើននៃការងារ
- មានពេលវេលាបត់បែនសម្រាប់ការងារ ក្នុងពេលចាំបាច់ ( ពេលល្ងាច និងចុងសប្តាហ៍)
- ទាក់ទង និងណាត់ភ្ញៀវសម្រាប់សម្ភាសន៍ និងសរសេររបាយការណ៍( សម្រាប់និពន្ធនាយក)
- គ្រប់គ្រងខាងផ្នែកអត្ថបទ និងតម្លើងកាសែតពីមួយលេខទៅមួយលេខ
- សហការ និងទាក់ទងជាមួយអ្នកឪសាញកាសែត
- គោរពក្រមសីលធម៌សារព័ត៌មាន
- អាចធ្វើការងារពេញម៉ោង
- ប្រាក់ខែផ្អែកទៅលើបទពិសោធន៍ និងសមត្ថភាព



លោក សំខុន ពិន ដែលជា ស្ថាបនិកកាសែតខ្មែរស.រ.អា

ក្រមសីលធម៌ការងារជាចំណុចសំខាន់ក្នុងការធ្វើការងារ ហើយបេក្ខជនអាចទទួលការបណ្តុះបណ្តាលបាន បើមានចម្ងល់ ។

តួនាទីនេះ នឹងជាជំនួយការផ្ទាល់ទៅនឹងនិពន្ធនាយក សំខុន ពិន ដែលមានបទពិសោធន៍ក្នុងវិស័យសារព័ត៌មានជាង២០ឆ្នាំ និងជាអតីតប្រធានសមាគមអ្នកកាសែតកម្ពុជា ( ១៩៩៣-១៩៩៧) ជាអតីតនាយកវិទ្យុអាស៊ីសេរីផ្នែកភាសាខ្មែរ ( ១៩៩៨-២០០៣) ព្រមទាំងជាស្ថាបនិកសារព័ត៌មានខ្មែរផុស្តសហរដ្ឋអាមេរិក ( ២០០៧-បច្ចុប្បន្ន) ។

បេក្ខជនចាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូបសង្ខេប (CV) និង Cover Letter មកកាន់អាស័យដ្ឋាន
45 Merrimack Street. Suite 218A
Lowell, MA 01852
ឬតាមអ៊ីម៉ែល khmerpostusa@gmail.com


# Rady Mom: State Rep's Kick Off Campaign on Saturday 6/21/14



Campaign's Director Sem Meas & Rady Mom's family

Rady MOM
STATE REPRESENTATIVE






ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ សៅរ៍ ទី២១ ខែមិថុនា ឆ្នាំ២០១៤

# ពលករខ្មែរចំណាកស្រុកវិលត្រឡប់មកដល់ស្រុកកំណើតវិញ មានចំនួនប្រហែល១៨០.០០០នាក់

**ដោយ : សាំង សុផន្ទរិទ្ធ** | **June 19, 2014**

ក្រុមមន្ត្រីនៅតាមព្រំដែនថៃបាននិយាយកាលពីម្សិលមិញថា ឥឡូវនេះពលករខ្មែរចំណាកស្រុកប្រហែល១៨០.០០០នាក់បានវិលត្រឡប់មកដល់ស្រុកកំណើតរបស់ខ្លួនវិញហើយ ចាប់តាំងពីការចាប់ផ្តើមសម្រុកចាកចេញរបស់ពលករចំណាកស្រុកក្នុងចំនួនដ៏ច្រើនពីប្រទេសថៃកាលពីសប្តាហ៍មុន ប៉ុន្តែគេបានកត់សម្គាល់ថា ការឆ្លងព្រំដែនបានថយចុះច្រើន។

អ្នកដែលវិលត្រឡប់មកវិញភាគច្រើន និយាយថា ពួកគេបានរត់ចោលការងារក្នុងប្រទេសថៃ ដោយមានពាក្យចចាមអារ៉ាមថា ពួកគេគឺជាគោលដៅនៃការចាប់ខ្លួនពីសំណាក់ ទាហានថៃ ដែលបានចាប់ផ្តើមប្រមូលពលករចំណាកស្រុកខុសច្បាប់ បន្ទាប់ពីការផ្តួលរំលំរដ្ឋាភិបាលក្រុងបាងកក កាលពីខែមុន ហើយបានប្រកាសច្បាប់អាជ្ញាសឹក។

លោក គោស៊ុំ សារឿត អភិបាលខេត្តបន្ទាយមានជ័យបានមានប្រសាសន៍ថា "រហូតមកទល់ពេលនេះមានពលករចំណាកស្រុកជាង១៨០.០០០នាក់ត្រូវបាននិរទេសដោយរដ្ឋាភិបាលយោធាថៃឆ្លងកាត់ច្រកទ្វារអន្តរជាតិប៉ោយប៉ែត ចាប់តាំងពីថ្ងៃទី៦ ខែមិថុនាមក"។

ច្រកឆ្លងកាត់ជាច្រើនហាក់ដូចជាបានកើនឡើងកាលពីថ្ងៃអាទិត្យនៅពេលដែលពលរដ្ឋខ្មែរជាង៤០.០០០នាក់បានចាកចេញពីប្រទេសថៃតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត។

យោងតាមតួលេខដែលបានពីរដ្ឋាភិបាល អង្គការសិទ្ធិមនុស្ស និងសាក្សីបានឱ្យដឹងថា យ៉ាងហោចណាស់ពលរដ្ឋខ្មែរចំនួន១០នាក់បានស្លាប់ ក្នុងនោះភាគច្រើនគឺស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ ចាប់តាំងពីថ្ងៃអាទិត្យអំឡុងការប្រមូល និងការខិតខំប្រឹងប្រែងត្រឡប់មកស្រុកកំណើតវិញ។ លោក សែម មករា អនុប្រធានច្រកទ្វារអន្តរជាតិប៉ោយប៉ែត បានមានប្រសាសន៍ថា ឥឡូវនេះសាកសពចំនួនប្រាំពីរនាក់ត្រូវបានបញ្ជូនមកដល់កម្ពុជាហើយ។



យោងតាមអង្គការសិទ្ធិមនុស្សអាដហុកបានឱ្យដឹងថា ពួកគេបានរាប់បញ្ចូលសាកសពបុរសម្នាក់ និងស្ត្រីពីរនាក់ដែលបានស្លាប់ បន្ទាប់ពីរថយន្តទូរីសដែលពួកគេជួលជិះមកស្រុកកំណើតបានផ្ទុះកង់នៅក្នុងខេត្តច័ន្ទបុរី ហើយបានក្រឡាប់។

អ្នកស្រី មួន ភៀយ ដែលរងរបួសស្រាលក្នុងគ្រោះថ្នាក់ចរាចរណ៍បាននិយាយថា រថយន្តទូរីសបានមកដល់កន្លែងដែលទាហានថៃបិទផ្លូវ នៅពេលនោះទាហានម្នាក់បានបាញ់ឡើងលើដើម្បីឱ្យរថយន្តទូរីសនោះឈប់។ អ្នកស្រីបាននិយាយថា អ្នកបើកបររថយន្តជនជាតិថៃបានបត់រថយន្តត្រឡប់ក្រោយភ្លាម ហើយបើកយ៉ាងល្បឿនចេញពីកន្លែងបិទផ្លូវនោះ ស្រាប់រថយន្តបានផ្ទុះកង់ ហើយក្រឡាប់តែម្តង។

អ្នកស្រីបាននិយាយតាមទូរស័ព្ទកាលពីម្សិលមិញពីផ្ទះរបស់អ្នកស្រីនៅក្នុងខេត្តបន្ទាយមានជ័យថា " ខ្ញុំនិងប្រពន្ធអ្នកបើកបររថយន្តបានអង្វរឱ្យគាត់ឈប់ ប៉ុន្តែអ្នកបើកបរមិនព្រមឈប់ទេ ហើយបន្ទាប់មករថយន្តក្រឡាប់តែម្តង"។

អ្នកស្រីបាននិយាយថា បុរសម្នាក់បានស្លាប់

**តទៅទំព័រទី ១៣**

## Return of Workers From Thailand Reaches 180,000

**By Saing Soenthrith | June 19, 2014**

Officials along the Thai border said Wednesday that some 180,000 Cambodians have now returned home since the start of a mass exodus of migrant workers from Thailand last week, but noted that the pace of crossings has slowed substantially.

Most returnees are saying they fled their jobs in Thailand amid rampant rumors that they were being targeted for arrest by the Thai Army, which began rounding up illegal migrants after overthrowing the government in Bangkok last month and declaring martial law.

"Until now there have been more than 180,000 migrant workers deported by the Thai junta across the Poipet international checkpoint since it started on June 6," said Banteay Meanchey provincial governor Kousoum Saroeuth.

The crossings seemed to have peaked on Sunday, when more than 40,000 Cambodians left Thailand through the Poipet checkpoint.

According to a combination of government, rights group and witness accounts, at least 10 Cambodians have reportedly died-mostly in traffic accidents-since Sunday amid the roundups and efforts to return home.

Sem Makara, deputy chief of staff at the Poipet checkpoint, said seven of the bodies have now been repatriated.

According to rights group Adhoc, they include the bodies of one man and two women who died after the van they had hired to take them home blew a tire in Chonburi province and rolled over.

Muon Phiey, who was slightly injured in the accident, said the van was approaching a roadblock manned by Thai troops when one of the soldiers fired into the air to make the van stop. She said the Thai driver instead turned the van abruptly around and was speeding away from the roadblock when a tire blew out and the van rolled.

"Me and his [the driver's] wife pleaded with him to stop, but the driver didn't and then we turned over," she said Wednesday by telephone from her home in Banteay Meanchey province.

**Continued to page 21**

## Six Evicted Boeng Kak Families Strike Land Deal

**By Khuon Narim | June 19, 2014**

Six families that were evicted from the Boeng Kak lake community, including long-time activist Heng Mom, confirmed Wednesday that they had accepted a deal from Phnom Penh City Hall for plots of land and titles in the same neighborhood.

The families have agreed to plots of land measuring 4-by-18 meters in Boeng Kak's Village 22, reducing to 40 the number of families still without land. More than 100 families were omitted from Prime Minister Hun Sen's August 2011 plan to give land titles to the remaining families fighting eviction in the area.

Some 3,000 families in the area had by then been forced from their homes to accommodate a real-estate project by a ruling party senator.

"I agreed to the deal with City Hall because they swapped my land close to the main road when it used to be further away," Ms. Mom said.

Ms. Mom had long ago separated from a group of Boeng Kak protesters led by high-profile activist Tep Vanny, and in 2012 promised officials she would vote CPP in the July 2013 election in return for titles.

The majority of former Boeng Kak residents who have yet to receive titles have declined City Hall's compensation, saying the land on offer is not enough.

"We cannot accept the deal offered by City Hall because it is smaller than the land size we occupied before it was taken," said Khy Ret, who lived in the area's Village 1.

Another former Boeng Kak resident, Sen Touch, also declined the offer, claiming her original land measured 900 square meters. "[City Hall] said we lived on state land, but everywhere is state land. There will be no land for living if everything belongs to the state," she said.

Am Sam Ath, technical supervisor for rights group Licadho welcomed City Hall's efforts to settle the Boeng Kak dispute.

"However, it's not right City Hall said they were evicted for living on state land. If they knew this land belonged to the state then authorities shouldn't have allow them to live there," Mr. Ath said.

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ សៅរ៍ ទី២១ ខែមិថុនា ឆ្នាំ២០១៤

តមកពីទំព័រទី ១២ ពលរដ្ឋខ្មែរចំណាកស្រុកវិលត្រឡប់មក...

នៅកន្លែងកើតហេតុ ហើយស្ត្រីពីរនាក់បានស្លាប់ដោយសាររងរបួសបន្ទាប់ពីដឹកតាមរថយន្តសង្គ្រោះបន្ទាន់ទៅកាន់មន្ទីរពេទ្យក្នុងប្រទេសថៃ។ អ្នកស្រី ភឿយ បាននិយាយថា ប្ដីរបស់អ្នកស្រី និងអ្នកដំណើរមួយចំនួនទៀតដែលបានរងរបួសក្នុងគ្រោះថ្នាក់ចរាចរណ៍នោះបានធូរស្រាលវិញហើយ នៅក្នុងប្រទេសថៃ។ អ្នកស្រីបាននិយាយថា "ខ្ញុំអំពាវនាវឱ្យស្ថានទូតកម្ពុជាជួយបញ្ជូនគាត់ទៅប្រទេសកម្ពុជាវិញ ពីព្រោះគាត់រងរបួស ហើយមិនទាន់ជាសះស្បើយនៅឡើយទេ។

លោក ស៊ុម ចាន់គា អ្នកឃ្លាំមើលនៅអង្គការអាដហុកប្រចាំខេត្តបន្ទាយមានជ័យបានមានប្រសាសន៍ថា អង្គការរបស់លោកបានបញ្ជូនបុគ្គលិកមួយក្រុមទៅប្រទេសថៃដើម្បីស៊ើបអង្កេតករណីនេះ។

កាលពីថ្ងៃអង្គារលោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានមានប្រសាសន៍ថា ប្រទេសថៃត្រូវទទួលខុសត្រូវចំពោះបញ្ហាទាំងអស់ដែលកើតចេញពីការសម្រុកចាកចេញរបស់ពលរដ្ឋខ្មែរក្នុងចំនួនដ៏ច្រើនរួមទាំងអ្នកស្លាប់ផងដែរ។

ពលរដ្ឋខ្មែរប្រាំមួយនាក់បានស្លាប់ក្នុងគ្រោះថ្នាក់ចរាចរណ៍ដាច់ដោយឡែកពីគ្នានៅពេលដែលរថយន្តទូរីសដែលពួកគេជិះបានផ្ទុះកង់ខណៈធ្វើដំណើរមកព្រំដែន ហើយបានក្រឡាប់។

អាជ្ញាធរថៃបានជូនដំណឹងមកប្រទេសកម្ពុជាថា បុរសម្នាក់ទៀតបានស្លាប់កាលពីថ្ងៃសុក្របន្ទាប់ពីលោតចេញពីទូកនេសាទដែលគាត់បានធ្វើការដោយខុសច្បាប់ដើម្បីគេចពីការចាប់ខ្លួន។

រដ្ឋាភិបាលយោធាថៃបានទទួលស្គាល់ថា ពិតជាបានបង្ក្រាបទៅលើពលករចំណាកស្រុកនៅក្នុងប្រទេសដោយខុសច្បាប់មែន ប៉ុន្តែបានបដិសេធថា មិនមានគោលនយោបាយណាមួយបង្ខំឱ្យពលករខ្មែរចំណាកស្រុកចាកចេញពីប្រទេសថៃទេ។

យោងតាមរបាយការណ៍ពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានថៃបានឱ្យដឹងថា បន្ទាប់ពីជំនួបនៅក្រុងបាងកកកាលពីថ្ងៃអង្គាររវាងរដ្ឋមន្ត្រីការបរទេសថៃ និងឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃរដ្ឋាភិបាលថៃលើកឡើងថា ខ្លួនស្វាគមន៍ពលករចំណាកស្រុកពីប្រទេសកម្ពុជាត្រឡប់មកវិញ ឱ្យតែពួកគេមានលិខិតស្នាមត្រឹមត្រូវ។

បើទោះជាការភ័យខ្លាចជាកត្តាធ្វើឱ្យពួកគេចាកចេញក៏ដោយ ក៏ពលករដែលវិលត្រឡប់មកវិញនិយាយថា ពួកគេសង្ឃឹមថា នឹងបានទៅប្រទេសថៃវិញកន្លែងដែលពួកគេអាចរកការងារធ្វើច្រើន និងមានប្រាក់ខែខ្ពស់នៅពេលឆាប់ៗតាមដែលអាចធ្វើទៅបាន៕ **សារុន**

# Gov't Moves to Assist Workers Fleeing Thailand

**By Saing Soenthrith | June 13, 2014**

As another estimated 10,000 migrant workers poured over the border from Thailand on Thursday, Prime Minister Hun Sen ordered 150 military trucks to bring them back to their home provinces, according to the governor of Poipet City.

A rights group, meanwhile, reported that as many as nine Cambodian workers may have been killed during raids by Thailand's military junta, which this week began deporting illegal migrant workers en masse-rounding them up and squeezing them into caged trucks to drive them to the border.

Cambodian migrant workers arrive at the Poipet international border checkpoint yesterday, after being rounded up and deported by the Thai junta. (Soum Chankea)

Poipet City governor Ngor Mengchruon said Cambodian authorities are overwhelmed by the number of migrant workers arriving back in the country.

"Our forces are standing by to help our migrant workers, but today too many are being deported across the Poipet international checkpoint," he said. "Now Prime Minister Hun Sen ordered 150 military trucks to be sent to help our migrant workers."

Mr. Mengchruon estimated that at least 10,000 workers arrived Thursday alone. The provincial government provided 20 buses to help return workers home, and have been handing out food and water.

"All of our forces are too overwhelmed with them," he said.

Rights group Adhoc on Thursday said there had been reports that up to nine migrants had been killed by Thai soldiers, while at least one more was reportedly beaten.

"Returnees have reported violent raids on houses where illegal immigrants are suspected of residing and incidences of the tearing up of documentation entitling Cambodians to work legally in the country," a statement from Adhoc said.

Soum Chankea, Banteay Meanchey provincial coordinator for Adhoc, said he had spoken to returnees who said they were shot at and witnessed others killed.

In one case, he said, two men were shot to death after they tried to grab back legal working papers that soldiers began to tear up. **Continued to page 21**

# ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម សម្ដេចម៉ែមានសភាពស្ងាត់ខុសធម្មតា

**ដោយ ៖ គុច ណារ៉េន** | June 19, 2014

ខណៈដែលបុគ្គលិក កម្មករ និងមន្ត្រីរាជការទូទាំងប្រទេសបានឈប់សម្រាកមួយថ្ងៃកាលពីម្សិលមិញ ដើម្បីអបអរព្រះរាជពិធីបុណ្យចម្រើនព្រះជន្មសម្ដេចម៉ែនរោត្តម មុនីនាថ




សម្ដេចម៉ែបានប្រារព្ធព្រះរាជពិធីនេះដោយស្ងាត់ៗជាមួយសែរាជវង្សានុវង្សប្រមាណ៦០រូបក្នុងព្រះបរមរាជវាំង។

សម្ដេចម៉ែបានប្រារព្ធព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់៧៨ព្រះវស្សាយាងចូល៧៩ព្រះវស្សារបស់ព្រះអង្គ ដោយការទទួលពរជ័យពីព្រះសង្ឃប្រាំអង្គក្នុងពិធីតូចមួយនៅព្រះបរមរាជវាំងវេលាម៉ោង៩ព្រឹក នេះបើយោងតាមការឱ្យដឹងពីព្រះអង្គម្ចាស់ស៊ីសុវត្ថិ ធម្មិកោ ដែលបានចូលរួមព្រះរាជពិធីនេះដែរ។

ព្រះអង្គម្ចាស់បានមានព្រះបន្ទូលថា "សម្ដេចម៉ែកំពុងកាន់ព្រះរាជមរណទុក្ខព្រះ-បរមរតនកោដ្ឋ សម្ដេចឪ នរោត្តម សីហនុ ដូច្នេះគ្មានពិធីធំដុំ គ្មាន តន្ត្រី និងពិធីលាងសាយភោជនីសម្រាប់សម្ដេចម៉ែនរោត្តម មុនីនាថ ទេ។ មានសារលិខិតថ្វាយព្រះពរ និងកន្ត្រកផ្កាមួយចំនួន **តទៅទំព័រទី ២១**

# Palace Birthday Celebration for Queen Mother a Subdued Affair

**By Kuch Naren | June 19, 2014**

As workers across the country enjoyed a day off Wednesday to commemorate Queen Mother Norodom Monineath's birthday, the woman at the center of the occasion celebrated quietly with about 60 members of her extended family at the Royal Palace.

The Queen Mother marked her 78th year by receiving blessings from five Buddhist monks at a small ceremony inside the palace at 9 a.m., according to Prince Sisowath Thomico, who attended the event.

Queen Mother Norodom Monineath inspects a seven-tier cake made in honor of her 78th birthday on Wednesday in a photograph posted to the Facebook page of Princess Norodom Arunrasmey.

"Her Majesty Queen Mother has been in mourning for the late King Father Preah Norodom Sihanouk, so there is no big celebration, no music and no royal dinner for Royal Highness Queen Mother Norodom Monineath," the Prince said.

"There have been a number of blessing letters and baskets of flowers sent by various ambassadors and diplomats to Cambodia, but there was no royal reception with government leaders and other officials," he added.

Prince Thomico explained that since the late King Father's death in October 2012, the Queen Mother had stopped holding large birthday celebrations.

"In the past, the [late] King Father held a royal dinner with diplomats and government leaders, but there are no loud music or dining reception since the late King Father passed away," he said.

However, a seven-tier birthday cake shaped like the royal umbrella was presented to the Queen Mother during the day, and last night a fireworks display was launched across the Tonle Sap river from the Royal Palace.

The occasion brought together many

**Continued to Page 21**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ សៅរ៍ ទី២១ ខែមិថុនា ឆ្នាំ២០១៤

# ប្រេសិតពិសេសអង្គការសហប្រជាជាតិជួបពិភាក្សាជាមួយនិយោជកជុំវិញទំនាក់ទំនងវិជ្ជាជីវៈ

**ដោយ ៖ ល័រិន គ្រុធើរ** | **June 20, 2014**

លោក សុរិយា ស៊ូបេឌី ប្រេសិតពិសេសសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានជួបជាមួយតំណាងនិយោជក និងក្រុមហ៊ុននៅក្នុងប្រទេសកម្ពុជាកាលពីម្សិលមិញសម្រាប់កិច្ចពិភាក្សាដែលផ្តោតលើការការពារសិទ្ធិកម្មករ និងវិធានការដែលអាចត្រូវបានចាត់ឡើងដើម្បីធានាឱ្យបានថា ទំនាក់ទំនងវិជ្ជាជីវៈដែលមានបញ្ហាមិនផ្ទុះអំពើហិង្សាម្តងទៀត ។

នៅក្នុងកិច្ចសម្ភាសមួយមុនជំនួប លោក ស៊ូបេឌី បានឱ្យដឹងថា "ការពិភាក្សានឹងផ្តោតជាទូទៅលើការការពារសិទ្ធិកម្មករអំពីបញ្ហា ថាតើបុគ្គលនិងអង្គការផ្សេងៗគ្នាអាចរួបរួមគ្នា ដើម្បីចែករំលែកបទពិសោធតាមរបៀបណា និងដើម្បីឱ្យប្រាកដថា ហេតុការណ៍ដ៏ហិង្សាកន្លងមកនឹងមិនកើតឡើងម្តងទៀត"។

លោកស្រី សានដ្រា ដាមីកូ (Sandra D'Amico) អនុប្រធានសហព័ន្ធសមាគមនិយោជកនិងពាណិជ្ជកម្មកម្ពុជាដែលបានចូលរួមក្នុងជំនួបនេះបានលើកឡើងថា និយោជកបានប្រាប់លោក ស៊ូបេឌី ថា ពួកគេសង្ឃឹមថា នឹងបានឃើញចលនាសហជីពមានការសហការគ្នាកាន់តែច្រើន និងមានការអនុវត្តច្បាប់ការងារកាន់តែប្រសើរ ។

លោកស្រីបានមានប្រសាសន៍ថា "និយោជកបានពិភាក្សាគ្នាអំពីភាពចាំបាច់នៅក្នុងការរៀបចំរចនាសម្ព័ន្ធនៃចលនាសហជីពឱ្យបានកាន់តែល្អជាងមុន និងការសហការគ្នាឱ្យបានកាន់តែច្រើននៅក្នុងចលនាសហជីព ដើម្បីឱ្យសហជីពអាចធ្វើជាអ្នកតំណាង និងតំណាងឱ្យទស្សនរបស់កម្មករ"។

លោកស្រី ដាមីកូ បានលើកឡើងថា ការតវ៉ានៅផ្លូវវេងស្រេងដែលទីបញ្ចប់បាននាំឱ្យមានការបង្ក្រាបបណ្តាលឱ្យមានមនុស្សស្លាប់ពីសំណាក់កងរាជអាវុធហត្ថកាលពីថ្ងៃទី៣ ខែមករា គឺ "ជារឿងមានជាប់ពាក់ព័ន្ធនឹងនយោបាយ" ប៉ុន្តែលោកស្រីបានមានប្រសាសន៍ថា ការជួបពិភាក្សា

**តទៅទំព័រទី ១៥**

# UN Envoy Meets Employers Over Labor Unrest

**By Lauren Crothers | June 20, 2014**

U.N. human rights envoy Surya Subedi met with representatives of the country's businesses and employers Thursday for talks that focused on the protection of workers' rights and measures that can be taken to ensure that strained industrial relations do not once again erupt into violence.

In an interview prior to the meeting, Mr. Subedi said the discussion would focus "generally around the protection of workers' rights, how different people and organizations can come together to make a contribution and to make sure we don't see a repeat of the violent events that have taken place on this issue."

Sandra D'Amico, vice president of the Cambodian Federation of Employers and Business Associations, who attended the meeting, said employers told Mr. Subedi that they hoped to see a more coordinated union movement and stronger enforcement of the Labor Law.

Ms. D'Amico said the protests on Veng Sreng Street that led to lethal suppression by military police on January 3 were "politically motivated," but said the conversation with Mr. Subedi touched on "what we think is necessary to ensure there is not a repeat of what happened in the context of January."

"I don't think anyone can ensure that things are improved. What needs to be done is we need to manage expectations more carefully," she said. "We cannot do things in an ad hoc manner as we did in the past."

The Labor Ministry began talks last month to formalize and reform the garment sector's minimum-wage setting process, with the Labor Advisory Council agreeing this week to implement annual increases through tripartite negotiations between employers, unions and the government.

Mr. Subedi also said Thursday that the three new judiciary laws, which were meant to increase public trust in the courts, had been undermined by provisions that have been widely criticized for safeguarding the power of the executive.

"The very idea why I recommended that these laws be enacted was to give the judiciary the independence that it deserves, to command the trust and respect of the people.

"But now, the very limit of independence seems to have been undermined by certain provisions in these laws, especially the law on the Supreme Council of Magistracy," he said.

# គណបក្សសង្គ្រោះជាតិចុះទៅតំបន់ក្បែរព្រំដែនថៃតែត្រូវមន្ត្រី និងក្រុមបុរសស្លៀកស៊ីវិលរារាំង

**ដោយ សាំង សុឥន្ទរិទ្ធ នេង គុច ណារ៉េន**
**| June 20, 2014**

ការខិតខំរបស់លោក កឹម សុខា មេដឹកនាំគណបក្សប្រឆាំងដើម្បីទៅជួបជាមួយពលករខ្មែរចំណាកស្រុកដែលភៀសខ្លួនចេញពីការបង្ក្រាបលើពលករខុសច្បាប់ក្នុងប្រទេសថៃនៅក្រុងប៉ោយប៉ែត និងដើម្បីចែកប្រាក់នោះ ត្រូវរារាំងដោយអាជ្ញាធរមូលដ្ឋាន និងក្រុមបុរសគ្មានអត្តសញ្ញាណដែលស្រែកប្រមាថ និងដែលគេសង្ស័យថា បានគប់ស៊ុតដាក់ក្បួនរថយន្តរបស់លោក កឹម សុខា ។



ពលករខ្មែរចំណាកស្រុកប្រមាណ២០០.០០០នាក់បានឆ្លងព្រំដែនកាលពីពីរសប្តាហ៍កន្លងមកនេះ ដោយខ្លាចទាហានថៃចាប់ខ្លួនចាប់តាំងពីកងទ័ពថៃបានទម្លាក់រដ្ឋាភិបាលក្រុងបាងកកកាលពីខែមុនមក ហើយកម្មករភាគច្រើនបានឆ្លងកាត់ច្រកទ្វារអន្តរជាតិប៉ោយប៉ែតក្នុងខេត្តបន្ទាយមានជ័យ។

ដោយមានជំនួយពីអង្គការក្រៅរដ្ឋាភិបាល និងអ្នកស្ម័គ្រចិត្តនោះ រដ្ឋាភិបាលបានចាប់ផ្តើមផ្តល់ជំនួយមនុស្សធម៌នៅច្រកទ្វារអន្តរជាតិនេះ ដើម្បីជួយសម្រួលដល់ការភៀសខ្លួនដ៏គំហុកនេះ និងជួយពលករចំណាកស្រុកឱ្យបានត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញ។ **តទៅទំព័រទី ១៦**

# 'Thugs' Thwart CNRP's Relief Effort on Border

**By Saing Soenthrith and Kuch Naren | June 20, 2014**

Opposition leader Kem Sokha's efforts to meet Thursday with Cambodian migrant workers in Poipet City fleeing a crackdown on illegal laborers in Thailand and to hand out cash were thwarted by local officials and unidentified men who hurled abuse and allegedly pelted his convoy with eggs.

Some 200,000 Cambodian migrants have poured across the border in the past two weeks amid fears of arrest by soldiers since the Thai Army overthrew the government in Bangkok last month, most of them coming through the Poipet border crossing in Banteay Meanchey province.

With the help of NGOs and volunteers, the government has mounted a humanitarian effort at the checkpoint to deal with the sudden exodus and to help returnees make it back to their home provinces.

Mr. Sokha, vice president of the opposition CNRP, had traveled to Poipet hoping to meet and talk with the returnees and hand out cash donations of 30,000 riel, or about $7.50, to help with their journeys home.

A video posted to CNRP President Sam Rainsy's Facebook page, however, shows security forces using motorcycles and barricades to block the road and Mr. Sokha's convoy. It also shows Long Ry, a CNRP lawmaker-elect from Banteay Meanchey and the party's security chief, asking Poipet City governor Ngor Mengchruon to let them into the areas where the returnees were gathering-to no avail.

"I want to get inside to see the facts with His Excellency, the leader [Mr. Sokha]," Mr. Ry says in the clip.

The governor denies his request and tells them to make their donations from the CNRP's local party headquarters.

"On behalf of the local authorities I am very happy to see donations, but to avoid anything that can cause disorder, donations should be made at the [CNRP] office," Mr. Mengchruon replies.

He then grants the convoy permission to quickly drive through the area, but not to linger or hand out any donations, and the video clip shows returnees packed in trucks eagerly grabbing at Mr. Sokha's hand as he slowly rides past.

Men in civilian clothes-whom the Facebook post labels "CPP thugs"-are seen chasing after the convoy and yelling at Mr. Sokha to "go away."

"The CNRP wanted to support our migrant workers with humanitarian aid as they come to Poipet, then we wanted to travel around," **Continued to page 16**

## តមកពីទំព័រទី ១៤ ប្រេសិតពិសេសអង្គការសហ...

ជាមួយលោក ស៊ូបេឌី គឺផ្តោតលើ" អ្វីដែលយើងគិតថាចាំបាច់ ដើម្បីធានាឱ្យបានថា អ្វីដែលកើតឡើងកាលពីខែមករានោះ នឹងមិនកើតឡើងម្តងទៀត"។

លោកស្រីបានមានប្រសាសន៍បន្ថែមថា "ខ្ញុំគិតថា គ្មាននរណាម្នាក់អាចធានាបានថា អ្វីៗអាចប្រសើរឡើងនោះទេ។ អ្វីដែលយើងចាំបាច់ត្រូវតែធ្វើនោះ គឺត្រូវធ្វើដោយប្រុងប្រយ័ត្ន។ យើងមិនអាចធ្វើអ្វីៗដោយមិនបានគិតទុកជាមុន ដូចអ្វីដែលយើងធ្វើកន្លងមកឡើយ"។

ក្រសួងការងារបានចាប់ផ្តើមការពិភាក្សាគ្នាកាលពីសប្តាហ៍មុនដើម្បីទទួលស្គាល់ជាផ្លូវការ និងដើម្បីកែទម្រង់ដំណើរការកំណត់ប្រាក់ខែគោលនៅក្នុងវិស័យកាត់ដេរដោយក្រុមប្រឹក្សាផ្តល់យោបល់ផ្នែកការងារបានព្រមព្រៀងនៅក្នុងសប្តាហ៍នេះដើម្បីអនុវត្តការដំឡើងប្រាក់ខែប្រចាំឆ្នាំតាមរយៈកិច្ចចរចាត្រីភាគីរវាងនិយោជកសហជីព និងរដ្ឋាភិបាល ។

កាលពីម្សិលមិញ លោក ស៊ូបេឌី បានថ្លែងដែរថា ច្បាប់ចំនួនបីដែលត្រូវបានអនុម័តក្នុងប៉ុន្មានសប្តាហ៍ថ្មីៗមកនេះដោយរដ្ឋសភា និងព្រឹទ្ធសភាដែលជាមធ្យោបាយ ដើម្បីបង្កើនការទុកចិត្តចំពោះតុលាការត្រូវបានធ្វើឱ្យខូចដោយបទប្បញ្ញត្តិដែលត្រូវបានមជ្ឈដ្ឋានទូទៅរិះគន់ទាក់ទិននឹងការការពារអំណាចនីតិប្រតិបត្តិ ។

លោកបានមានប្រសាសន៍ថា "ខ្ញុំសប្បាយរីករាយណាស់ដែលច្បាប់ទាំងនេះបានឆ្លងកាត់សភាទាំងពីរ ប៉ុន្តែស្របពេលនោះនៅពេលដែលខ្ញុំត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់លើខ្លឹមសារនៃច្បាប់ខ្ញុំព្រួយបារម្ភអំពីបទប្បញ្ញត្តិមួយចំនួន។ មូលហេតុដែលខ្ញុំផ្តល់អនុសាសន៍លើច្បាប់ដែលត្រូវបានអនុម័តទាំងនេះ គឺដើម្បីផ្តល់ឱ្យតុលាការនូវឯករាជភាពដែលខ្លួនសមនឹងទទួល និងដើម្បីធ្វើឱ្យមានការទុកចិត្ត និងការគោរពប្រជាពលរដ្ឋ"។ លោកបានមានប្រសាសន៍បន្ថែមថា "ប៉ុន្តែឥឡូវនេះឯករាជភាពដែលមានកម្រិតហាក់បី ដូចជាត្រូវបានធ្វើឱ្យខូចដោយបទប្បញ្ញត្តិមួយចំនួននៅក្នុងច្បាប់ទាំងនេះ ជាពិសេសច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម" ៕

**គីមហឿន**










តមកពីទំព័រទី ១៤

## គណបក្សសង្គ្រោះជាតិចុះទៅតំបន់ក្បែរ...

លោក កឹម សុខា អនុប្រធានគណបក្សសង្គ្រោះជាតិបានធ្វើដំណើរទៅក្រុងប៉ោយប៉ែត ដោយសង្ឃឹមថា នឹងបានជួបសំណេះសំណាលជាមួយពលករចំណាកស្រុក និងចែកប្រាក់ចំនួន ៣០.០០០រៀល (ប្រហែល៧.៥០ដុល្លារ) ដើម្បីជួយឱ្យពួកគេបានត្រឡប់ទៅស្រុកកំណើតវិញ។

តែទោះជាយ៉ាងណាវីដេអូឃ្លីបមួយដែលត្រូវបានបង្ហោះលើទំព័រហ្វេសប៊ុករបស់លោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិបានបង្ហាញឱ្យឃើញថា កងសន្តិសុខបានប្រើម៉ូតូ និងរបាំងដើម្បីបិទផ្លូវ និងរារាំងក្បួនរថយន្តរបស់លោក កឹម សុខា ។ វីដេអូឃ្លីបនេះក៏បានបង្ហាញឱ្យឃើញផងដែរថា លោក ឡុង រី សមាជិកសភាជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិមកពីខេត្តបន្ទាយមានជ័យ និងជាប្រធានផ្នែកសន្តិសុខរបស់គណបក្សប្រឆាំងនេះដែរនោះបានស្នើសុំការអនុញ្ញាតពីលោក ងោ ម៉េងជ្រួន អភិបាលក្រុងប៉ោយប៉ែតឱ្យពួកគាត់ចូលទៅតំបន់ដែលពលករចំណាកស្រុកកំពុងជួបជុំគ្នា ប៉ុន្តែមិន បានសម្រេចនោះទេ។

លោក ឡុង រី បានមានប្រសាសន៍នៅក្នុងវីដេអូឃ្លីបនោះថា "ខ្ញុំចង់ចូលទៅ ដើម្បីចង់ដឹងការពិតជាមួយឯកឧត្តមឱ្យ កឹម សុខា"។ លោកអភិបាលក្រុងប៉ោយប៉ែតរូបនេះ បានបដិសេធការស្នើសុំរបស់លោក ឡុង រី ហើយបានប្រាប់ពួកគាត់ឱ្យទៅចែកអំណោយនៅទីស្នាក់ការគណបក្សសង្គ្រោះជាតិនៅក្នុងខេត្តនោះវិញ។

លោក ម៉េងជ្រួន បានឆ្លើយតបថា "ក្នុងនាមជាអាជ្ញាធរមូលដ្ឋានខ្ញុំរីករាយណាស់ដែលបានឃើញអំណោយ ប៉ុន្តែដើម្បីចៀសវាងបញ្ហាដែលអាចធ្វើឱ្យខូចសណ្តាប់ធ្នាប់នោះ ការចែកអំណោយគួរតែធ្វើឡើងនៅការិយាល័យឱ្យគណបក្សសង្គ្រោះជាតិ"។

បន្ទាប់មកលោកបានអនុញ្ញាតឱ្យក្បួនរថយន្តបើកកាត់តំបន់នោះ ប៉ុន្តែមិនឱ្យបង្អែបង្អង់ ឬក៏ចែកអំណោយនោះទេ ហើយវីដេអូឃ្លីបនេះក៏បានបង្ហាញឱ្យឃើញពីពលករចំណាកស្រុកដែលជិះលើរថយន្តចង់ចាប់ដៃលោក កឹម សុខា ខណៈរថយន្តរបស់លោកបើកឆ្លងកាត់យ៉ាងយឺតៗផងដែរ។

ក្រុមបុរសស្លៀកស៊ីវិលដែលនៅលើទំព័រហ្វេសប៊ុកហៅថា "មនុស្សរបស់គណបក្សប្រជាជនកម្ពុជា" ត្រូវបានគេឃើញថាបានដេញតាមពីក្រោយក្បួនរថយន្ត ហើយស្រែកឱ្យលោក កឹម សុខា "ចាកចេញឆ្ងាយ"។

លោក ឡុង រី បានមានប្រសាសន៍ពេលទាក់ទងតាមទូរស័ព្ទតាមក្រោយថា "គណបក្សសង្គ្រោះជាតិចង់ផ្តល់ជំនួយមនុស្សធម៌ឱ្យពលករចំណាកស្រុក ខណៈពួកគាត់មកក្រុងប៉ោយប៉ែត ហើយបន្ទាប់មកទៀតយើងចង់ធ្វើដំណើរកម្សាន្តក្នុងក្រុងនេះ។ ប៉ុន្តែប្រតិភូរបស់យើងត្រូវបានរំខានដោយឧគ្ឃោសនសព្ទ និងស៊ីផ្លេដែលចេញពីរថយន្តយោធា និងការស្រែកចេញពីក្រុមបុរសពាក់អាវខៀវ"។

លោក ស៊ុម ចាន់គា អ្នកឃ្លាំមើលរបស់អង្គការអាដហុកប្រចាំខេត្តបន្ទាយមានជ័យបានឱ្យដឹងថា រថយន្តមួយគ្រឿងនៅក្នុងក្បួនរបស់គណបក្សសង្គ្រោះជាតិដែលមិនមែនជារថយន្តរបស់លោក កឹម សុខា ក៏មានប្រឡាក់ថ្នាំពណ៌ និងស៊ុតផងដែរ ហើយបានតតាំងជាមួយរ៉ឺម៉កម៉ូតូកង់បីចំនួនពីរគ្រឿងដែលអ្នកដំណើរក្នុង រ៉ឺម៉កនោះ បានលាបដាដែលមានសរសេរថា ការគាំទ្រឥតងាករេរបស់ពលរដ្ឋមូលដ្ឋានចំពោះលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងការស្អប់ចំពោះ "មនុស្សអាក្រក់"។

លោក កែ សម្ផស្ស ទីប្រឹក្សានៅគណបក្សសង្គ្រោះជាតិប្រចាំខេត្តបន្ទាយមានជ័យបានលើកឡើងថា ការខិតខំរារាំងនោះពិតជាមានការរៀបចំទុកជាមុន។ លោកបានមានប្រសាសន៍ថា "វាមិនមែនកើតឡើងដោយចៃដន្យទេ។ វាត្រូវបានរៀបចំឡើងយ៉ាងល្អដើម្បីប្រឆាំងនឹងប្រតិភូបក្សរបស់យើង។ ប្រតិភូរបស់យើងចង់ចែកប្រាក់ខ្លះ ដើម្បីឱ្យពលករចំណាកស្រុកអាចមានសោហ៊ុយធ្វើដំណើរទៅស្រុកកំណើតវិញ ព្រោះរថយន្តដឹកពួកគេមកត្រឹមទីរួមខេត្តប៉ុណ្ណោះ ប៉ុន្តែយើងមិនអាចធ្វើអ្វីបានទេ"។

ទាំងលោក ម៉េងជ្រួន និងលោក គោស៊ុំ សារឿត អភិបាលខេត្តបន្ទាយមានជ័យមិនអាចទាក់ទងសុំការធ្វើអត្ថាធិប្បាយបានទេ។ លោក អ៊ុំ សុផល ស្នងការនគរបាលក្រុងប៉ោយប៉ែតបានឱ្យដឹងថា លោកមិនបានដឹងថា អ្នកដែលគេចោទថាជា "មនុស្សរបស់គណបក្សប្រជាជនកម្ពុជា" នេះជានរណាទេ។

លោកបានមានប្រសាសន៍ថា "យើងមិនស្គាល់មនុស្សទាំងនោះទេ ។ ហើយមិនដឹងថាតើពួកគេជាមនុស្សគណបក្សប្រជាជន ឬនរណាឱ្យប្រាកដទេ ដែលនិយាយរឿងអាក្រក់ៗ ឬដែលដេញក្បួនរថយន្តរបស់លោក កឹម សុខា នោះ"។

លោក សម រង្ស៊ី និងលោក កឹម សុខា ដែលជួបការលំបាកយ៉ាងខ្លាំងក្នុងការចរចាជាមួយគណបក្សប្រជាជនកម្ពុជា ដើម្បីបញ្ចប់ការធ្វើពហិការមិនចូលសភារបស់គណបក្សសង្គ្រោះជាតិដើម្បីតវ៉ាប្រឆាំងនឹងការបោះឆ្នោតជាតិដ៏ចម្រូងចម្រាសកាលពីឆ្នាំមុនត្រូវនគរបាល និងក្រុមបុរសស្លៀកស៊ីវិលរារាំងរាល់លើកចំពោះការធ្វើដំណើរទៅតាមខេត្តក្នុងប៉ុន្មានសប្តាហ៍ថ្មីៗនេះ។

កាលពីដើមខែមិថុនា បុរសមួយក្រុមបានបិទផ្លូវដោយខុសច្បាប់ ដើម្បីរារាំងមេដឹកនាំទាំងពីរនេះមិនឱ្យចុះទៅតំបន់ខ្លះក្នុងខេត្តឧត្តរមានជ័យ រីឯនគរបាលមូលដ្ឋានវិញមិនអើពើអ្វីឡើយ ។

កាលពីមួយខែមុនកងរាជអាវុធហត្ថបានរារាំងលោក សម រង្ស៊ី មិនឱ្យចុះទៅសួរសុខទុក្ខសហគមន៍មួយនៅភាគឦសាននៃខេត្តរតនគិរីដែលមានវិវាទដីធ្លីជាយូរមកហើយជាមួយក្រុមហ៊ុនកសិឧស្សាហកម្មឡើយ ដោយលើកឡើងដើម្បីសុវត្ថិភាពផ្ទាល់ខ្លួនរបស់មេដឹកនាំគណបក្សរូបនេះ៕ **គឹមហឿន**

Continued from page 1?

## 'Thugs' Thwart CNRP's Relief Effort

said Mr. Ry, contacted by telephone afterward.

"But our delegation was disturbed with loudspeakers and horns from military trucks and yelling from a group of men in blue shirts."

Soum Chankea, a monitor in the province for rights group Adhoc, said a car in the CNRP convoy-not Mr. Sokha's-was also splattered with paint and eggs and met by a pair of tuk-tuks whose passengers rolled out banners proclaiming the local population's undivided support for Prime Minister Hun Sen and its distaste for certain unspecified "bad men."

Ker Samphoas, an adviser to the CNRP in the province, said the effort was surely coordinated.

"It did not happen by accident. It was well organized against our party delegation," he said. "Our delegation wanted to hand out some extra money so they [the returnees] could pay for taxis to get home, because the trucks only take them to the provincial towns, but we couldn't."

Neither Mr. Mengchruon nor provincial governor Kousoum Saroeuth could be reached for comment. Poipet City police chief Um Sophal said he had no idea who the alleged "CPP thugs" were.

"We don't know about those people, whether they were CPP who said bad things or chasing Kem Sokha's convoy," he said.

Mr. Rainsy and Mr. Sokha, who are in difficult talks with the CPP to end the CNRP's boycott of the National Assembly in protest over last year's disputed national elections, have had several of their provincial trips blocked by police and plainclothes groups in recent weeks.

In early June, a group of men set up an illegal roadblock that kept the pair from visiting parts of Oddar Meanchey province that had served as the final bastion of the Khmer Rouge, while local police did nothing.

A month earlier, military police prevented Mr. Rainsy from visiting a community in northeastern Ratanakkiri province that is locked in a long-running land dispute with an agribusiness firm, supposedly for the opposition leader's own safety.




Continued from Page 04

# How the Portrayal of Asians in the...

"best friend" and not the hero?

Many adaptations of Japanese anime or manga done in the United States which present strong, usually Asian, heroes reset the traditional Japanese setting to an American one, and instead of casting Asian actors, studios cast big-name stars who are not Asian. In a CNN article, Stephanie Siek quotes, "Kent A. Ono, a professor of Asian-American studies at the University of Illinois at Urbana-Champaign, said the practice of casting white actors to play Asians and Asian-American characters has a long history in Hollywood. Until recent decades, this mostly took the form of white actors playing stereotypical representations of Asian characters" (Siek). The Academy Award-winning portrayal of O-Lan from The Good Earth was performed by Louise Rainer, a German actress (Higbie). The famous performance byMickey RooneyinBreakfast at Tiffany's is currently thought of as racist, but at the time Rooney was applauded for his amazing performance in the Oscar-award-winning movie (Calder). If Asian actors cannot even get good parts that are specifically 'Asian,' how will they ever get parts that aren't written for 'Asians?'

The lack of Asians on screen does do psychological and social damage to both Asian and non-Asian children. The lack of childhood role models for Asian-American children slows the social progression towards complete liberation. In 2009, Kevin Wu, a notable YouTube video blogger, mentioned his lack of Asian role models in his life as a kid. He talked about Goku, a popular anime character, as being his childhood hero. "There weren't any other Asian superheroes growing up, so Goku was like our only idol, our hero" (Wu). Asian children search for role modelswith whom to identify, and when they don't find them in Hollywood, some turn to the media coming out of Asia, likeJapanese animation, for heroes. These stereotypes also change how non-Asian children socially relate to Asian children. For non-Asian children, images like these may lead to limited thinking: Asians are only good at certain things, or every Asian kid in their class will grow up the same way. Audrey Kwak supports this view in Asian Americans in the Television Media: Creating Incentive for Change, and writes, "For children, the visual absence of Asian Americans on television establishes subconscious conclusions of what one can and cannot be – actors, anchormen, and women – and perceptions of what one is – studious, exotic, nerdy" (Kwak, 409 ). The lack of confirmation that Asian Americans can succeed in television can clearly affect how people think and what people think certain groups can do. Adin Kahisi, an African American author of Beyond the Talented Tenthspoke on Maurice Carvier's showBlack Men Screaming, and recognized "the invisibility... a veil is actually put on the Asian community when it comes to public media, nobody sees them. [The] public opinion that's created through the media is the quiet Asian that you never see" (qtd. Carvier).We must improve and change the visuals to be able to change minds, but we must change minds before we can change visuals. Options must be opened and stereotypes must be overcome to socially liberate the world.

But what are these "Asian stereotypes" that are portrayed on screen? In the first decades of television and movies, several Asian stereotypes became prevalent. One stereotype that Asian actors have encountered is the outdated idea that Asians can only hold certain clichéd jobs like restaurant workers, businessmen, martial artists, and laundry workers. Audrey Kwak, writing for the Boston College Third World Law Journal describes the hardships of an Asian actor in the media. "One Asian actor's experience is particularly telling: in a 2003 survey of Asian Americans in prime time TV, he disclosed that he had played 'a dry cleaner and a Chinese take-out delivery man in 21 different prime-time shows' in the span of a few years" (Kwak, 407-408). Other stereotypes which affect Asian actresses include two-dimensional characters like the "dragon lady," an aggressive and usually sexualized woman, or the "China doll," a submissive, helpless, pure-hearted woman, which are offensive because they display an inaccurate view of Asian cultures. Jeffry Kimble, an African American man, speaking on Black Men Screaming, also discusses certain stereotypes that Asians encounter onscreen. "If you look on television you don't really see a lot of Asian Americans portrayed in roles. There are a number of supporting roles. A lot of times they are the only single members of a cast, so if it's an Asian male he doesn't get the luxury of an Asian wife" (qtd. Carvier).

Various Asian actors have spoken and written about how they feel and what they think about auditioning for certain parts. Actress Lucy Liu, currently cast as Watson in CBS's new show, "Elementary," said when she was auditioning for the Broadway revival of Miss Saigon in 1990, "There aren't many Asian roles, and it's very difficult to get your foot in the door. 'Miss Saigon' is really important for all Asians. It will have so much to do with what happens in the future for us in the theater" (qtd. Rothstein). Some may argue that societal perceptions have changed in the last 20 years, but in 2010, Raymond Wong, a Hong Kong actor struggling to make it in Hollywood, wrote about his experience with casting directors: "[They] simply wouldn't cast me in anything not written as 'Asian.'" He wrote about the hordes of hungry Asians at casting calls. "The only... description was that the actor must be Chinese... When I got to the audition, there [was] a roomful of Asian actors... hungry for work, and their agents sent them out regardless of whether they were, in fact, of Chinese descent... We're going into the second decade of the 21st century, and Hollywood is still stuck in the 50's sometimes. It is frustrating" (Wong). Finding Asian actors in roles where race was not the reason they were cast is rare, but this disparity is becoming more apparent as television becomes a more and more important influence. When there is such a lack of roles for Asian actors, then directors, casting directors, and producers must open their minds to non-traditional or non-conventional casting.

Today, the number of Asian stereotypes on television and in movies has decreased, contrary to what Raymond Wong thinks. Even though the stereotypes portrayed in American media has decreased, as a country we all must keep fighting for completely accurate depictions on the screen for all racial minorities. The increased popularity of the media coming from South Korea and Japan has started to portray East Asia as cool and modern which should help the image of Asians that has been maintained in Hollywood . Other racial groups have already broken through these limiting factors. After the African American Civil Rights movement succeeded in changing the negative views and discrimination directed at African Americans, sitcoms that featured a Black family as the main characters (like "The Cosby Show") broke out of the social constraints of past times. Though Asian portrayals haven't improved as quickly as the portrayals of African Americans, the representation of Asians has improved over time. "We are making headway. I'm not a pessimist," Takei said. "We have made tremendous headway from the time I started in this business in 1957" (qtd. Von Metzke).

It is clear that the Asian misrepresentation in the media is damaging and pervasive. Though we must admit that we have become more supportive of "the exotic" in the media, we cannot say that the problem is fixed. It is clear that Asian stereotypes are still very much with us. The media is expanding, allowing more opportunities to arise for Asian American actors to seize their chances and change the media. Our country should applaud these endeavors, and show the mainstream media how important it is to represent all people in America today.



# ដេកមិនលក់ ប៉ះពាល់សុខភាព និងសម្រស់



●●●ដេកមិនលក់ធ្វើឱ្យមានផលវិបាកច្រើនចំពោះសុខភាព និងសម្រស់។ លោកអ្នកគ្រប់រូបពិតជាចៀសមិនផុតឡើយចំពោះបញ្ហាដេកមិនលក់។ ដេកមិនលក់នេះទៀតសោតអាចបណ្តាលឱ្យមានរង្វង់ភ្នែកខ្មៅ ខូងភ្នែក ជម្ងឺឈឺក្បាល ឬរិលមុខជាដើម។ ប៉ុន្តែដេកមិនលក់មិនមែនជាជម្ងឺទេ គ្រាន់តែជាអាការរោគមួយប្រភេទដែលបណ្តាលមកពីការគិតច្រើននិងមកពីជម្ងឺផ្សេងៗ។

**មូលហេតុដេកមិនលក់**

អាការដេកមិនលក់កើតមកពីបញ្ហា២យ៉ាង។

**១. បញ្ហាផ្លូវកាយ :** ជម្ងឺពាក់ព័ន្ធរាងកាយមានដូចជាឈឺសរសៃរោយឆ្អឹងខ្នងបញ្ហារោគស្ត្រីជាដើម។ ម្យ៉ាងទៀតវាអាចបណ្តាលមកពីការធ្វើការច្រើនហួសកំណត់ពុំសូវមានពេលសម្រាកដែលភាគច្រើនកើតមានលើកម្មករសំណង់ និងអ្នកធ្វើការនៅរោងចក្រ ។ ជួនកាលមកពីការទទួលទានអាហារច្រើនជ្រុល ក៏ធ្វើឱ្យរសាប់រសល់ពិបាកដេក។

**២. បញ្ហាផ្លូវចិត្ត :** អាចកើតចេញជាច្រើន រូបភាពតាមរយៈពិបាកចិត្ត ឬស្មុគស្មាញនៅកន្លែងធ្វើការដែលជាកត្តាចម្បងសម្រាប់ការគិតច្រើនធ្វើឱ្យដេកមិនលក់។ អ្នកខ្លះទៀតកង្វល់អំពីបន្ទុកក្រុមគ្រួសារ មានការមិនយល់ចិត្តគ្នា ឬដោះស្រាយមិនចេះចប់មិនចេះហើយជាដើម។ ម្យ៉ាងទៀតមូលហេតុដេកមិនលក់ក៏អាចដោយសាររឿងស្នេហាមានជម្លោះមិនសូវត្រូវរ៉ូវគ្នាជាដើមផងដែរ។

**វិធីដោះស្រាយដេកមិនលក់**

មានដំណោះស្រាយមួយចំនួនសម្រាប់លោកអ្នកជួយខ្លួនឯងឱ្យគេងលក់ស្រួល។

តទៅទំព័រទី ២៤

តមកពីទំព័រទី ០៨ **មីយាមី នៃរដ្ឋ ផ្លរីដា ជាតំបន់កសិកម្ម...**

ស្មើរខានមិនបាននៅតូបមួយដែលតាំងនៅកណ្តាលទីផ្លាមិនអាចចៀសមិនឃើញ ឬមិនស្រេកទឹកមាត់មិនកើត។

ល្ងាចនេះក្រុមយើងសម្រេចបរិភោគល្ងាចនៅក្បែរចំណតនាវាកំសាន្តដោយសារជាផ្លូវចេញចូលនៃនាវាគ្រប់ធុនរាប់ទាំងនាវានេសាទផង ដែលយើងគិតថា នឹងសម្បូរម្ហូបសមុទ្រស្រស់ៗជាមិនខាន។ យើងចូលភោជនីយដ្ឋានមួយឈ្មោះ ហ្វ៉ារែសតូចច្រឡឹងតែស្អាតមានអ្នកទទួលភ្ញៀវរាក់ទាក់ច្រើន ជាស្ប៉ានិសនិយាយអង់គ្លេសនៅតែជាស្ប៉ានិសច្រើននៅឡើយ នៅទីប្រជុំរមនីយដ្ឋានដូច្នេះមិនសូវខ្វះភ្ញៀវចេញចូលទេ តែថ្ងៃនេះចំថ្ងៃគេប្រគួតបាល់ឱបក្រុមល្បីឈ្មោះនៅកីឡាដ្ឋានក្បែរភោជនីយដ្ឋានយើងអាចជ្រើសតុណាអង្គុយក៏បានដែរ ស្រុកនេះគេចូលចិត្តមើលបាល់ឱបច្រើនជាងឃ្លានបាយទៅទៀត។ យើងពិគ្រោះគ្នាក្នុងការហៅមុខម្ហូប ហើយព្រមព្រាងគ្នាបញ្ជាម្ហូបមានត្រីសមុទ្រ មានបង្គារស្រុស មានគ្រុំ នឹងមឹកចៀនតែដែលគួរឱ្យអស់សំណើចនោះ គឺថ្ងៃល្ងាចនេះអ្នកបំរើមានចំនួនច្រើនជាងភ្ញៀវតែគេប្រាប់យើងថា គេមានបំរើសាច់អាំងថ្មីៗគ្រប់មុខបើចង់ហៅរកអ្នកបំរើ គ្រាន់តែលើកបា្លកសញ្ញាពណ៌ខៀវពេលមានសាច់ឆ្អិនភ្លាមអ្នកបំរើនឹងយកមកបង្ហាញដើម្បីឱ្យជ្រើសរើសអ្វីដែលភ្ញៀវត្រូវការតែបើមិនត្រូវការទៀតទេ ឱ្យដាក់ទង់សញ្ញាពណ៌ក្រហមអ្នកចំអិនសាច់នឹងឈប់មកសួរនាំទៀតហើយ ។ ម្លោះហើយសាច់មាន់អាំងសាច់គោអាំងសាច់ចៀមអាំងយ៉ាងឈ្ងុយឆ្ងាញ់មកបន្តបន្ទាប់គ្នាយ៉ាងញាប់មានសាច់អ្វីផ្សេងទៀតដែលមិនចាំច្បាស់ ក៏មកជាមួយដែរធ្វើឱ្យចង់ភ្លក់ជាខ្លាំងពេលខ្លះប៉ុណ្ណារ៉ូ ទៅបើកលេងទង់ប្លាកដាក់ពណ៌ក្រហមបានបញ្ឈប់ការបួលសាច់អាំងស្វ័យប្រវត្តដោយមិដឹងខ្លួនទាល់តែបាត់អ្នកបំរើយូរបន្តិច ទើបមានអ្នកសួររកទើបដឹងថា មានបន្ទំប្តូរប្លាកបណ្តាលឱ្យផ្ទុះសំណើចគ្រប់គ្នាមានតែប៉ុណ្ណារ៉ូទេដែលធ្វើមុខឡិងឡង់មិនដឹងគេសើចរឿងអ្វីទេ។ វិធីបំរើនេះធ្វើឱ្យយើងភ្លេចខ្លួនបរិភោគសាច់អាំងហួសចំណុះភ្លេចងម្ហូបបញ្ជាឯទៀតៗធ្វើឱ្យសល់ក៏ត្រូវខ្ចប់យកទៅផ្ទះទាំងមិនចង់តែស្តាយ ពីព្រោះសល់ម្ហូបច្រើនពេក ។

យើងបញ្ចប់រាត្រីនៅភោជនីយដ្ឋានយ៉ាង ឃឹតពេលពេញមួយថ្ងៃនេះយើងក៏បានក៏បានទៅទស្សនាកន្លែងផ្លែកៗបានច្រើនដែរ ធ្វើឱ្យយើងនឿយហត់មិនតិចទេ តែរីករាយនឹងបានឃើញថ្មីៗ ដែលផ្លែកភ្នែកថា បានរឿនសូត្រពីដំណើរកំសាន្តរបស់យើងខ្លះដែរ។ អ្នកស្រី ភីរុង បើកឡានត្នាំយើងត្រឡប់មកសណ្ឋាគារវិញ ក្រោមទស្សនីយភាពរាត្រីកាលនៃម៉ាយ៉ាមីដែលពន្លឺភ្លើងអគ្គីសនីបំភ្លឺគ្រប់ទិសទីក្រុងដដែលក៏បានក្លាយជាក្រុងពន្លឺមួយទៀតមើលលែងស្គាល់ថែមទាំងមានភ្លៀងធ្លាក់ថែមទៀត នាំឱ្យដំណើរយើងរឹតតែយឺត ។ មកដល់សណ្ឋាគារដល់ឱកាសនឹងកន្លែងលាគ្នាជាមួយអ្នកស្រីភីរង់ព្រមទាំងអរគុណដែលបាននាំឱ្យស្គាល់រមនីយដ្ឋានថ្មីៗដែលអនុញ្ញាត្តិឱ្យយើងសរសេរអត្ថបទនេះជូនលោកអ្នកអានបាន។

នៅបាំងមួយថ្ងៃទៀត យើងនឹងហោះហើរត្រឡប់មកឡូវែលវិញ ដូច្នេះវាជាថ្ងៃសម្រាកសម្រាប់រៀបឥវ៉ាន់នឹងទិញវត្ថុអានុស្សាវរីយផ្ញើមិត្តភក្រ្ត។ អង្គុយតែម្នាក់ឯងសម្លឹងមើលអ្នកហែលទឹកក្នុង ស្វីមីងពូល មើលអ្នកដេកសំដឹលក្រោមពន្លឺថ្ងៃក្តៅហែងមើលអ្នកបំរើជញ្ជូនម្ហូបនឹងភេសជ្ជៈជូនភ្ញៀវងាកទៅសមុទ្រដែលក្មេងចាស់ឈ្មុលច្រមុះក្នុងដីខ្សាច់ ឬចុះប្រលែងរលកសមុទ្រដោយស្មើតែគ្មានសំលៀកបំពាក់បិតបាំងខ្លួនទាល់តែសោះមើលអ្នកយាមនៅទីខ្ពស់ទីទាបប្រឹងការពារសន្តិសុខដែនដីខ្សាច់ឆ្នេរសមុទ្ររបស់ខ្លួនអារម្មណ៍សម្បូរបែបក៏ហោះហើរចេញមកដែរ ។ សំនួរដែលគ្មានចំឡើយ ហូរចេញមកយ៉ាងគ្មានសណ្តាប់ធ្នាប់ហេតុអ្វីបានជាមានអាងហែលទឹកនៅក្បែរគ្នានឹងមាត់សមុទ្រ ហេតុអ្វីក៏អ្នកបំរើទៅយកចិត្តអ្នកដេកមិនចង់ហូប ហេតុអ្វីក៏ទៅទិញកន្លែងសម្រាប់លេងដីខ្សាច់ ហេតុអ្វីក៏អ្នកមានដោះខោអាវ រីឯអ្នកក្របឹ្រងស្លៀកសំពត់អាវទោះជាក្តៅហែងក៏ដោយ... ហេតុអ្វី? ហេតុអ្វី? ហេតុអ្វី?



អារម្មណ៍ហៀរហូរមិនត្រឡប់មកវិញពីព្រោះគ្មានចម្លើយអ្វីក្រៅពីសង្គមសម័យនៃទីផ្សារពាណិជ្ជកម្មនៃសង្គមទំនើបនៃវប្បធមិអនាគត គឺជាការព្យាបាលជម្ងឺផ្លូវចិត្តចាស់របស់យើងដែលតាំងពី៥០ឆ្នាំចុងក្រោយនេះមកសង្គមខ្មែរចេះតែគម្រាម បង្ខំ បន្ទុះបង្អាប់ បង្ហាត់តែឱ្យខ្លាច ឱ្យធ្វើតាម គោរពអ្នកធំ អ្នកមានលុយ អ្នកមានអំណាច...តែនៅនគរថ្មីនេះ យើងមានសិទ្ធនឹងជ្រើសរើសសណ្ឋាគារដែលយើងចង់នៅមានសេរីភាពនឹងធ្វើអ្វីដែលយើងប្រាថ្នាចង់បានចង់ដេកលើដីខ្សាច់ ឬលើគ្រែ អ្នកចង់ធំ ឬអ្នកចង់តូចគេមានគំរូនៃការឡើងកាន់អំណាចស្មើគ្នាក្នុងច្បាប់...។ ខ្ញុំនៅចាំពាក្យរបស់គ្រូពេទ្យខាងជម្ងឺផ្លូវចិត្តម្នាក់និយាយថា ការធ្វើអ្វីដែលយើងចង់យើងមានគម្រោងចូលរួមដោយខ្លួនឯងដោយគ្មានបង្ខិតបង្ខំ គឺជាការព្យាបាលសុខភាពរូបរាងកាយដ៏សំខាន់បំផុតសំរាប់ជីវិតមនុស្ស ៕

# ប្រាសាទអង្គរវត្ត និងប្រាសាទបាយ័នជាប់លេខ ៦ និង ៧ ក្នុងចំណោមទេសភាពស្រស់ស្អាតបំផុតនៅលើដីទាំង២៥

**ដោយ ៖ សុខា**

ប្រភពអត្ថបទពីគេហទំព័រទ្រីបអែតវៃសឺ

រដូវក្តៅឈានចូលមកដល់។ ខែមិថុនា អាកាសធាតុល្អ មានពន្លឺថ្ងៃ ហើយថ្ងៃវែងជាងយប់នាំឱ្យមានការគិត តើត្រូវឱ្យវេលាដែលវែងនេះប្រព្រឹត្តទៅឱ្យមានអត្ថន័យរបៀបណា!។ មនុស្សម្នាហាក់ស្រស់ស្រាយមានអំណររាល់ពេលដែលរដូវកាលនេះមកដល់។

តាមរយៈគេហទំព័រទ្រីបអែតវ៉ាយសឺទីតាំងចំនួន២៥ ត្រូវបានជាប់ចំណាត់ថ្នាក់ជាកន្លែងដែលមានទេសភាពស្រស់ស្អាតបំផុតនៅលើដី។

លោកអ្នកអាននឹងបានឃើញទីតាំងបីដែលមានចំណាត់ថ្នាក់នាំមុខមានលេខមួយគឺ

Machu Picchu នៃប្រទេស ពេរូ (Peru) លេខពីរគឺ Sheikh Zayed Grand Mosque Center Abu Dhabi, នៃប្រទេស យូណៃធីត អារ៉ាប់ អេមីរែត (United Arab Emirates) និងលេខបីគឺ Taj Mahal ក្រុង Agra ប្រទេសឥណ្ឌា (India)។

សំខាន់ជាងនេះ គឺប្រាសាទអង្គរវត្ត និងប្រាសាទបាយ័ន ដែលជាបេតិកភ័ណ្ឌនៃព្រះរាជាណាចក្រកម្ពុជាទទួលបានចំណាត់លេខ៦ និង៧ មានសម្លេងល្អក្នុងឆាកអន្តរជាតិត្រដមត្រសងនឹងតំបន់ទេសចរណ៍លំដាប់១នានាក្នុងពិភពលោក។

ប្រាសាទអង្គរវត្តដែលទទួលបានចំណាត់ថ្នាក់លេខ៦ និងប្រាសាទបាយ័នដែលទទួលបានចំណាត់ថ្នាក់លេខ៧ ស្ថិតក្នុងខេត្តសៀមរាបនៃព្រះរាជាណាចក្រកម្ពុជា។ ប្រាសាទទាំងពីរមានវ័យចំណាស់រាប់ពាន់ឆ្នាំមកហើយ ហើយនាំប្រទេសកម្ពុជាឱ្យត្រូវបានពិភពលោកចាប់អារម្មណ៍និងយកចិត្តទុកដាក់។



1-Machu-Picchu ប្រទេសពេរូ



2- Sheikh-Zayed-Grand-Mosque-in-Abu-Dhabi ប្រទេស យូអេ-អ៊ី

ឈ្មោះទាំង២៥នៃទីតាំងដែលមានទេសភាពលើដីស្រស់ស្អាតបំផុត លេខ១គឺ Machu Picchu នៃប្រទេស ពេរូ (Peru) លេខពីរគឺ Sheikh Zayed Grand Mosque Center

Abu Dhabi, នៃប្រទេស យូណៃធីត អារ៉ាប់ អេមីរែត (United Arab Emirates) និងលេខបីគឺ Taj Mahal ក្រុង Agra ប្រទេសឥណ្ឌា India) ៤ លេខ៤ គឺ Great Cathedral and Mosque

Cordoba នៃប្រទេសអេស្ប៉ាញ (Spain) លេខ ៥ St. Peter's Basilica, Vatican City, Italy លេខ៦ គឺប្រាសាទអង្គរវត្ត (Angkor Wat ) ប្រទេសកម្ពុជា(Cambodia)លេខ៧ គឺប្រាសាទបាយ័ន (Bayon Temple) ប្រទេសកម្ពុជាលេខ៨ គឺ Church of Our Savior on Spilled Blood, St. Petersburg, Russia លេខ ៩គឺ Gettysburg National Military Park

Gettysburg, Pennsylvania លេខ១០គឺ Ancient City Walls, Dubrovnik, Croatia

លេខ ១១គឺ Shwedagon Pagoda, Yangon (Rangoon), Myanmar លេខ១២ Lincoln Memorial and Reflecting Pool, Washington DC, District of Columbia លេខ ១៣ Petra World Heritage Site, Petra - Wadi Musa, Jordan លេខ ១៤ Great Wall at Mutianyu, Beijing, China លេខ១៥ Ancient City of Ephesus, Selcuk, Turkey លេខ ១៦ The Alhambra, Granada, Spain លេខ១៧ Australian War Memorial, Canberra, Australia លេខ ១៨ Siena Cathedral ,Siena, Italy លេខ ១៩ Milan Cathedral (Duomo), Milan, Italy លេខ ២០ Basilica of the Sagrada Familia, Barcelona, Spain លេខ២១ Golden Gate Bridge, San Francisco, California លេខ២២ Cristo Redentor (Statue of Christ the Redeemer), Rio de Janeiro, Brazil លេខ ២៣ Teotihuacan World Heritage Site, San Juan Teotihuacan, Mexico លេខ២៤ Golden Temple - Harmandir Sahib, Amritsar, India លេខ២៥ Sydney Opera House ,Sydney, Australia ។



លេខ៦-Angkor- Wat ប្រទេស (Cambodia)



7-Bayon Temple ប្រទេស (Cambodia)



3-Taj-mahal-in-Agra ប្រទេស India

ផ្អែកលើឈ្មោះដែលបានបង្ហាញទាំង២៥នៃតំបន់ដែលមានទេសភាពស្រស់ស្អាតបំផុតខាងលើសង្ឃឹមថា លោកអ្នកមានជម្រើសណាមួយក្នុងចិត្ត និងត្រៀមគម្រោងទៅកាន់តំបន់នោះសម្រាប់វិស្សមកាលរដូវក្តៅរបស់លោកអ្នកតាមការគួរ ៕

តមកទំព័រទី ១៣

## ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម...

ពីឯកអគ្គរាជទូត រដ្ឋទូត និងមន្ត្រីការទូតនានាប្រចាំកម្ពុជា ប៉ុន្តែគ្មានពិធីទទួលមេដឹកនាំក្នុងជួររដ្ឋាភិបាល និងមន្ត្រីផ្សេងៗទៀតទេ"។

ព្រះអង្គម្ចាស់បានមានបន្ទូលថា ចាប់តាំងពីសម្តេចឪបានចូលទិវង្គតនៅខែតុលា ឆ្នាំ២០១២ មកសម្តេចម៉ែឈប់រៀបចំព្រះរាជពិធីចម្រើនព្រះជន្មធំដុំទៀតហើយ។ ព្រះអង្គបានបន្តថា "កន្លងមកសម្តេចឪតែងតែរៀបចំពិធីលាងសាយភោជន៍ជាមួយមន្ត្រីការទូត និងមេដឹកនាំក្នុងជួររដ្ឋាភិបាល ប៉ុន្តែគ្មានតន្ត្រីអឹងកង ឬពិធីលាងសាយភោជន៍ទេ ចាប់តាំងពីសម្តេចឪសោយទិវង្គតមក"។

ទោះជាយ៉ាងណានំខេកប្រាំពីរថ្នាក់ដែលមានរាងដូចស្វេតច្ឆត្រត្រូវបានថ្វាយសម្តេចម៉ែអំឡុងថ្ងៃចម្រើនព្រះជន្មរបស់ព្រះអង្គ ហើយកាលពីយប់មិញមានពិធីអុជកាំជ្រួចនៅទន្លេសាបខាងមុខព្រះបរមរាជវាំង។

ព្រះរាជពិធីនេះគឺជាឱកាសជួបជុំគ្នារបស់សែរាជវង្សជាច្រើនដែលមកពីគ្រប់និន្នាការនយោបាយ រួមមានទាំងព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ដែលទើបបង្កើតគណបក្សសង្គមរាស្ត្ររាជាធិបតេយ្យកាលពីសប្តាហ៍មុន និងព្រះអង្គម្ចាស់ចក្រពង្ស៍ដែលជាអ្នកស្មោះត្រង់នឹងគណបក្សប្រជាជនជាយូរមកហើយផងដែរ។

ទូរទស្សន៍ជាតិបានចាក់បញ្ចាំងខ្សែភាពយន្តដែលព្រះបរមរតនកោដ្ឋសម្តេចឪ និងសម្តេចម៉ែសម្តែងជាតួឯកនៅមុនព្រះរាជពិធីបុណ្យចម្រើនព្រះជន្មកាលពីម្សិលមិញ។

សារថ្វាយព្រះពរពីស្ថាប័ននានារបស់រដ្ឋាភិបាលត្រូវបានចុះផ្សាយព្រោងព្រាតតាមកាសែតក្នុងស្រុក ចំណែកឯទីភ្នាក់ងារសារព័ត៌មានអាកាប៉េរបស់រដ្ឋ ក៏បានចុះផ្សាយសារលិខិតស្រដៀងគ្នាពីមន្ត្រីជាន់ខ្ពស់មួយចំនួនដែលរួមមានទាំងលោក នេត សាវឿន អគ្គស្នងការនគរបាលជាតិ និងលោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃផងដែរ។

លោក ឈិន កេតណា អគ្គលេខាធិការនៃគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិបានមានប្រសាសន៍ថា ព្រះឆាយាលក្ខណ៍របស់សម្តេចម៉ែត្រូវបានដាក់តាំងនៅខាងមុខបណ្តាក្រសួង និងអគារនានារបស់រដ្ឋាភិបាលដើម្បីគោរពដល់ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មរបស់ព្រះអង្គ៕ **សុខុម**






Continued from Page 12

## Palace Birthday Celebration for...

royal family members from across the political spectrum, including Prince Norodom Ranariddh, who earlier this month launched the Community of Royalist People Party, and Prince Norodom Chakrapong, a long-time CPP stalwart.

State-run television station TVK screened movies starring the late King Father and the Queen Mother in the run-up to Wednesday's national holiday.

Blessing messages from various government institutions were printed in local newspapers, while the state-owned AKP news agency ran similar messages from a number of high-ranking officials, including National Police Chief Neth Savoeun and Interior Minister Sar Kheng.

Chhin Ketana, secretary-general of the National Committee for Organizing National and International Festivals, said the Queen Mother's portrait had been displayed in front of ministries and government buildings to honor her birthday.

Continued from Page 12

## Gov't Moves to Assist Workers...

"We are now investigating these cases," he said.

On Tuesday, more than 6,500 migrant workers passed through Poipet, and nearly 7,700 arrived the following day, according to officials at the border checkpoint.

The numbers stand in stark contrast to those provided by the Ministry of Foreign Affairs, which said on Wednesday that 7,507 workers arrived between June 1 and Monday.

An additional 600 workers arrived at O'Smach international checkpoint in Oddar Meanchey province, said commune chief Phang Sam Ath. There, too, provincial officials and the Cambodian Red Cross have had to step in to transport workers home.

At Prum international checkpoint in Pailin province, 772 workers returned-a threefold increase from the previous day, said Oum Kakrona, a border checkpoint police chief.

Another 760 migrant workers arrived at the Phnom Dey international checkpoint in Battambang province, bringing the three-day total to more than 3,000, according to Colonel Chhun Lon, chief of the border liaison office.

"According to the migrant workers, they were arrested by Thai soldiers because of martial law," he said. "[The junta] has ordered all business owners to stop using illegal migrant workers; so our migrant workers have no job to do and they were arrested by Thai soldiers and sent to the military base before being deported."

An Bunhak, president of Top Manpower and former head of the Association of Cambodian Recruitment Agencies, criticized the sweep, saying it had come without warning and left the government with no time to prepare.

"We are so sorry that the junta did this so quickly…. It is very hard for our government to help them," he said.

But he conceded the roundup wasn't wholly unpopular.

"I met some factory owners who are using legal migrant workers, they supported the junta's action," he said.

Sal Pheap, 19, had been employed at a Thai restaurant for a year when soldiers stormed in earlier this week to round up illegal immigrants.

A fluent Thai speaker, Mr. Pheap eluded them briefly, until they discovered he had no identity card.

"They arrested all of us and pulled us into a very big area-then they forced us to climb up into trucks," he said.

The group was divided into two, and those who had money to bribe the officials were trucked out immediately. The rest languished for at least half a day.

rith@cambodiadaily.com

Continued from page 12

### Return of Workers From Thailand...

She said one man died at the scene and the two women died from their injuries after being taken by ambulance to a Thai hospital.

Ms. Phiey said her husband and some of the other passengers injured in the accident were still in Thailand recovering.

"I appeal to the Cambodian Embassy to help send him back to Cambodia, because he is wounded and he has not yet recovered," she said.

Soum Chankea, an Adhoc monitor based in Banteay Meanchey, said the NGO was sending a team into Thailand to investigate the case.

Six Cambodians died in a separate accident when their van also blew a tire while heading toward the border and rolled over.

The Thai junta has admitted to clamping down on workers who are in the country illegally but denied having any policy to drive Cambodian migrants out of Thailand.

After a meeting in Bangkok on Tuesday between the Thai foreign minister and Cambodia's ambassador to Thailand, the Thai government said it was welcoming Cambodia's migrant workers back, so long as they had the proper paperwork, according to reports in Thai media.

Despite the fears that made them flee, returning workers say they hope to head back to Thailand-where they can find more work at better wages-as soon as possible.

# CLASSIFIED ADS





រឿងរាមកេរ្តិ៍ ដោយសាគូ សាមុត
តម្លៃ $10




របាំបុរាណខ្មែរ ដោយសាគូ សាមុត
តម្លៃ $10




រឿងរាមកេរ្តិ៍ ដោយសាគូ សាមុត
តម្លៃ $10




ក្រុងភ្នំពេញមុនឆ្នាំ១៩៥៤
តម្លៃ $10




CAMBODGE
តម្លៃ $5




អង្គការជានរណា?
បភាគ តម្លៃ $5/1

| Name | Phone # |
|---|---|
| Shipping Address | Email |
| City, State, Zip | Book Title(s) |

BOOK ORDER FORM

Checks or Money Order Payable to KhmerPost USA, LLC
អាចទិញនៅអាស័យដ្ឋាន៖ 45 Merrimack St., Suite 218A, Lowell, MA 01852

## Your Bussiness

Card is Here for $50/mon

ពាណិជ្ជកម្មរបស់អ្នកនៅទីនេះចំណាយ
ត្រឹមតែ $50 ក្នុង១ខែ




## សិក្សាពីឥស្លាម

**សួរ :** មានចម្ងល់អ្វីទេពីឥស្លាម?

**ឆ្លើយ :** សូមទៅមើលគេហទំព័រ
www.peacetv.tv ឬគេហទំព័រ
មួយទៀត www.gainpeace.com.

Q) Any Questions on Islam?

A) watch www.peacetv.tv
visit www.gainpeace.com.

## ប្រូវីដិនខ្មែរវីដេអូ

មានជួសជុល និងលក់កុន
ចិន-ថៃ-ខ្មែរ-ឥណ្ឌា
គ្រប់ប្រភេទមានចម្រៀងសម័យវីដេអូ
ខារ៉ាអូខេថ្មីៗ

742 Potters Avenue
Providence, RI 02907
ទូរស័ព្ទ : (401) 787 6663

www.vmlaptops.com

## Computer Repair

Repair, Buy, Sale, and Trade

VM LAPTOPS CENTER

VANNAK MOEUN (VICTOR)
President

(401)-314-7777
(513)-518-4938

301 Reservoir Ave Unit 2
Providence, RI 02907

E-mail: van@vmlaptops.com

Fax#: (401)-461-2220

## We Buy Broken Laptops

Free, Free, Free,Free
Computer Diagnostic

VM LAPTOPS CENTER

Laptops Motherboard Replacement
Virus, Spy ware, Ad ware Removal
Laptops DC Jack Replacement
Laptops Screen Replacement

Scan to view our Website!

## Grow your bussiness

Call: **978-677-7092**

ជំនួញ និង ការរកទទួលទានរបស់អ្នកនៅក្រុងឡូវែល នឹងបានជោគជ័យរីតតែប្រសើរ
បើលោកអ្នកហៅមកកាន់ផ្នែកផ្សាយពាណិជ្ជកម្ម របស់ខ្មែរផុសសហរដ្ឋអាមេរិក **978-677-7092**

តមកពីទំព័រទី ៣២ ទេសចរណ៍បន្ទាយសត្វស្លាប នៅតំបន់...

មជ្ឈមណ្ឌលបានកត់ត្រានូវគ្រប់ចំនួនភ្ញៀវដែលទៅកម្សាន្ត ដើម្បីជៀសវាងផលប៉ះពាល់ទៅលើបន្ទាយសត្វស្លាបទឹក។ ចំណូលដែលបានមកពីការលក់សំបុត្រចូលទស្សនាអំណោយសប្បុរសធម៌ និងការលក់ទំនិញផ្សេងៗត្រូវបានយកទៅប្រើប្រាស់ចំណាយលើការគ្រប់គ្រងតំបន់ស្នូល។ ការបង្កើនមុខរបរទ្រទ្រង់ជីវភាពដែលមិនប៉ះពាល់បរិស្ថាន។ ការអប់រំបរិស្ថានដល់សិស្សសាលាក្នុងសហគមន៍។ ការថែរក្សា និងគ្រប់គ្រងមជ្ឈមណ្ឌល។ ការឧបត្ថម្ភការអភិវឌ្ឍសហគមន៍មានភូមិបណ្តែតទឹកចំនួន៥ ស្ថិតនៅជាប់និងតំបន់ស្នូលព្រែកទាល់។

ទោះជាយ៉ាងនេះក្តីក្រុមមន្ត្រីបរិស្ថានបានលើកឡើងថា មន្ត្រីឧទ្យានុរក្ស ដែលកំពុងបម្រើការការពារបន្ទាយសត្វស្លាបទឹកនោះបច្ចុប្បន្នមានចំនួន៣២នាក់ ពួកគេបានផ្លាស់ប្តូរវេនយាមគ្នាជាប្រចាំនៅបន្ទាយសត្វស្លាប។ ប៉ុន្តែចំនួននេះនៅពុំទាន់គ្រប់គ្រាន់សម្រាប់តម្រូវការការពារបន្ទាយសត្វស្លាបទឹកដ៏កម្រចង់ផុតពូជដែលកំពុងរស់នៅលើផ្ទៃដីព្រៃទំហំជាងពីរម៉ឺនហិកតានោះបានទេ។

បញ្ហានេះ ធ្វើឱ្យគេមានក្តីបារម្ភថា ប្រភេទសត្វស្លាបទឹកដែលកំពុងរស់នៅផ្តុំគ្នានៅតំបន់ស្នូលព្រែកទាល់នោះ នៅតែអាចទទួលរងគ្រោះ ដោយគេជឿថា ក្រុមមនុស្សនៅតែអាចលបលួចចូលទៅយកពងរបស់វានិងបាញ់សម្លាប់យកមកទទួលទានថែមទៀត៕


# Night Time Duct Cleaners Wanted

Large established duct cleaning company is looking for hardworking technicians to perform kitchen grease exhaust cleaning, Hvac cleaning, mold remediation, and fire&water cleanup. $12-$20 per hour depending on experience. Will train the right person.

Must have valid drivers license. We provide health, 401k, vacation, holidays, and OT. Room for advancement. $1,000.00 Bonus for city of Boston and State certified cleaners. **Call 781.356.8244**

# ដំណឹងជ្រើសរើសបុគ្គលិក

## អ្នកសម្អាតបំពង់លូ ពេលយប់

យើងខ្ញុំជាក្រុមហ៊ុនខ្នាតធំ ផ្នែកសម្អាតលូ កំពុងត្រូវការជ្រើសរើសអ្នកបច្ចេកទេសឧស្សាហ៍ព្យាយាមធ្វើការ ដើម្បីធ្វើការខាងសម្អាតផ្ទះបាយជម្រះដោយវ៉ាក់ (Hvac) សម្អាតកន្លែងដក់មានស្នាមជ្រាប និងមានសម្អាតប្រដាប់ផ្តល់សញ្ញាអគ្គីភ័យ និងប្រព័ន្ធទឹកផងដែរ។ ប្រាក់ខែធ្វើការងារផ្តល់ជូនគិតជាម៉ោង$១២/ម៉ោងទៅ $២០/ម៉ោង អាស្រ័យទៅលើបទពិសោធន៍។ យើងខ្ញុំនឹងបង្ហាត់បង្រៀនបន្ថែម។

ត្រូវមានប័ណ្ណបើកបរ មានសុពលភាព។ យើងខ្ញុំផ្តល់នូវតម្លៃតបស្នងមានសុខភាព ៤០១ពាន់
វិស្សមកាលថ្ងៃសម្រាក និងម៉ោងបន្ថែម និងផ្តល់លុយបន្ថែម$១,000.00
សម្រាប់អ្នកដែលមានសញ្ញាប័ត្រផ្នែកនេះពីបសស្តុន និងពីរដ្ឋ។
សូមទូរស័ព្ទមក **781.356.8244**

# MORTGAGEE'S SALE OF REAL ESTATE AT PUBLIC AUCTION

Tuesday, June 24, 2014 at 10:00 am

**Lowell - Commercial Store/Res.**

**. 168 Liberty Street & 649 School Street** . 7,213 Sf Lot
**(aka 641-643 School Street)** 4,991 Sf Gr Living Area

**. Multi-tenanted**

**TERMS: $10,000.00** cash or certified check at the time and place of the sale. The balance to be paid within thirty (30) days at the law offices of Attorney for the Mortgagee.

*Auctioneer makes no representations as to the accuracy of the information contained herein*

**THE JUMPP COMPANY, AUCTIONEER**
**CHELMSFORD (978) 250-1540 Mass License #711**
**www.jumppcompany.com**


# NOTICE OF PUBLIC MEETING

The Northern Middlesex Metropolitan Planning Organization (NMMPO) will meet Tuesday June 24th, 2014 at 2:00 P.M. Updated versions of the FFY 2015-2018 TIP and FFY 2015 Unified Planning Work Program (UPWP) will be presented and a vote will be taken to endorse. In addition, the NMMPO will be provided a draft Title VI document to discuss and review. The NMMPO meeting will be held at the Northern Middlesex Council of Governments office, 40 Church Street, Suite 200, Lowell, MA. Please note that the TIP contains the program of projects for the Lowell Regional Transit Authority (LRTA). The MPO's public participation process satisfies the LRTA's public participation requirements for the program of projects.

Notice: This location is accessible to people with disabilities and is near public transportation. NMCOG offers secure bicycle parking on the second floor. The NMMPO provides reasonable accommodations and/or language assistance free of charge upon request (including but not limited to interpreters in American Sign Language and languages other than English, open or closed captioning for videos, assistive listening devices and alternate material formats), as available. For assistance, please contact Justin Howard at (978) 454-8021, ext 121 or at jhoward@nmcog.org . Requests should be made as soon as possible for services requiring advanced arrangements, including sign-language, CART or language translation or interpretation.

# សេចក្តីជូនដំណឹង កិច្ចប្រជុំជាសាធារណៈ

អង្គការរៀបចំគម្រោងនៃក្រុងធំៗក្នុងខ័ណ្ឌមីដដលស៊ិកខាងជើង ហៅកាត់ថា អិន អឹម អឹម ភី អូ (NMMPO) នឹងបើកកិច្ចប្រជុំជាសាធារណៈមួយនៅថ្ងៃអង្គារ ទី២៤ ខែមិថុនា ឆ្នាំ២០១៤ នៅវេលាម៉ោង ២ រសៀល។ កិច្ចប្រជុំនេះ ធ្វើឡើងដើម្បីបង្ហាញសាធារណជនឱ្យបានជ្រាបពីព័ត៌មានថ្មីៗនៃកម្មវិធីអភិវឌ្ឍគម្រោងសម្រាប់មធ្យោបាយធ្វើដំណើរសាធារណៈហៅកាត់ថា (TIP) សម្រាប់ឆ្នាំ ២០១៥-២០១៨ និងសេចក្តីព្រាងនៃគម្រោងបញ្ចូលកម្មវិធីការងាររួមគ្នាសម្រាប់ឆ្នាំ២០១៥ ហៅកាត់ថា (UPWP) ឬ (យូ ភី ដាប់បលយូ ភី)។

កិច្ចប្រជុំខាងលើនឹងប្រព្រឹត្តទៅនៅការិយាល័យរដ្ឋាភិបាលក្នុងខណ្ឌមីដដលសិកខាងជើង ផ្លូវ៤០ ឆឺចស្រ៊ីតស្វីតលេខ២០០ ក្រុងឡូវែល រដ្ឋម៉ាសាឈូសេត (40 Church Street, Suite 200, Lowell, MA)។ សូមចំណាំថា កម្មវិធីធីប (TIP) មានគម្រោងដែលទាក់ទៅនឹងសេវាមធ្យោបាយធ្វើដំណើរសាធរណៈនៃមន្ទីរទូរគមនាគមន៍ប្រចាំតំបន់ឡូវែល ហៅកាត់ថា អិល អ័រ ធី អេ (LRTA)។ ការចូលរួមជាសាធារណៈនៃកិច្ចប្រជុំខាងលើជាបច្ច័យជំរុញគម្រោងមធ្យោបាយធ្វើដំណើរសាធារណៈឱ្យបានដល់ការពេញចិត្តពីកម្មវិធីនេះ។

**ចំណាំ:** ទីកន្លែងនៃកិច្ចប្រជុំខាងលើផ្តល់ដល់អ្នកចូលរួមដែលមិនចេះភាសាអង់គ្លេស និងជនពិការនូវទីតាំងងាយទៅដល់ ព្រោះនៅក្បែរមធ្យោបាយធ្វើដំណើរសាធារណៈ។ អិន អឹម ស៊ី អូ ជី ផ្តល់ជូននូវការចតទោចក្រយាន្តនៅជាន់ទីពីរប្រកបដោយសុវត្ថិភាព។ លោកអ្នកអាចទទួលបានទីកន្លែងស្នាក់នៅ និងការបកប្រែភាសាដោយគិតថ្លៃ (ទាំងភាសាកាយវិកា និងសម្លេងការថតរូប និងវីដេអូ ប្រដាប់ជំនួយសម្លេងស្តាប់ការប្រជុំ និងឧបករណ៍ជំនួយក្នុងទម្រង់ផ្សេងៗទៀត) តាមរយៈការស្នើរសុំពេលចូលរួមកិច្ចប្រជុំខាងលើ។

សម្រាប់ការស្នើរសុំទីកន្លែងស្នាក់នៅ និងសេវាបកប្រែភាសាពេលចូលរួមកិច្ចប្រជុំ សូមទាក់ទង ចឹសស្ទីន ហូវឹដ តាមរយៈលេខទូរស័ព្ទ ៩៧៨-៤៥៤-៨០២១ បន្តចុចលេខ១២១ ឬអាចអ៊ីម៉ែល jhoward@nmcog.org . ការស្នើរសុំជំនួយបកប្រែភាសាកាយវិកា និងភាសានិយាយគួរតែធ្វើឡើងឱ្យលឿនបំផុតតាមដែលអាចធ្វើបាន ដើម្បីឱ្យបុគ្គលិកដែលទទួលបន្ទុកអាចរៀបចំឱ្យបានទាន់ពេលវេលា៕

# ខ្មែរអ្នកជាតិនិយម

តពីលេខមុន

ដំឡើងពន្ធអាករទាំងឡាយផ្សេងៗផងទៀត។ បន្ទាប់ពីបានដាក់សេចក្តីស្នើនេះទៅរដ្ឋសភារួចហើយ ស្តេច សីហនុ បានចេញដំណើរទៅខេត្តសៀមរាបដឹកនាំសហប្រតិបត្តិការសឹកមួយដែលមានកងកម្លាំងចំនួន៣ កងវរសេនាតូច គឺងវរសេនាតូចឆ័ត្រយោង, កងវរសេនាតូចទី៣ និងកងឯកភាពរបស់ ដាប ឈួន ក្នុងគោលដៅរុករកចាប់លោក សឺន ង៉ុកថាន់។

នៅពេលនោះក្របខណ្ឌជំនាន់ទី១ បានប្រយុទ្ធទប់ទល់នឹងកងយោធារបស់ស្តេច សីហនុ រហូតដល់ទ្រង់ដកទ័ពឈមធ្វើសហប្រតិបត្តិការទៅវិញ។ ក្រោយពីដកទ័ពថយបានចំនួនពីរបីថ្ងៃស្តេច សីហនុ បានស្នើសុំឱ្យបារាំងទៅទម្លាក់គ្រាប់បែកលើជំរុំអូរស្វាច់ ដែលបណ្តាលឱ្យឆេះរោងស្បៀងមួយតែពុំបានបណ្តាលឱ្យខូចខាតដល់ជីវិតមនុស្សទេ។

លុះត្រឡប់មកដល់ភ្នំពេញវិញ ស្តេច សីហនុ បានដឹងថា រដ្ឋសភាបានទាត់ចោលទាំងស្រុងនូវសំណើរទាំងអម្បាម៉ានរបស់ទ្រង់។ មិនតែប៉ុណ្ណោះមានពួករដ្ឋមន្ត្រីដែលភាគច្រើនជាពូជស្តេចបានទូលថា ពួកគេប្រុងក្បត់ ដើម្បីរំលាយរាជាធិបតេយ្យ។ ការរំជើបរំជួលនេះបានរាលដាលរហូតទៅពួកសិស្សវិទ្យាល័យម្តងទៀត ហើយក៏បាននាំគ្នាធ្វើកូដកម្មអស់រយៈពេលជាង១ខែ ។ លើកនេះ នរោត្តម សីហនុ បានចោទប្រកាន់គណបក្សប្រជាធិបតេយ្យថា :

**ទី១** ពួកប្រជាធិបតេយ្យខ្លះមានការទាក់ទងជាមួយពួកយៀកមិញ។




**ទី២** គណៈកម្មាធិការនាយកនៃគណបក្សប្រជាធិបតេយ្យបានលបបង្កើតឃាតកម្មផ្សេងៗ (ក្នុងរឿងនេះ តំណាងរាស្ត្រគណបក្សប្រជាធិបតេយ្យចំនួន៩រូបបានត្រូវចាប់យកទៅឃុំឃាំង)។

**ទី៣** គណៈបក្សប្រជាធិតេយ្យបានប្រើហិបការទូតនៅបាងកក ធ្វើជាការទាក់ទងជាមួយលោក សឺន ង៉ុកថាន់ នៅឯភ្នំដងរែក។

ថ្ងៃទី១៣ មករា ១៩៥៣ ស្តេច សីហនុ បានប្រើជាលើកទី២ នូវមាត្រាទី២១ នៃរដ្ឋនុញ្ញ ដើម្បីរំលាយរដ្ឋសភា ហើយថែមទាំងបានចេញរាជក្រឹត្យមួយប្រកាសប្រើច្បាប់អាជ្ញាសឹកផងទៀត។

ការចចេសចង់យកឈ្នះចាញ់រវាងក្រុមនយោបាយទាំងពីរ គឺក្រុមរាជនិយម និងក្រុមប្រជាធិបតេយ្យដោយពុំបាននឹកគិតដល់ផលវិបាកដ៏អាក្រក់មកលើប្រជាជាតិនោះបានធ្វើឱ្យប្រទេសជាសត្រូវរបស់ជាតិខ្មែរកាន់តែបានផលចំណេញខ្លាំងឡើងទៀត។ ពួករាជនិយមដែលធ្លាប់តែបានរស់នៅថ្កុំថ្កើងរុងរឿងបានបុណ្យស័ក្តិខ្ពង់ខ្ពស់ដោយសាបារមីរាជបល្ល័ង្កតាំងពីបុរាណកាលមកហើយដែលទុករាស្ត្រប្រជាជាទាសៈទាសីនោះរមែងរិះរកគ្រប់កលល្បិចគ្រប់មធ្យោបាយ ដើម្បីការពាររាជបល្ល័ង្កកុំឱ្យរលំ និងរក្សារាជនិយមកុំឱ្យរលាយ។ ឯក្រុមប្រជាធិបតេយ្យនិយមវិញក៏មានគំនិតអាក្រក់គិតតែរកប្រយោជន៍ផ្ទាល់ខ្លួននិងបក្សពួកខ្លួនដូចជា ពួករាជនិយមដែរ តែអាងទៅលើចំណេះវិជ្ជា និងសញ្ញាប័ត្ររបស់ខ្លួនតែឥតមានគំនិតដល់វាសនាសង្គមជាតិខ្មែរសម័យនោះឡើយ ។

ក្រុមទាំងពីរនេះ បានភ័ន្តច្រឡំយ៉ាងធំក្នុងដំណើរការនយោបាយរបស់ខ្លួន។ នេះជាកំហុសទី១ ហើយនេះជាការពិតឥតប្រកែតបានដែលអ្នកដឹកនាំនយោបាយខ្មែរត្រូវតែទទួលថា នៅក្នុងប្រទេសទន់ខ្សោយមួយដែលមានប្រជាពលរដ្ឋខ្លះខ្វះការសិក្សាតាំងពីដីដូនជីតារបស់ខ្លួនរៀងរហូតមកនោះបានស្គាល់តែរបបគ្រប់គ្រងរាជនិយមផ្តាច់ការធ្លាប់តែគោរពឱនលំទោនយកស្តេចជាម្ចាស់ជីវិតលំត្បូង(ក្បាលធរបស់ខ្លួនជាម្ចាស់ផែនដីស្រឡាញ់ស្តេចលើសជីវិតខ្លួនសុខចិត្តទូលល្អងធូលីព្រះបាទព្រះរាជាទូលព្រះបង្គន់លុតជង្គង់ឱនសិរសាក្រាបទៀបព្រះរាជានាំគ្នាសន្មតទុកក្សត្រីយ៍គ្រងរាជជាទេវតារបស់មនុស្ស។ អ្នកណាពូកែអែបអបចេះលុតក្រាបចេះដើរដូចទាចេះផ្សៀងកព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យលើកស្ទួយអ្នកនោះឱ្យមានបុណ្យស័ក្តិមានឋានៈខ្ពស់ត្រដែត។ អ្នកណាមួយហ៊ានរឹងទទឹងនឹងព្រះរាជឱង្ការអ្នកនោះនឹងត្រូវទទួលទោសទណ្ឌកម្មរហូតបាត់បង់ជីវិតក៏មាន។ ម្យ៉ាងទៀតជំនាន់បារាំងជិះជាន់ខ្មែរនោះ ហៅថា "លទ្ធិប្រជាធិបតេយ្យ" ឬអ្វីហៅថា "ឯករាជ្យ" ។

ពួកប្រជាធិបតេយ្យសម័យនោះ អួងអាងថា ជ័យជំនះទាំងប៉ុន្មានរបស់ពួកគេ គឺបានមកដោយការដឹកនាំរបស់បញ្ញវន្តថ្មីៗរបស់ពួកគេ ។ នេះជាការភ័ន្តច្រឡំទី២ ។ តាមពិតជ័យជំនះរបស់គណបក្សប្រជាធិបតេយ្យសម័យនោះ គឺជាជ័យជំនះនយោបាយដែលជាចំណងប្រជាពលរដ្ឋខ្មែរភាគច្រើន ជាលំអានឯករាជ្យដែលក្រុមអ្នកជាតិនិយមលោក សឺន ង៉ុកថាន់ បានធ្វើពលិកម្មបំរើជាតិ រហូតដល់ជាប់គុកច្រវាក់ បាត់បង់ជីវិតក៏មាន និរទ្ទេសខ្លួ ឬរត់ចូលព្រៃចោលគ្រួសារដើម្បីតស៊ូយកឯករាជ្យពីបារាំងក៏មាន ។

នៅក្នុងរដ្ឋធម្មនុញ្ញខ្មែរ រដ្ឋសភាជានីតិបញ្ញត្តិគឺជាអង្គការធំមួយរបស់រដ្ឋ ។ អ្នកដឹកនាំគណបក្សប្រជាធិបតេយ្យសម័យនោះ ពុំបានទុករដ្ឋសភាជាអង្គការធំសម្រេចកិច្ចការធំៗរបស់ប្រទេសជាតិទេ វាទៅជាគណកម្មាធិការនាយកនៃគណ-បក្សឯករាជ្យឯណោះទៅវិញ ដែលជាអ្នកសម្រេចកិច្ចការធំៗរបស់ប្រទេស ។ គណៈកម្មាធិការនាយកនេះ ជាអង្គការអាថិកំបាំងឥតទទួលខុសត្រូវនៅចំពោះមុខរដ្ឋអ្នកណាទេ ប៉ុន្តែត្រួតត្រាលើសេចក្តីសម្រេចចិត្តរបស់គណៈរដ្ឋមន្ត្រីទាំងស្រុង ព្រមទាំងលើសកម្មភាពនៃអ្នករាជការជាន់ខ្ពស់ ដូចជាអង្គការកុម្មុយនីស្ត ប៉ុល ពត ដែរ ។ ពួក

តទៅលេខក្រោយ

ប្រជាធិនតេយ្យសម័យនោះដឹកនាំប្រទេសរ

## តមកទំព័រទី ១៨ ដេកមិនលក់ អាចប៉ះពាល់ សុខភាព...

លោកអ្នកត្រូវរកមូលហេតុពិតប្រាកដដែលបណ្តាលឱ្យដេកមិនលក់ ដើម្បីដំណោះស្រាយទាន់ពេលវេលានិងទៅតាមរឿងនីមួយៗ។ លោកអ្នកគួរតែដោះស្រាយដោយសន្តិវិធីរម្ងាប់អារម្មណ៍ដោយខ្លួនឯង ហើយព្យាយាមសម្ងំដេកមិនត្រូវគិតពីរឿងអ្វីទាំងអស់ ដើម្បីជួយឱ្យមានអារម្មណ៍ឱ្យជ្រះថ្លាពេលក្រោកពីដំណេក។

លោកអ្នកអាចទៅពិភាក្សាជាមួយដៃគូដែលអ្នកទុកចិត្ត ដូចជាមិត្តភក្តិបងប្អូនគូសង្សារជាដើម។ តែបើបញ្ហាសំខាន់មិនអាចដោះស្រាយបាន គួរទៅជួបអ្នកជំនាញដើម្បីផ្តល់ជាយោបល់និងអាចជួយសម្រួលឱ្យដេកលក់។

### ផលវិបាកនៅពេលដេកមិនលក់

ដេកមិនលក់មានផលវិបាកច្រើនចំពោះរាងកាយ ដូចជាស្រកទម្ងន់លឿនស្លេកស្លាំងទាំងមុខមាត់ ឬរូបរាងកាយមិនស្រស់ថ្លាជាដើម។ មិនត្រឹមតែប៉ុណ្ណោះទេ ធ្វើឱ្យរង្វង់ភ្នែកជាំខ្មៅមួយរយៈពេល ឬអាចជារៀងរហូតក៏មាន។ ម្យ៉ាងទៀតជម្ងឺអាចមកបៀតបៀនបានយ៉ាងឆាប់រហ័សព្រោះសុខភាពចុះទ្រុឌទ្រោម។ ដេកមិនលក់ជាបញ្ហាមួយដែលកើតចំពោះលោកអ្នកគ្រប់វ័យដោយសារការគិតដែលមានលក្ខណៈផ្សេងៗពីគ្នា។

### វិធីទប់ស្កាត់នៅពេលដេកមិនលក់

លោកអ្នកមិនគួរគិតច្រើនពេកទេនៅពេលដេកមិនលក់ និងសូមកុំធ្វើសកម្មភាពដែលនាំឱ្យគិតដល់រឿងរ៉ាវដែលអាក្រក់ ចំពោះខ្លួនឯង។ ដើម្បីទប់ស្កាត់បញ្ហាទាំងនោះលោកអ្នកដែលដេកមិនលក់គួរប្រតិបត្តិដូចខាងក្រោមទើបអាចប្រសើរជាងមុន ហើយជួនកាលអាចបំភ្លេចបញ្ហាគ្រប់យ៉ាង និងជួយឱ្យដេកលក់ស្រួលទៀតផង។

### មិនត្រូវទទួលទានអាហារច្រើនហួសកំណត់ឡើយ

ព្យាយាមរម្ងាប់អារម្មណ៍ចំពោះរឿងរ៉ាវទាំងឡាយដែលពាក់ព័ន្ធនឹងខ្លួនឯង ត្រូវគិតមួយរឿងៗឱ្យដាច់ស្រឡះពីគ្នាមិនត្រូវគិតច្របូកច្របល់នូវបញ្ហាទាំងអស់ទេ ត្រូវលួងខ្លួនឯងថាអ្វីៗក៏អាចដោះស្រាយបានដែរ ឱ្យតែយើងហ៊ានប្រឈមមុខនឹងការពិត ប្រសិនបើអាចនិយាយពីរឿងរបស់ខ្លួនបាន គួរតែនិយាយប្រាប់អ្នកណាម្នាក់



ដែលអ្នកទុកចិត្តបំផុត ។

បើលោកអ្នកគិតថាខ្លួនមានអាការខុសប្រក្រតី គប្បីលោកអ្នកត្រូវទៅពិភាក្សាជាមួយគ្រូពេទ្យជំនាញ ដើម្បីរកវិធីទប់ស្កាត់ឱ្យទាន់ពេលវេលា។

លោកអ្នកត្រូវគិតថាការបាក់ទឹកចិត្តអ្នកណាក៏ជួបប្រទះដែរ មិនអាចចៀសផុតបានទេ ហើយការបាក់ទឹកចិត្តទាំងនោះក៏ជាចំណែកមួយដ៏ធំធ្វើឱ្យលោកអ្នកដេកមិនលក់។ អ្វីដែលសំខាន់លោកអ្នកត្រូវជួយខ្លួនឯងឱ្យបានចំពោះរឿងដែលកើតឡើងជុំវិញខ្លួន៕

# គុណប្រយោជន៍នៃផ្លែឈើ ក្នុងការព្យាបាលជំងឺ



**មានផ្លែឈើជាច្រើនណាស់ដែលអាចជួយការពារបានដល់សុខភាពរបស់មនុស្សលោក ។ ពីមួយថ្ងៃទៅមួយថ្ងៃការរកឃើញថ្មីជាបន្ថែមទៀត ពីគុណប្រយោជន៍នៃផ្លែរុក្ខជាតិសុទ្ធតែអាចជួយឱ្យមនុស្សយើងរស់នៅក្នុងជីវិតប្រកបដោយភាពមាំមួនដោយពុំចាំបាច់ព្រួយបារម្ភ និងបញ្ហាជំងឺតម្កាត់អ្វីនោះឡើយ ។**

### ផ្លែសារីជួយបំបាត់ការឈឺចុកចាប់

បើទោះបីជាបរិភោគផ្លែសារីស្រស់ក្តី ឬត្រូវបានច្នៃយ៉ាងណាក៏ដោយ ក៏រសជាតិនៃផ្លែសារីជួយបំបាត់បានរាល់ការឈឺចុកចាប់ ។ ប្រការដែលចាប់អារម្មណ៍នោះ ដោយសារតែផ្លែឈើនេះជួយកម្ចាត់បានយ៉ាងមានប្រសិទ្ធភាពរាល់ករណីឈឺសន្លាក់ឆ្អឹង ឬការឈឺចាប់ដោយសារជំងឺមហារីក ។

### ផ្លែក្រូចថ្លុងជួយកាត់បន្ថយជាតិខ្លាញ់កូឡេស្តេរ៉ូល

ផ្លែក្រូចថ្លុងសម្បូរទៅដោយជីវជាតិវីតាមីនសេ ។ ប៉ុន្តែនៅក្នុងផ្លែឈើប្រភេទនេះ ក៏មានផ្ទុកទៅដោយសារធាតុវេជ្ជសាស្ត្រដទៃទៀតយ៉ាងច្រើនដែលមានប្រយោជន៍ខ្លាំងណាស់ ពិសេសគឺមានសារធាតុម្យ៉ាងមានឈ្មោះហៅថា Pectin ដែលជាជាតិសរសៃជួយកាត់បន្ថយបាននូវសារជាតិកូឡេស្តេរ៉ូល ។

### ផ្លែឪឡឹកជួយប្រឆាំងនឹងឱកាសកើតមហារីក

ជាប្រភេទផ្លែឈើដែលមានគុណភាពខ្ពស់មានប្រសិទ្ធភាពយ៉ាងក្រៃលែងក្នុងការទប់ស្កាត់បានពីការកើតជំងឺមហារីក ។ ផ្លែឪឡឹកមានរសជាតិទឹកនៅក្នុងផ្លែរហូតដល់ទៅ៩២% ។ ប៉ុន្តែផ្លែឈើឪឡឹកសម្បូរទៅដោយសារធាតុដ៏មានតម្លៃខ្ពស់បំផុតសម្រាប់សុខភាពរបស់មនុស្សយើង ។ ការច្របាច់កៀបយកទឹកពីផ្លែឪឡឹកតែមួយផ្លែនោះ គេនឹងទទួលបានជីវជាតិវីតាមីនសេ វីតាមីនអា និងជាតិប៉ូតាស្យូមបានយ៉ាងគ្រប់គ្រាន់ ។ លើសពីនេះទៅទៀត នៅក្នុងផ្លែឪឡឹកមានទាំងជាតិអាស៊ីតអាមីន (Acid Amin) មានឈ្មោះហៅថា Citruline ដែលជួយសម្រួលដល់ការបន្ទោបង់បានយ៉ាងងាយស្រួលបំផុត ។

ក្រុមអ្នកវិទ្យាសាស្ត្រសុទ្ធតែមានជំនឿថា សារជាតិការ៉ូទីន (Carotenoid) ដែលមាននៅក្នុងផ្លែឪឡឹកនោះ ពិតជាមានប្រសិទ្ធភាពក្នុងការទប់ស្កាត់ប្រឆាំង និងជំងឺមហារីកសុដន់ ព្រមទាំងបញ្ហាជំងឺមហារីកទាំងឡាយនៅក្នុងប្រព័ន្ធរំលាយអាហារបានយ៉ាងល្អថែមទៀតផង ៕

**KhmerPost USA, LLC**
**សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក**
អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us
តាមដានយើងនៅទំព័រហ្វេសប៊ុក Like us at: www.facebook.com/KhmerPostUSA
**ផ្សាយពាណិជ្ជកម្ម Advertising**
អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office) |
អ៊ីម៉ែលsobenpin@khmerpost.us
**អ្នកនិពន្ធ Editorials**
និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*
(978) 942 - 1641 | rogerpin@khmerpost.us

អ្នកនិពន្ធកិត្តិយស **Contributed Writers:**
Kim Phien, Kim Sos, Mao Chan Somnom, Mam Yin,
Richard Howe Esq.
**ច្នៃសោភ័ណភាពកាសែត Design Artist**
Heng Chhunleng
**ជំនួយការរដ្ឋបាល Administrative Assistant**
Sokha Lim

KhmerPost USA, LLC is an independent newspaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local community, and national news; and give an insight into Cambodian & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Massachusetts serving Greater Lowell, Lynn, Revere, MA, Providence, RI, CT, NY, NJ, and Philadelphia, PA.

Mail subscription is available within the U.S. & Canada at $60.00 or 70 Euros in Europe per year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009



**ហាងខ្មែរជួសជុលរថយន្ត**

**បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ**

**Rathe´s Auto Service**

State and Emission
Inspaction General
Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងក៏រិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬ ធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376

# កម្ចាត់មុន និងជួយឱ្យស្បែកមុខតឹងណែន



មុននៅលើស្បែក គឺជាបញ្ហាមួយដែលមនុស្សគ្រប់រូបតែងជួបប្រទះដោយសារជាតិខ្លាញ់លើស្បែកមុខកើនឡើង ដែលបង្កឱ្យកើត មានមុននៅកន្លែងមួយចំនួនដូចជា : ស្បែក មុខ ក ស្មា ក្បាល និងស្បែកខ្នង ។ ដូច្នេះខាងក្រោមនេះ គឺជាវិធីសាស្ត្រព្យាបាលមុនដ៏ឆាប់រហ័សដោយធម្មជាតិ ។

**១. ក្រូចឆ្មារ :** គឺជាឱសថព្យាបាលដែលអាចកម្ចាត់មុន និងមុនអង្គាមបានយ៉ាងឆាប់រហ័ស ពីព្រោះទឹកក្រូចឆ្មារសម្បូរទៅដោយវីតាមីន C ដែលជួយថែរក្សាស្បែកមុខឱ្យស.ភ្លឺរលោង តឹងណែនដោយធម្មជាតិ ។ មានវិធីពីរយ៉ាងដើម្បីកម្ចាត់មុននៅលើស្បែកមុខរបស់អ្នកដោយប្រើទឹកក្រូចឆ្មារធម្មជាតិ ។

**វិធីទី១ :** យកកំណាត់ស្អាតមួយ ឬសំឡីជ្រលក់ទៅក្នុងទឹកក្រូចឆ្មារបន្ទាប់មកលាបថ្នមៗនៅលើកន្លែងកើតមុន មុនពេលចូលគេង ។

**វិធីទី២ :** អ្នកអាចយកទឹកក្រូចឆ្មារមួយ ស្លាបព្រាបាយ លាយជាមួយម្សៅCinnamon Powder មួយស្លាបព្រាកាហ្វេ បន្ទាប់មកលាប នៅលើស្បែកមុខ ដែលកើតមុន ទុកមួយយប់ រួចលាងសម្អាតចេញដោយទឹកក្តៅឧណ្ហៗ ។ ប៉ុន្តែវិធីនេះ គឺមិនអាចប្រើបានចំពោះអ្នកមានស្បែកមុខប្រតិកម្មនោះទេ ។

**២. ទឹកឃ្មុំ :** គឺជាឱសថធម្មជាតិមួយសម្រាប់ផ្សះជំងឺ ដែលអាចជួយព្យាបាលមុខកើតមុនឱ្យជាសះស្បើយបានយ៉ាងឆាប់រហ័ស និងជួយការពារការឆ្លងមេរោគលើស្បែកកើតមុនទុករយៈពេល៣០នាទី ។ បន្ទាប់មកលាងសម្អាតមុខឱ្យស្អាតជាមួយនឹងទឹកក្តៅឧណ្ហៗជម្រើសមួយទៀត លាយទឹកឃ្មុំជាមួយនឹងម្សៅ Cinnamon កូរចូលគ្នាឱ្យសព្វ ដើម្បីធ្វើជាម៉ាស់បន្ទាប់មកលាបនៅលើមុនមុនពេលចូលគេងរួចលាងសម្អាតស្បែកមុខដោយទឹកត្រជាក់ជាការស្រេច ៕

LOWELL ELDER CARE
978-596-1111

មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

345 Chelmsford St. Lowell, MA 01851/ – www.lowelleldercare.com

អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ៏កក់ក្តៅមួយ ដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។

មណ្ឌលផ្តល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

Our Services

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips





សូមហៅលេខទូរស័ព្ទ (978) 596-1111

# ហាងជួសជុលរថយន្តឡូវែល

## Lowell Automatic Transmission









**Spring Special $19.95**

ពិសេសសម្រាប់រដូវផ្ការីក

- ថ្មអាគុយ/តេស្តប្រព័ន្ធបញ្ឆេះភ្លើង
- ពិនិត្យអង់ទីហ្វ្រីស
- ពិនិត្យហ្វ្រាំងទាំងមូល
- ជម្រះប្រេងគ្រប់ប្រភេទ
- បង្វិលកង់រថយន្តឲ្យស្មើ

**ពិនិត្យ**

- បន្ទះជូតកញ្ចក់ឡាន
- ប្រព័ន្ធកំដៅ/ត្រជាក់
- ប៊ែលធ៍ / ហូស (Belts & Hoses)
- អំពូលភ្លើងខាងក្រៅទាំងអស់

**ដូរប្រេងតម្លៃត្រឹមតែបន្ថែម $9.95**

- **កែកុងអំពូលភ្លើងខាងមុខ**
  តម្លៃ. $79.95
  បញ្ចុះតម្លៃ $49.95
- **ប្រភេទអំពូលបំភ្លឺសម្រាប់**
  Vehicle Flush Options
  ▸ Transmission ▸ Power Steering
  ▸ Brake System ▸ Fuel System

202 Chelmsford Street. Lowell, MA 01851

**ប្រព័ន្ធភ្លើង ជួសជុលទូទៅ សំបក និងតួខ្លួនឡាន**

Phone: 978-458-4775|978-453-8621|Fax: 978-454-4599

## ហាងលក់រថយន្តផ្លូវឆេមស្ហ្វត

## Chelmsford Street Auto Sales

Auto Sales

Full & Part Time

Unique opportunity with Fast Growing Auto Sales and Service Used Car Dealership
Looking for a self motivated Auto Sales Person with strong computer skills. Auto Sales Experience a plus, but will train the right person.
Must speak English and khmer.
Benefits include Health and Insurance, Paid Holidays, Paid Vacation, Retirement Plan(Full time).
Fax your resume today to 978-454-4599 or Email to Roger@cstreeauto.com



AccuCare
Home Care Agency
Group Adults Foster Care Program

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## Homecare Agency

Group Adult Foster Care Program (GAFC)
MassHealth

សេវាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្ដានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ



*Compassionate Care & Reliable*
*Professional & Cultural Sensitive*
*Management & Staffs speak Khmer*

កម្មវិធី *Group Adult Foster Care (GAFC)* គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្ដល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្ដង ។

*Accucare Homecare Agency is the perfect solution for seniors and others who are not ready to leave their home for an institutional setting or live with reltives because of illness or chronic conditions. We improve your life by providing one-on-one compassionate senior care in the comfort of your own home.*

**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

*To be eligibled for GAFC you must:*

- -រស់នៅផ្ទះរដ្ឋ *(live in subsidized or public housing)*
- -អាយុ ២២ ឆ្នាំឡើងទៅ *(age 22 years and older)*
- -មាសប៉ៃហិលស្តង់ដា *(eligible for Masshealth Standard)*
- -ត្រូវការជំនួយក្នុងការរស់នៅប្រចាំថ្ងៃយ៉ាងហោចណាស់មួយដូចជា មុជទឹក ស្លៀកពាក់ ពេលប្រើបន្ទប់ទឹក ចំអិនអាហារ ឬ ពេលដើរ *(need daily assistance with one or more personal care tasks such as bathing, dressing, toileting, meal preparation and/or moving)*
- -មានការអនុញ្ញាតពីគ្រូពេទ្យផ្ទាល់ខ្លួនអ្នក *(have physician statement of your condition)*
- -ត្រូវបានវាយតំលៃផ្នែកសុខភាព និងការអនុម័តយល់ព្រមពីកម្មវិធី *(be screened and approved for the program )*

**ផលប្រយោជន៍ទទួលបាន :**

*Benefits you will get:*

- -ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ *(personal care service in your home, up to one hour of service each day)*
- -ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក *(Medication Managemant)*
- -ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីឃើ *(an individual care plan developed by a registered nurse and case manager)*
- -វាយតំលៃលើសេចក្ដីត្រូវការជាប្រចាំជាបន្តបន្ទាប់ *(ongoing monitoring of needs)*
- -សមាជិកអាចទាក់ទងមក ២៤ម៉ោង *(24-hour access to services)*

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:

ឱក តុលាយុត្តិ ឡូវែល
Tolayuth Ok: Lowell
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852



# ជោគជតារាសីលោកអ្នក ទាំង១២ ប្រចាំឆ្នាំរោង

## ឆ្នាំជូត

លោកអ្នកគួរប្រុងប្រយ័ត្នចំពោះការនិយាយស្តីបន្តិច ពីព្រោះអាចនឹងមានគូសត្រូវចាំចាប់ទោសកំហុសមួលបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះរបស់លោកអ្នកឱ្យប្រែក្លាយទៅជាស្មុយអសោចិ៍ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញមានក្រុមមនុស្សតាមឈ្នានីសច្រើន ដូចច្នេះត្រូវប្រយ័ត្នបន្តិចចៀសវាងការបរាជ័យ ។ រីឯបញ្ហាស្នេហាមានភាពចម្រូងចម្រាសដាក់គ្នាបន្តិចបន្តួច ៕

## ឆ្នាំឆ្លូវ

រាល់ការស្មុគស្មាញដែលធ្លាប់កើតមានលើលោកអ្នកក្នុងពេលនេះ នឹងត្រូវអហោសិកម្មទាំងអស់ ហើយទ្រព្យដែលរបូតចេញពីដៃទៅនឹងវិលត្រឡប់មកវិញយ៉ាងគ្រប់គ្រាន់ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ ត្រូវគិតគូរឱ្យបានច្បាស់លាស់មុននឹងដាក់ទុនថ្មីទើបមិនខាតបង់រាល់ការចំណាយទាំងនោះ ។ រីឯបញ្ហាស្នេហាត្រូវចេះពួនជ្រោយចំណងស្នេហាដោយមានភាពផ្អែមល្ហែមទើបជាការប្រសើរ ៕

## ឆ្នាំខាល

លោកអ្នកមានភ័ព្វសំណាងល្អក្នុងការងារទទួលរឿងឡើងតួនាទី ឬប្រាក់បៀវត្សរ៍បន្ថែម ។ ជាងនេះទៀតនោះប្រសិនបើចង់ពឹងពាក់អ្នកមានយសស័ក្តិខ្ពង់ខ្ពស់ក្នុងរឿងអ្វីមួយនឹងបាន ដូចបំណងផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ អាចរកប្រាក់ចំណូលចិញ្ចឹមគ្រួសារបានដោយស្រួលទេ មិនមានអ្វីមករាំងស្ទះឡើយ ។ រីឯបញ្ហាស្នេហាគូស្នេហ៍រមែងចេះអត់ឱនឱ្យគ្នា ៕

## ឆ្នាំថោះ

រាល់កិច្ចការសព្វបែបយ៉ាងលោកអ្នកអាចជួបនឹងបញ្ហាខ្លះៗ នាគ្រាដំបូងប៉ុន្តែក្រោយមកមិនមានអ្វីជាឧបសគ្គរារាំងទៀតឡើយ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ មានការទិញចូលលក់ចេញគ្រាន់ បើអាចរកផលកម្រៃត្រឡប់មកផ្ទះវិញ យ៉ាងត្រជាក់ចិត្ត ។ រីឯបញ្ហាស្នេហាមានភាពផ្អែមល្ហែម និងស្រស់ស្រាយប្រៀប ដូចត្រីក្នុងទឹកនារដូវខែវស្សាដូច្នេះដែរ ៕

## ឆ្នាំរោង

ក្នុងរយៈពេលនេះលោកអ្នកជួបនឹងបញ្ហាខាងផ្លូវចិត្តមិនសូវជាសប្បាយរីករាយប៉ុន្មាននោះទេ តែប្រសិនបើចង់ទទួលផលពីការងារនោះ ចូរធ្វើចិត្តឱ្យត្រជាក់ ទើបបានសម្រេចដូចបំណង ។ បើជាអ្នកប្រកបរបររកស៊ីជួញដូរវិញ គឺមានការប្រទាំងប្រទើសជាមួយអ្នកមានមុខរបរដូចគ្នា ដូច្នេះគួរបើកចិត្តឱ្យទូលាយ ។ រីឯបញ្ហាស្នេហាមានការកាំចិត្ត ព្រោះតែម្នាក់ៗចង់ចាញ់ឈ្នះគ្នានោះឯង ៕

## ឆ្នាំម្សាញ់

នៅក្នុងរយៈពេលនេះ លោកអ្នកទទួលលាភសក្ការៈពីសាច់ញាតិបងប្អូនដែលជិតស្និទ្ធ ។ ក្រៅពីនោះក៏នៅទទួលបានដំណឹងល្អដែលមានប្រយោជន៍ដល់ជាតិ និងការងាររបស់លោកអ្នកតទៅអនាគតទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញផលកម្រៃទទួលបានកាក់កបគ្រាន់បើតែហាមកុំជួញដូរផ្លូវឆ្ងាញប្រយ័ត្នមានបញ្ហាដល់ខ្លួន ។ រីឯបញ្ហាស្នេហាគូស្នេហ៍អាចមានការរកាំរកូសគ្នាខ្លះ ប៉ុន្តែមិនធ្ងន់ធ្ងរនោះទេ ៕

## ឆ្នាំមមី

លោកអ្នកអាចនឹងមានអារម្មណ៍ច្របូកច្របល់បន្តិចនៅក្នុងរយៈពេលនេះ ព្រោះកិច្ចការដែលថា នឹងទទួលបានផលល្អនោះ វាអាចមានការប្រែប្រួលដោយសារតែមានការរំខានពីអ្នកដទៃ ។ បើចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចរកផលកម្រៃគ្រាន់ បើគួរជាទីគាប់ប្រសើរជាងមុន ។ រីឯបញ្ហាស្នេហាពុំមានផលរមាស់អ្វីនោះឡើយ ៕

## ឆ្នាំមមែ

អាចពោលបានថា លោកអ្នកមានសេចក្តីសុខក្នុងជីវិត និងការងារ ព្រោះវិបត្តិ និងភាពស្មុគស្មាញដែលមានកន្លងមកក៏បានធូរស្រាលឡើងវិញមួយកម្រិតផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ ទោះបីជាចេញទៅជួញដូរនៅទីណាក្តី គួរចៀសវាងការដាក់ទុនថ្មីព្រោះអាចនាំឱ្យខាតបង់ ។ រីឯបញ្ហាស្នេហាគូស្នេហ៍ច្រើនប្រចណ្ឌខុសរឿង ៕

## ឆ្នាំវក

រាល់ការបំពេញការងាររបស់លោកអ្នកក្នុងរយៈពេលនេះសុទ្ធតែផ្តល់នូវអត្ថប្រយោជន៍ គួរឱ្យជាទីពេញចិត្តទាំងអស់គ្មានអ្វីមករាំងស្ទះឡើយ ហើយជាងនេះទៀត នោះគម្រោងការដែលបានត្រៀមទុកជាយូរមក ហើយក៏នឹងបានសម្រេចផងដែរ ។ បើជាអាជីវកររកស៊ីវិញ មានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ រីឯបញ្ហាគូស្នេហ៍ច្រើនយល់ចិត្តគ្នា និងនឹករលឹកគ្នា បើនៅឆ្ងាយ ៕

## ឆ្នាំរកា

រាល់ការបំពេញការងារទាំងឡាយលោកអ្នកមិនមានបញ្ហាអ្វីចោទនោះទេ ប៉ុន្តែក្នុងនោះ សូមប្រយ័ត្នកុំយកអាសាមនុស្សសម្បុរសឱ្យសោះ ព្រោះនាំឱ្យកើតរឿងសៅហ្មងទៅថ្ងៃក្រោយ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចសន្សំទុកបានខ្លះ ។រីឯបញ្ហាស្នេហាចូរកុំយកភាពមានះចង់ចាញ់ឈ្នះប្រយ័ត្នកើតមានជម្លោះវិវាទឈានដល់ការប្រេះស្រាំ ៕

## ឆ្នាំច

លោកអ្នកនឹងទទួលបាននូវលាភសក្ការៈពីភាគហ៊ុនរកស៊ី និងមិត្តរួមការងារយ៉ាងច្រើនគួរឱ្យពេញចិត្ត ។ លើសពីនេះទៅទៀតគម្រោងការដែលបានត្រៀមទុកនឹងបានសម្រេចដូចបំណងទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ គួរជួញដូរនៅទីជិតៗទើបសមប្រកប ។ រីឯបញ្ហាស្នេហាគូស្នេហ៍ចេះស្តាប់ឱវាទគ្នា ៕

## ឆ្នាំកុរ

រាល់កិច្ចការដែលលោកអ្នកប៉ងប្រាថ្នា ជាយូរមក ហើយនោះក្នុងរយៈពេលនេះ គឺបានសមដូចបំណង ហើយគ្មានអ្វីមករារាំងនោះទេ ហើយរាល់ការប៉ងយាយីពីមនុស្សដែលមានបំណងមិនល្អមកលើលោកអ្នកនោះក៏មិនបានសម្រេចដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចពង្រីកអាជីវកម្មឱ្យធំបន្ថែមទៀតបាន ។ ឯបញ្ហាស្នេហាគូស្វាមីភរិយាមានភាពសុខដុមរមនាគ្មានផលរមាស់អ្វីឡើយ ៕

## សាគូ សាម៉ុត

# ប្រវត្តិសាស្ត្រកម្ពុជា និង វរជនខ្មែរ

តពីលេខមុន

ប្រធាន “គណបក្ស ប្រជាធិបតេយ្យ” ដែលទើបនឹងបង្កើត នៅខែមេសា ១៩៤៦ ដោយ លោក ស៊ឹម វ៉ា, ឈាន វ៉ន, អៀវ កើស ។ ប្រទេសកម្ពុជា បានប្រើពហុបក្ស រហូតដល់ឆ្នាំ ១៩៥៥ ជាឆ្នាំបង្កើត “សង្គមរាស្ត្រនិយម” ដោយ សម្តេច សីហនុ ។ នៅថ្ងៃទី ១ កញ្ញា ១៩៤៦ មានការបោះឆ្នោត សភាធម្មនុញ្ញ ជាលើកទី ១ នៅកម្ពុជា ដែល មិនដែលមាន សោះ នៅប្រទេសនេះ ។ ក្នុង ចំនួន ៦៧ អាសនៈ នៅសភា គណបក្ស ប្រជាធិបតេយ្យ បានទទួល ៥០ អាសនៈ ។ ទ្រង់ យុត្តិវង្ស ជាស្ថាបនិកម្នាក់ នៃ រដ្ឋធម្មនុញ្ញ ដែលអនុញ្ញាត ឲ្យ មហាក្សត្រ សីហនុ ប្រកាសឲ្យប្រើ នៅថ្ងៃទី ៦ ឧសភា ១៩៤៧ **“ប្រទេសកម្ពុជា ជាប្រទេស រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ”** ។ ជា គណបក្ស ឈ្នះឆ្នោត ស៊ីសុវត្ថិ យុត្តិវង្ស ត្រូវបានតែងតាំងជា នាយករដ្ឋមន្ត្រី ពីថ្ងៃទី ១៥ ធ្នូ ១៩៤៦ ដល់ថ្ងៃទី ២៤ កក្កដា ១៩៤៧ ។ ទ្រង់ យុត្តិវង្ស បានចរចាជាមួយ បារាំង ជាច្រើនលើក ដែលអនុញ្ញាតឲ្យបារាំង ផ្តល់ដល់ កម្ពុជានូវ “លក្ខន្តិកៈរដ្ឋស្វ័យត នៅក្នុងសភាបារាំង” ។ ទ្រង់ យុត្តិវង្ស បានចូលទីវង្គត នៅថ្ងៃទី ១១ សីហា ១៩៤៧ ដោយ “ជម្ងឺ” តែមតិខ្លះនិយាយថា “សុគតទាន់ហន់” របៀប នេះ បង្កើតឲ្យមានការសង្ស័យ ។ ស៊ីសុវត្ថិ យុត្តិវង្ស ជាក្សត្រាខ្មែរម្នាក់ ជាវរជន ជាបញ្ញវន្ត មានប្រាជ្ញាវាងវៃ ដែលពិបាករក ក្សត្រា-ក្សត្រី ណា មកប្រៀបនឹងព្រះអង្គបានឡើយ ។

## ស៊ីសុវត្ថិ សិរិមតៈ
### (១៩១៤ - ១៩៧៥)

អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ មានវង្សត្រកូលពី ព្រះបាទ ស៊ីសុវត្ថិ និង ត្រូវជា បងជីដូនមួយ សម្តេច សីហនុ (លើស ៨ ឆ្នាំ) ។ ទ្រង់ សិរិមតៈ បានធ្វើជា រដ្ឋមន្ត្រី ច្រើនលើក នៅទសវត្ស ឆ្នាំ ១៩៥០ និង ឆ្នាំ ១៩៦០ ។ ទ្រង់មាននិន្នាការនយោបាយស្តាំនិយម និង ធ្លាប់បានធ្វើចំណាប់អារម្មណ៍នយោបាយ ទៅ សម្តេច សីហនុ ពីកង្វះភាពសេរីនិយម ។

ឧបនាយករដ្ឋមន្ត្រី **“រដ្ឋាភិបាល ស្រោចស្រង់ជាតិ”** ចុងឆ្នាំ ១៩៦៩ ស៊ីសុវត្ថិ សិរិមតៈ ចាត់ចូលជា វរជន ដ៏សំខាន់ម្នាក់ នៃ ព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ ក្នុងការទម្លាក់ សីហនុ ពីតំណែង និង ជាអ្នកសំខាន់ម្នាក់ ក្នុងការបង្កើត “សាធារណរដ្ឋខ្មែរ” ចន្លោះឆ្នាំ ១៩៧១-១៩៧២ ។ គាត់បានស្លាប់នៅឆ្នាំ ១៩៧៥ ពេលដែលខ្មែរក្រហមយកអំណាចបាន ។

### ជីវប្រវត្តិ

អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ កើតនៅថ្ងៃ ២២ មករា ១៩១៤ នៅក្រុងភ្នំពេញ ។ នៅឆ្នាំ ១៩៤១ ទ្រង់ជា តួប្រជែងមួយរូប សំរាប់រាជបល្ល័ង្ក តែអាជ្ញាធរបារាំងអាណានិគម បានជ្រើសរើស សម្តេច នរោត្តម សីហនុ ជា មហាក្សត្រ ទៅវិញ ។ នៅឆ្នាំ ១៩៤៩ ទ្រង់ សិរិមតៈ បានដឹកនាំការចរចាចុះចូល ដាប ឈួន និង ក្រុមគាត់ ចំនួន ៤០០ នាក់ នៅតំបន់ សៀមរាប មករាជរដ្ឋាភិបាល ដែលអនុញ្ញាតឲ្យធ្វើពិធីបុណ្យអធិកអធម ថ្វាយកាំភ្លើងទៅ មហាក្សត្រ សីហនុ នៅអង្គរធំ ។

ទេសរដ្ឋមន្ត្រី នៅខែមិថុនា ១៩៥២ នៃ រាជរដ្ឋាភិបាល នរោត្តម សីហនុ ទ្រង់ សិរិមតៈ បានកាន់ក្តាប់ ក្រសួង ការពារជាតិ, ប៉ុស្តិ៍ និង ទូរគមនាគមន៍ នៅខែមករា ១៩៥៣ ។ រដ្ឋមន្ត្រី ការបរទេស នៃ រដ្ឋាភិបាល ប៉ែន នុត នៅខែកក្កដា ១៩៥៣, រដ្ឋមន្ត្រី ការពារជាតិ ពីខែ មករា ដល់ មេសា ១៩៥៥ ។ នៅខែកក្កដា ១៩៥៧ ដល់ខែមករា ១៩៥៨ គាត់ជា រដ្ឋមន្ត្រី ការពារជាតិ, ពត៌មាន និង ទេសចរណ៍ នៃ រដ្ឋាភិបាល ស៊ឹម វ៉ា ។

ពីឆ្នាំ ១៩៦២ ដល់ឆ្នាំ ១៩៦៤ ទ្រង់ សិរិមតៈ ជាអគ្គរាជទូតនៅប៉េកាំង, ពីឆ្នាំ ១៩៦៦ ដល់ឆ្នាំ ១៩៦៧ ជាអគ្គរាជទូតនៅតូក្យូ ។ នៅខែសីហា ១៩៦៩ ទ្រង់ សិរិមតៈ ជា ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុក មហាផ្ទៃ, សន្តិសុខ, អប់រំជាតិ និង កិច្ចការសាសនា ។ គាត់មាន ភារកិច្ចជា នាយករដ្ឋមន្ត្រីស្តីទី នៅពេលដែល លោក លន់ នល់ មកព្យាបាលរោគនៅ ស្រុកបារាំង នៅខែកុម្ភៈ ១៩៧០ ។

នៅឆ្នាំ ១៩៦៩ ដោយយល់ថា នយោបាយ “អព្យាក្រឹត” របស់ សម្តេច សីហនុ ជា ការចូលបក្សកុម្មុយនិស្តតាមព្រឹត្តិកិច្ច អាជ្ញាធរអាមេរិក និចសុន ទំនងជាបានទាក់ទងដោយ សម្ងាត់ លោក លន់ នល់ និង ស៊ីសុវត្ថិ សិរិមតៈ ដើម្បីស្ទង់ចិត្តចង់ដឹងថា មានបំណងប្រកាស “សាធារណរដ្ឋ” នៅកម្ពុជា ឬទេ ? ការបកស្រាយរបៀបនេះ បានត្រូវកែតម្រូវជាច្រើនលើកពី លន់ នល់ - សិរិមតៈ ដោយសំអាងថា នៅពេលនោះ សម្តេច សីហនុ កំពុង ធ្វើនយោបាយខិតទៅជិតលោកខាងលិច ដោយបានភ្ជាប់ចំណងទូតជាមួយ ស.រ.អា. នៅ ថ្ងៃទី ១១ មិថុនា ១៩៦៩ និង គ្រប់សុន្ទរកថាពេលចុងក្រោយ សម្តេច សីហនុ បានបង្ហើប ឲ្យដឹងថា មានទ័ពវៀតកុងនៅលើទឹកដីខ្មែរ ។

នៅថ្ងៃទី ១៨ មីនា ១៩៧០ ក្នុងខណៈដែល សម្តេច សីហនុ គង់នៅប៉េកាំង ទ្រង់ សិរិមតៈ បានតាមដានមើល លោក លន់ នល់ នាយករដ្ឋមន្ត្រី រៀបចំឲ្យ សភាទាំងពីរ ទម្លាក់ សម្តេច សីហនុ ពីតំណែងប្រមុខរដ្ឋ ។ ទង្វើនេះ បង្ខំឲ្យ សម្តេច សីហនុ ធ្វើការ សងសឹក រហូតធ្វើសម្ព័ន្ធមិត្តជាមួយកុម្មុយនិស្ត យួន-ចិន និង ខ្មែរក្រហម ។

គ្មានជំរើស រដ្ឋាភិបាលថ្មី លន់ នល់ - សិរិមតៈ ត្រូវស្ថិតនៅក្នុងជួរ ស.រ.អា. ដោយ ទទួលជំនួយ សេដ្ឋកិច្ច - យោធា ពី ស.រ.អា. ដើម្បីបង្ក្រាបខ្មែរក្រហម ។ លើសពីនេះ រដ្ឋាភិបាលថ្មី បានអនុញ្ញាតទ័ព អាមេរិក - យួនខាងត្បូង ធ្វើប្រតិបត្តិការសឹកក្នុងស្រុកខ្មែរ ដើម្បីកំទេច ភ័ស្តុភារយោធា - ស្បៀងអាហារ វៀតកុងក្នុងស្រុកខ្មែរ ។ ថ្ងៃទី ២៨ សីហា ១៩៧៣ ទ្រង់ សិរិមតៈ បានធ្វើលិខិតចំហរចំពោះ “ស្តេច សីហនុ” រៀបរាប់តាំងពី សម្តេច សីហនុ ឡើងគ្រងរាជ្យ, កែប្រែរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧ ដើម្បីបង្កើតតំណែង “ប្រមុខរដ្ឋ” នៅឆ្នាំ ១៩៦០, ចំនួនទ័ពយួនកុម្មុយនិស្តនៅស្រុកខ្មែរ ។

- នៅឆ្នាំ ១៩៦០ នៅពេល ព្រះសុរាម្រិត សុគតភ្លាម *“យុវជន រាជសង្គមនិយមខ្មែរ” ដែលជាអង្គការមួយ... ដែលប្អូនបង្កើតនេះ បានរៀបចំធ្វើបាតុកម្មតាមបញ្ជារបស់ប្អូន ដើម្បីទាមទារឲ្យប្អូនឯង ឡើងកាន់នាទីជា “ប្រមុខរដ្ឋ”... ។ ... សភាទាំងពីរបានរួមប្រជុំ ហើយជាបន្ទាប់មក គឺនៅថ្ងៃ ១៩ មិថុនា ១៩៦០ ក៏បានតែងតាំងប្អូនជា “ប្រមុខរដ្ឋ” ។*
- *“...ប្អូនបានលួចធ្វើការទាក់ទងយ៉ាង “ជិតស្និទ្ធ” ជាមួយ យៀកណាមខាងជើង-យៀកកុង រហូតដល់ទៅអនុញ្ញាតឲ្យពួកនេះតាំង មូលដ្ឋានទ័ព, មន្ទីរពេទ្យ, មជ្ឈមណ្ឌល-*

តទៅលេខក្រោយ




# Connect with over 20,000 residents in Lowell!




Soben Pin, Managing Partner




KhmerPost USA - Your portal to the 2nd largest Cambodian-American population in the United States

Free Full Color Biweekly Bilingual Cambodian-American Newspaper available over 100 locations serving Greater Lowell, Lynn, Boston and beyond.

**Call 978-677-7163** for a free quote today!

សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា

KhmerPost USA

KhmerPost USA | 45 Merrimack St., Suite 218A | Lowell, MA, 01852
Phone: 978.677.7163 | Fax : 978-677-7092
www.khmerpost.us | Info@khmerpost.us

# KhmerPost USA

The Cambodian-American Biweekly Newspaper

សារព័ត៌មានខ្មែរ-អាមេរិក ចេញពីរសប្តាហ៍ម្តង

a free local newspaper reaching over 20,000 Cambodian readers in the Greater Lowell area every two weeks

ផ្តល់ជូនកាសែតឥតគិតថ្លៃដល់អ្នកអានខ្មែរច្រើនជាង២០០០០នាក់នៅតំបន់ឡូវែលរាល់ពីសប្តាហ៍ម្តង

Soben Pin, Managing Partner អ្នកគ្រប់គ្រង សុបិន្ត ពិន

**978.677.7163 (Office) 978. 656.8141 (Mobile)**

សូមកក់ពាណិជ្ជកម្មអ្នកជាមួយយើងខ្ញុំ ហើយទទួលបានការបញ្ចុះតម្លៃ២០%

## Reserve Your 2014 Ads with us today and receive up to 20% OFF!

(Please mention this coupon ad: Summer 2014)

## Sample of our affordable pricing បញ្ជីតម្លៃពាណិជ្ជកម្មក្នុងតម្លៃសមរម្យ

| ទំហំទំព័រ Page Size | ប្រវែង Length x Width | 1ខែ 1 month | 3 ខែ 3 months 10%OFF | 6 ខែ 6 months 15%OFF | 12 ខែ 12 months 20%OFF |
|---|---|---|---|---|---|
| 1/2 page color | (6.5"x10") | $484 | $440/m | $411/m | $387/m |
| 1/4 page color | (6.5"x5") | $264 | $240/m | $224/m | $211/m |
| 1/4 Classify Ad | (6.5"x5") | $160 | | | |
| 1/8 Classify ad | (3.25"x5") | $100 | | | |
| Business Card | | $50 | | | |

## Our 2014 Publishing Dates កាលវិភាគបោះពុម្ព

| | |
|---|---|
| June 6th & 20th<br>July 11th & 25th<br>August 8th & 22nd | September 5th & 19th<br>October 10th & 24th<br>November 7th & 21st<br>December 5th & 19th |

*all ad materials are due one week prior to publishing date.

រាល់គំរូពាណិជ្ជកម្មត្រូវបញ្ជូន1សប្តាហ៍មុនចូលរោងពុម្ព




## Call or Visit our Sales Office

45 Merrimack Street. Suite 218A. Lowell, MA 01852

Tel: 978.677.7163. Cell: 978. 656.8141 Fax: 978.677.7092

Email: sobenpin@khmerpost.us or KhmerPostUSA@gmail.com

www.khmerpost.us | www.facebook.com/KhmerPostUSA





# ទេសចរណ៍បន្ទាយ សត្វស្លាបទឹក នៅតំបន់ព្រែកទាល់ខេត្តបាត់ដំបង

**ខេត្តបាត់ដំបង:** សត្វស្លាបទឹកនៅតំបន់ស្នូលព្រែកទាល់កំពុងមានចំនួនកើនឡើងច្រើន ក្រោយពីរាជរដ្ឋាភិបាលបានចាត់វិធានការអភិរក្សតាំងពីឆ្នាំ១៩៩៩មក។ ទន្ទឹមគ្នានេះ តំបន់សត្វស្លាបនេះ ក៏កំពុងទាក់ទាញភ្ញៀវទេសចរបរទេសឱ្យចូលទៅទស្សនាផងដែរ។

ក្រុមមន្ត្រីឧទ្យានុរក្សការពារនៅតំបន់ព្រែកទាល់បានសម្តែងក្តីព្រួយបារម្ភថា សត្វស្លាបទឹកនៅតំបន់ ព្រែកទាល់នោះ នៅតែបន្តរងគ្រោះ ដោយសារកម្លាំងអភិរក្សការពារនៅតំបន់នោះនៅពុំទាន់មានចំនួនគ្រប់គ្រាន់តាមតម្រូវការជាក់ស្តែង។

មធ្យោបាយធ្វើដំណើរទៅទស្សនាសត្វស្លាបទឹកនៅព្រែកទាល់មានតែការជិះទូកកាណូត។ ភ្ញៀវទេសចរទាំងអស់ពួកគេអាចទៅកម្សាន្តនៅទីនោះបានដោយចាប់ផ្តើមចេញដំណើរពីខេត្តបាត់ដំបង ទៅខេត្តសៀមរាប។ មុនពេលចូលដល់បន្ទាយសត្វស្លាបទឹកនោះពួកគេ និងបានឃើញនៅអមមាត់ស្ទឹងមានផ្ទះនៅក្នុងភូមិបណ្តែតទឹកក្នុងទឹកបឹងទន្លេសាប។ នៅតាមផ្លូវទឹកមើលឃើញមានឧបករណ៍នេសាទត្រី ដូចជាទូកកាណូត ឆ្នុកចាប់ត្រី បែចិញ្ចឹមត្រីមានទូកនេសាទទូកធំៗ ខ្លះមានដំបូល ជ្រកសម្រាប់ស្នាក់អាស្រ័យថែមទៀត។

នៅពេលធ្វើដំណើរតាមកាណូតចូលតាមដៃព្រែកនៃបឹងទន្លេសាបទៅដល់ទីជម្រកសត្វស្លាបទឹកដែលកំពុងរស់នៅនៅរដូវប្រាំងនេះ។ គេសង្កេតឃើញមានសត្វស្លាបជាច្រើនប្រភេទកំពុងរស់នៅទីនោះ។ សត្វស្លាបខ្លះកំពុងហែលទឹករកចាប់ត្រីធ្វើជាចំណី និងសត្វស្លាប ខ្លះទៀតកំពុងទុំនៅលើដើមឈើដែលនៅអមសងខាងមាត់ព្រែកក្នុងព្រៃព្រោងព្រាត។ សត្វស្លាបមួយចំនួនហាក់បីដូច ជាស៊ាំ គឺមិនផ្អើលនឹងក្រុមអ្នកទេសចរដែលចូលទៅឃើញពួកវាទេ។

លោក ញ៉ែម សំអាត ជាមន្ត្រីឧទ្យានុរក្សបន្ទាយសត្វស្លាបទឹកព្រែកទាល់។ លោករៀបរាប់ថា តាមការប៉ាន់ប្រមាណសត្វស្លាប់ទឹកដែលកំពុងអភិរក្សនៅក្នុងដែនបន្ទាយសត្វស្លាបព្រែកទាល់នេះ មានចំនួនជាង៦ម៉ឺនក្បាល។ បច្ចុប្បន្នមានសត្វស្លាបទឹកចំនួន១៣ប្រភេទទៀតកំពុងនាំគ្នាបង្កាត់ពូជថែមទៀត។

សត្វស្លាបទឹកនៅតំបន់ព្រែកទាល់មានជាច្រើនប្រភេទ។ សត្វស្លាបទឹកទាំងនោះជាប្រភេទសត្វកម្រនៅភូមិភាគអាស៊ី។ ក្នុងនោះមានសត្វស្មោញ សត្វរនាលស សត្វរនាលពណិ សត្វទុងស សត្វទុងប្រផេះ សត្វត្រដក់តូច ត្រដក់ធំ សត្វក្ងួនស សត្វអកត្រីក្បាលប្រផេះ សត្វពពូលទឹក សត្វអង្កត់ខ្មៅ សត្វត្រកៀលខ្សង សត្វក្អែកទឹក កុក គ្រោងតូច កុកគ្រោងធំ ក្រសារធ្នង់ ក្រសារប្រផេះ និងសត្វក្អែកជាដើម។ ប្រភេទសត្វស្លាបទឹកទាំងនេះ កំពុងរស់នៅក្នុងព្រៃទឹកបឹងទន្លេសាបនៃតំបន់ស្នូលព្រែកទាល់ស្ថិតនៅភូមិព្រែកទាល់ ឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ដែលកំពុងគ្រប់គ្រងដោយក្រសួងបរិស្ថាន។

រាជរដ្ឋាភិបាលកម្ពុជាក្រសួងបរិស្ថានបានចាប់ផ្តើមអភិរក្សសត្វស្លាប់ទឹកដ៏កម្រនៅតំបន់ស្នូលព្រែកទាល់នេះ កាលពីឆ្នាំ១៩៩៩។ ក្រោយមកនៅអំឡុងឆ្នាំ២០០៥ ក៏បានបង្កើតមជ្ឈមណ្ឌលគ្រប់គ្រងតំបន់ស្នូលព្រែកទាល់ថែមទៀត។ មជ្ឈមណ្ឌលគ្រប់គ្រងតំបន់ស្នូលព្រែកទាល់នេះបានបោះទីតាំងស្ថិតនៅក្នុងភូមិព្រែកទាល់ឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ដោយបានសង់អគារថ្មខ្ពស់មួយ មានបន្ទប់ជាច្រើនសម្រាប់ផ្តល់សេវាឱ្យភ្ញៀវទេសចរស្នាក់នៅបានថែមទៀត ។ភ្ញៀវទេសចរដែលធ្វើដំណើរពីខេត្តសៀមរាប ឬក៏ខេត្តបាត់ដំបងទាំងនោះពួកគេត្រូវទៅសំចតនៅមជ្ឈមណ្ឌលគ្រប់គ្រងតំបន់ស្នូលព្រែកទាល់។ នៅតំបន់ស្នូលព្រែកទាល់នោះ មានបង្កើតសហគមន៍អេកូទេសចរសម្រាប់ផ្តល់សេវាជូនភ្ញៀវទេសចរតាមរយៈការដឹកជញ្ជូនតាមទូកកាណូតជូនភ្ញៀវទៅទស្សនាសត្វនៅតាមដងព្រៃជាប់មាត់ព្រែកនានាដែលជាជម្រកសត្វស្លាបទឹកជាច្រើនប្រភេទកំពុងផ្តុំគ្នារស់នៅទីនោះ។ មន្ត្រីឧទ្យានុរក្សបន្ទាយសត្វស្លាបព្រែកទាល់បានអះអាងថា ចំនួនភ្ញៀវទេសចរធ្វើដំណើរទៅទស្សនាសត្វបានកើនឡើងជាបន្តបន្ទាប់រាល់ឆ្នាំ។ **តទៅទំព័រទី ២៣**





